ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសជ

**ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩**

**សវនាការលើកទី៤២**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលវ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក តាន់ សេណារ៉ុង

**អានីស អះម៉េត**

លោក ពេជ្រ សម្បត្តិ

លោក *ហ្សាធិរី ឡាំពែល* *(Mr.Zachery LAMPEL)*

***ជនជាប់ចោទ៖***

*លោក* កាំង ហ្កេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mrs.Marie-Paule Canizares)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក គឹម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

### លោកស្រី ជិន ម៉េត

សួរដោយ លោក សេង ប៊ុនឃាង ផ្តើមពី.....ទំព័រ ១២
សួរដោយ លោក អានីស អះម៉េត ផ្តើមពី.....ទំព័រ ១៧
សួរដោយ លោកស្រី ម៉ាទីន ហ្សាកកាំង ផ្តើមពី.....ទំព័រ ២០
សួរដោយ លោក គីម ម៉េងឃី ផ្តើមពី.....ទំព័រ ២៧
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី.....ទំព័រ ៣៤
សួរដោយ លោកស្រី ម៉ារីប៉ូល កានីហ្សារ ផ្តើមពី.....ទំព័រ ៣៧
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី.....ទំព័រ ៣៨

### លោកស្រី ណាំ ម៉ុន

សួរដោយ ប្រធានអង្គបុរេ ផ្តើមពី.....ទំព័រ ៤៤

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក **អានីស អះម៉េត** | អង់គ្លេស |
| លោកស្រី ម៉ារីប៉ូល កានីហ្សារ | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោកស្រី ជិន ម៉េត | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក តាន់សេណារុង | ខ្មែរ |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី | អង់គ្លេស |
| លោកស្រី ណាំ ម៉ុន | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលក្នុងបន្ទប់សវនាការ]*

[០៩:០៣:២៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ជិន ម៉េត ជាបន្ត ។ ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមាន និងបុគ្គលដែលត្រូវអញ្ជើញចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ ចំណែកឯបុគ្គលដែលមកត្រូវផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះដែរ ក៏មានវត្តមាន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អានីស អះម៉េត៖**

សូមគោរពលោកចៅក្រម លោកប្រធាន មុននឹងបន្តការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមានចំណុចតូចមួយដើម្បីបញ្ជាក់ ដោយមានការអនុញ្ញាត គឺថាចំណុចមួយ គឺកិច្ចការរដ្ឋបាលមួយគឺបញ្ហារឿងខ្លឹមសារ ។ សំណើទាក់ទងនឹងកិច្ចការរដ្ឋបាលនោះ គឺសក្ខីកម្មរបស់សាក្សីសម្រាប់សប្តាហ៍ក្រោយនោះ លោកចៅក្រមបានដាក់កាលបរិច្ឆេទ គឺសាក្សីពីរសម្រាប់ពីរថ្ងៃ សម្រាប់អាទិត្យក្រោយ ហើយខ្ញុំសូមមានការណែនាំ សម្រាប់ពេលភាគីនីមួយៗ សម្រាប់ភាគីនីមួយៗផ្តល់សក្ខីកម្ម ។ អ៊ីចឹង គឺថាយើងមានសាក្សីម្នាក់សម្រាប់មួយថ្ងៃប៉ុន្តែ ដើម្បីឲ្យយើងរៀបចំបានស្រួល ដើម្បីឲ្យយើងធ្វើអង្គជំនុំជម្រះអាចណែនាំយើងខ្ញុំ ។ ចំណុចមួយទៀត គឺទាក់ទងទៅនឹងលោកមេធាវី វ៉ែនណឺ គឺថាយើងចង់បានមួយម៉ោងកន្លះសម្រាប់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងមួយម៉ោងមេធាវីការពារ ។ អ៊ីចឹង គឺថាសំណើយើងដូច្នេះ-- ។ ចំណុចខ្លឹមសារទីពីរទាក់ទងទៅនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺទាក់ទងទៅនឹងរូបថតដែលបង្ហាញជូនលោកប្រធាន នៅពេលដែលសួរសំណួរទាក់ទងទៅនឹង នៅពេលដែលគាត់ទៅទួលស្លែងនោះ គាត់បង្ហាញរូបថតមួយដែលតាមថារូបថត

របស់គាត់ ។ ហើយរូបថតរបស់អ្នកទោសស្រីផ្សេងទៀត ដែលគាត់ស្គាល់នៅពេលដែលគាត់ទៅដំបូងនៅខែវិច្ឆិកា ឆ្នាំ២០០៧ ទៅទួលស្លែងនោះ ។ ខ្ញុំស្នើថារូបថតនោះ គឺថានឹងត្រូវដាក់ទៅក្នុងកំណត់ត្រាគឺដែលថាទាក់ទងទៅនឹងភស្តុតាងដែលពាក់ព័ន្ធទៅនឹងរឿងក្តីដែលគាត់ផ្តល់សក្ខីកម្មនេះ ។

សូមអរគុណ ។

[០៩:០៦:៤០]

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដែលបានមានចំណាប់អារម្មណ៍លើបញ្ហាអស់នេះ។ ចំពោះបញ្ហាកិច្ចការរដ្ឋបាលអំពីការកំណត់ពេលវេលាសម្រាប់ភាគីនោះ អង្គជំនុំជម្រះក៏បានពិភាក្សាគ្នាមុនពេលចូលមកនេះដែរ ដោយមានការចាប់អារម្មណ៍អំពីបញ្ហាមានការប្រែប្រួលលើពេលវេលាដែលកំណត់សម្រាប់ស្តាប់សក្ខីកម្មរបស់សាក្សី ដែលមានសាក្សីខ្លះកន្លះថ្ងៃ សាក្សីខ្លះមួយថ្ងៃ សាក្សីខ្លះមួយថ្ងៃកន្លះ អ្នកខ្លះទៀតពីរថ្ងៃនោះ ។ អ៊ីចឹង មានការប្រែប្រួលខុសពីការណែនាំរបស់អង្គជំនុំជម្រះពេលលើកមុនសម្រាប់តែការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សីដែលត្រូវធ្វើក្នុងអំឡុងពេលមួយថ្ងៃប៉ុណ្ណោះ ។ ប៉ុន្តែជាក់ស្តែង គឺមានករណីខ្លះ គឺមានការប្រែប្រួលខុសពីមួយថ្ងៃ ។ ហើយអង្គជំនុំជម្រះបានពិភាក្សាគ្នាហើយ ហើយបញ្ហានេះអង្គជំនុំជម្រះនឹងជម្រាបជូនដំណឹងដល់ភាគីទាំងអស់នៅក្រោយ នៅក្នុងថ្ងៃនេះមុនដំណើរការសវនាការសប្តាហ៍ក្រោយ ។

ហើយចំពោះសំណើសូមពេលវេលាជាក់លាក់នោះ គឺអង្គជំនុំជម្រះនឹងពិចារណា យកទៅពិចារណានៅក្នុងអំឡុងពេល នៃពិភាក្សាអំពីការបែងចែកពេលវេលាសម្រាប់ភាគី ។

អញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមគោរពលោកប្រធាន!

អង្គជំនុំជម្រះក៏បានសម្រេចរួចហើយអំពីពេលវេលាសម្រាប់ភាគីម្នាក់ៗ ដើម្បីសួរសំណួរទៅសាក្សី ។ អង្គជំនុំជម្រះគិតថា សាមសិបមីនុតសម្រាប់សហព្រះរាជអាជ្ញា សែសិបមីនុតសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ហើយសែសិបនាទីសម្រាប់មេធាវីការពារ ។ យើងយល់ឃើញថាប្រសិនបើយើងបន្ថែមពេលវេលាក៏ត្រូវបន្ថែមឲ្យមេធាវីការពារ រីឯដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងសហព្រះរាជអាជ្ញាហ្នឹង គឺមាន

ប្រហែលជា ហុកសិបប្រាំពីរនាទីទៅហើយ ។ អ៊ីចឹង គឺថាមិនមានសមភាព នៃអំណាចទេ ។ ហើយៗ យើងមាន ចិតសិបមីនុតសម្រាប់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ។ អ៊ីចឹង ថាតើពេលវេលាដែល-- ហេតុអ្វីបានជាត្រូវបន្ថែមពេលទៅសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីនោះ? អ៊ីចឹងគឺថា ដែលថាពេលវេលាច្រើនជាងមួយថ្ងៃ ដើម្បីឱ្យសួរសំណួរទៅសាក្សីនោះ ។ មេធាវីការពារមិនឯកភាពទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីទេ ប្រសិនបើអង្គជំនុំជម្រះអនុញ្ញាតនោះ ។ ហើយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ មានមួយម៉ោងកន្លះនោះ យើងនឹងស្នើសុំមិនមែនពីរម៉ោងទេ យើងសូមពេលបីម៉ោងសម្រាប់មេធាវីការពារ ដើម្បីឱ្យខ្លួនអាចសំណួរទៅសាក្សីនោះដែរ ។

[០៩:០៩:៤៩]

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវីការពារក្តី ដែលបានកត់សម្គាល់បញ្ហានេះ ។ អង្គជំនុំជម្រះមិនបានគិតថា ទទួលតែសំណើភាគីម្ខាង ហើយខាងម្ខាងទៀតមិនគិតនោះទេ ។ អង្គជំនុំជម្រះប៉ុនប៉ងក្នុងការគណនាពេលវេលានេះឱ្យបានសមស្រប ឱ្យបានត្រឹមត្រូវ និងសមភាពរវាងភាគី ។ ហើយជាការគិតបឋមនេះ សូមជម្រាបថា អំឡុងពេលនៃពេលវេលាដែលបានចែករួចហើយ គឺឱ្យស្តាប់មួយថ្ងៃ ។ អ៊ីចឹងបើអង្គជំនុំជម្រះធ្វើតែកន្លះថ្ងៃវិញ ពេលវេលាដែលចែករួចហើយត្រូវចែកនឹងពីរ សែសិបមីនុត នៅសល់តែ ម្ភៃមីនុត សាមសិបមីនុត សល់ ដប់ប្រាំមីនុត នេះគឺជាគោលការណ៍ ។ តែបើសិនជាពីរថ្ងៃគុណនឹងពីរនេះជាមួយមូលដ្ឋានដែលគ្រោងនឹងគិតគ្រាន់តែមិនទាន់បានសម្រេចប៉ុណ្ណោះ ។ អ៊ីចឹង ទាំងភាគីទាំងអស់ត្រូវទទួលបានដូចគ្នា ប្រសិនបើធ្វើមួយថ្ងៃទទួលបាន សែសិបមីនុត ធ្វើពីរថ្ងៃទីទទួលបានប៉ែតសិបមីនុត ។ គឺយើងគណនាទៅលើផ្អែកលើមូលដ្ឋាននេះ ដោយសារអង្គជំនុំជម្រះបានជម្រាបជូនហើយថាកន្លងមក គឺយើងបានធ្វើការណែនាំកម្រិតពេលវេលា បែងចែកពេលវេលាសម្រាប់សួរដេញដោលនោះគឺការសួរដេញដោលសម្រាប់ធ្វើសវនាការតែមួយថ្ងៃទេ ។ ឥឡូវនេះ យើងកត់សម្គាល់ឃើញថាមានការប្រែប្រួលសាក្សីខ្លះ យើងធ្វើតែកន្លះថ្ងៃ សាក្សីខ្លះសំខាន់យើងធ្វើមួយថ្ងៃកន្លះ ខ្លះសំខាន់មែនទែន យើងធ្វើដល់ទៅពីរថ្ងៃ ។ អ៊ីចឹង មានការប្រែប្រួលអង្គជំនុំជម្រះបានពិចារណាពីបញ្ហានេះហើយ គ្រាន់តែមិនទាន់សម្រេចប៉ុណ្ណោះ ហើយនឹងសម្រេចនៅក្នុងថ្ងៃនេះ ពេលវេលាមួយជាក់លាក់ យើងនឹងប្រកាសអំពីពេលវេលាដែលធ្វើបែងចែកនៅការដេញដោលនេះ ។

ប៉ុន្តែ អង្គជំនុំជម្រះក៏សូមរំឭកផងដដែរថា ការកត់សម្គាល់ឃើញនៅក្នុងអំឡុងនៃការសួរដេញដោលពេលវេលាខ្លី ប៉ុន្តែការតាំងសំណួរមិនចំអង្គហេតុ វាឆ្ងាយពីអង្គហេតុ ឬក៏ក្រៅអង្គហេតុ ឬក៏សួរច្រំដែល សួរអស់ពេលទៅបានទាមទារសូមពេលបន្ថែមទៀត ក៏មកសួរសំខាន់ ។ សំណួរសំខាន់មិនប្រើពេលវេលាឲ្យអស់លទ្ធភាពទេ បែរជាសួរប្រាសចាកពីអង្គហេតុ ។ នេះជាការកត់សម្គាល់។ អ៊ីចឹងអត់មានលទ្ធភាពក្នុងការផ្តល់ពេលវេលាឲ្យទេ ប្រសិនបើពេលវេលាដែលចែកឲ្យហើយ ប្រើប្រាស់នៅក្នុងលក្ខខណ្ឌនៃសំណួរសំខាន់ពាក់ព័ន្ធបំណងដើម្បីស្វែងរកការពិត ហើយវានៅសំណួរសំខាន់ទៀតនោះអង្គជំនុំជម្រះនឹងពិចារណាថា នឹងអនុញ្ញាតផ្តល់ពេលវេលាបន្ថែមសមស្រប ដើម្បីឲ្យសម្តែងរកការពិត ។

[០៩:១២:៣៧]

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅដល់តំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើការសួរដេញដោលដល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជិន ម៉េត ។ ហើយសហព្រះរាជអាជ្ញាមានអំឡុងមានពេលវេលាសាមសិបមីនុត ។ សូមអញ្ជើញបាទ ។

**លោក សេង ប៊ុនឃាង**

សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ឈប់សិន! ឥឡូវបង្អង់ទៀត បីដងហើយមេ-- មានបញ្ហាអីទៀតទៅ?

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំក៏មានសំណើពីរទាក់ទងទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានេះ សំណើទីមួយ គឺរូបថតដែលបញ្ជាក់ដោយដើមបណ្តឹងរដ្ឋប្បវេណី ដែលថា ត្រូវដាក់ចូលក្នុងកំណត់ត្រានេះ ។ យើងចង់ដឹងថា តើរូបថតនេះយកមកពីណា? នៅពេលណាដែលគេបានថតនោះ? ហើយយើងត្រូវការព័ត៌មានផ្សេងទៀតទាក់ទងនឹងរូបថតនេះ ដែលត្រូវបានបង្ហាញជាលើកទីមួយពីម្សិលមិញនេះ ដោយមានសង្ខេបដោយមិនបានដឹង យើងដឹងជាមុនថា តើរូបថតនុ៎ងបានមកពីណា? និយាយពីអ្វីនោះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដើម្បីបំភ្លឺគោលជំហររបស់មេធាវីការពារនោះ គឺខ្លួនចង់ជំទាស់នឹងការដាក់ចូលនូវរូបថត ឬក៏ចង់ជំទាស់ទៅនឹងតម្លៃនៃភស្តុតាងនោះ?

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

ដរាបណាដែលយើងមិនបានព័ត៌មានគ្រប់គ្រាន់ ដែលធ្វើឲ្យយើងកំណត់ថា តើតម្លៃពិតប្រាកដនៃរូបថតនេះ? ហើយនិងថា តើពេលណាដែលគេថតនោះ?

យើងសន្និដ្ឋានថាមេធាវីត្រូវបានព័ត៌មាន ហើយបើសិនជាលោកចៅក្រមមានសំណួរអ្វី ខ្ញុំនឹងឆ្លើយដោយជាក់លាក់ទៅតាមសំណួរនោះ?

[០៩:១៤:៥៩]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា យើងអាចសួរទៅដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីឲ្យបង្ហាញរូបថតនោះ ដោយខ្ញុំគិតថា អង្គជំនុំជម្រះហើយនិងភាគីក៏មានស្ថានភាពដូចគ្នានឹងមេធាវីការពារដែរ យើងមិនទាន់ដឹងច្បាស់អំពីលក្ខណៈនៃរូបថតទាំងនេះទេ ។ ហើយប្រហែលជាមេធាវីអាចនឹងធ្វើសំណើបន្ទាប់ពីការបង្ហាញ ការបញ្ជាក់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ។ អ៊ីចឹងសូមឲ្យដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់ឡើងវិញ តើរូបថតនោះមានលក្ខណៈដូចម្ដេច? គាត់មានយោបល់ដូចម្ដេច?

**ប្រធានអង្គជំនុំ៖**

ម៉េចទៅដើមបណ្ដឹងរដ្ឋប្បវេណី មានរូបថតឯណាផ្សេងទៀតដែលថាចង់បង្ហាញនោះ មាន ដែរទេ? ហើយរូបថតនោះរូបថតអ្នកណាគេ?

**លោកស្រី ជិន ម៉េត៖**

ចាស, លោកប្រធាន រូបថត-- ខ្ញុំស្ដាប់មិនបានទេ ។ តើរូបថតហ្នឹងជារូបថតមិត្តនារីនៅក្នុងកង? ឬមួយរូបថតរបស់នាងខ្ញុំផ្ទាល់ ដែលខាងអង្គការជម្លមណ្ឌលអភិវឌ្ឍន៍សង្គមគេបានថត ហើយគេបានយកមកឲ្យខ្ញុំទុកជាភស្តុតាង?

**ប្រធានអង្គជំនុំ៖**

រូបថតហ្នឹងដូចពីរូបថតពីម្សិលមិញទេ ឬក៏រូបថតផ្សេងពីម្សិលមិញ?

**លោកស្រី ជិន ម៉េត៖**

ចាស, រូបថតហ្នឹងមានតែមួយច្បាប់ហ្នឹង ដូចពីម្សិលមិញហ្នឹង អត់មានរូបថតឯណាផ្សេងទៀតទេ ។

**ប្រធានអង្គជំនុំ៖**

រូបថតនេះយើងបានធ្វើការពិនិត្យ និងដេញដោលរួចអស់ហើយ អត់មានបញ្ហាអីមកលើកទៀតទេ ហើយបើមានរូបថតផ្សេង រូបថតណាមួយផ្សេងទៀត ដែលប៉ុនប៉ងក្នុងការដាក់បង្ហាញដល់អង្គជំនុំជម្រះនាពេលនេះ ។

**លោក គឹម ម៉េងឃី៖**

សូមជម្រាបប្រសាសន៍លោកប្រធាន! បើខ្ញុំមិនច្រឡំទេប្រហែលជាដើមបណ្តឹងរដ្ឋប្បវេណីលោកស្រីមិនយល់នូវអ្វីដែលកំពុងតែនិយាយនេះ ហើយខ្ញុំបញ្ជាក់បន្តិច គឺថាកាលពីម្សិលមិញ លោកស្រីបានលើករូបថតមួយដែលមានរូបស្រីពីរនាក់ ហើយថតទៅ គឺមានជាប់រូបលោកស្រីនៅទួលស្លែង ដែលគេអះអាងថា មានរូបលោកស្រីនៅទួលស្លែង គឺរូបថតហ្នឹង គឺមិនមែនដែល-- ជារូបថត ដែលលោកស្រីដែលបង្ហាញជូនអង្គសវនាការទេ ។ សូមអរគុណ ។

[០៩:១៧:៥៨]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះមានរូបណាផ្សេងទៀតទេ? ឥឡូវឲ្យមន្ត្រីតុលាការយកមកបង្ហាញយើងមើល៍ ។

[០៩:១៩:២៣]

រូបដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំដាក់បង្ហាញនៅចំពោះមុខអង្គជំនុំជម្រះ រូបដែលនៅក្នុងដៃរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះពិតមែនទេ ឬក៏មានរូបផ្សេងពីនេះ?

**លោក អានីស អះម៉េត៖**

សូមគោរពលោកប្រធាន! ខ្ញុំយោងទៅរករូបថតមួយដែលគាត់ឈរនៅខាងក្រោយ នៅរូបថតពាក់កណ្តាលខ្លួននៅក្នុងស-២១ ។ អ៊ីចឹង រូបដែលលោកប្រធានសួរអំពីបញ្ហានេះគាត់និយាយថា គាត់បានទៅទីនោះ ហើយខ្ញុំបានស្គាល់ពួកកងនារីជាមួយខ្ញុំ ខ្ញុំបានឃើញរូបថតខ្ញុំ នៅក្បែររូបថតមួយដែល

គាត់បញ្ជាក់ឈ្មោះ ហើយខ្ញុំបានទៅទីនោះក្នុងខែវិច្ឆិកា ឆ្នាំ២០០៧ ហើយបញ្ជាក់អំពីថា គាត់បានទៅទីនោះ គាត់ស្គាល់មនុស្សដែលត្រូវបានជាប់ឃុំនៅទីនោះ ហើយនេះគឺថាវាទាក់ទងទៅនឹងសក្ខីកម្មនេះ ។ ដូច្នេះហើយបានជាខ្ញុំស្នើដាក់រូបថតនេះទៅជាផ្នែកមួយនៃរឿងក្ដីនេះ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការសូមយករូបថតនេះជូនដល់មេធាវីការពារក្ដីដើម្បីពិនិត្យ ។ ពិនិត្យរូបនេះ ហើយពិនិត្យរូបដែលមានរង្វង់ក្រហម ។

[០៩:២២:២២]

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

ខ្ញុំមានសំណួរមួយទៅដើមបណ្ដឹងរដ្ឋប្បវេណី ។ យើងបានឃើញនៅលើរូបថតនេះ ដែលមានរូបថតមួយចំនួន ដែលថា មានមនុស្សពីរនាក់ដែលមានរូបភាពធំៗ ប៉ុន្តែអ្នកទាំងពីរនេះ គឺថាមិនមែនជាដើមបណ្ដឹងរដ្ឋប្បវេណីទេ អ្នកដែលរូបធំពីរហ្នឹង ។

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយបានទេ? រូបពីរថ្មី-- រូបពីរថតពីមុខ ពីមុខរូបថត ពីរនាក់ហ្នឹងអ្នកណាគេ?

**លោកស្រី ជិត ម៉េត៖**

ចាស, លោកប្រធាន រូបថតនារីពីរនាក់ដែលឈរពីមុខខ្ញុំហ្នឹង គាត់បានមកពីខេត្តកំពង់ធំ នៅស្រុកប្រាសាទបល្ល័ង្គ គាត់ធ្វើការកិច្ចការនារីឃុំ ។ គាត់បានធ្វើដំណើរការមកទស្សនកិច្ចនៅទីក្រុងភ្នំពេញដើម្បីមើលរូបភាពនៅក្នុងមន្ទីរទួលស្លែង ក៏ដូចជានៅបឹងជើងឯក ។ តែពេលដែលគាត់ចូលក្នុងមន្ទីរទួលស្លែងទៅគាត់បានឃើញរូបថតនាងខ្ញុំហ្នឹងនៅមានតាំងនៅក្នុងតាប្លូគេ ហើយគាត់បានថា “រូបនាងខ្ញុំពីមុនកន្លងមកគេបានថា ខ្ញុំហ្នឹងស្លាប់ហើយ ហើយគេបានធ្វើបុណ្យបញ្ជូនឲ្យខ្ញុំរួចអស់ហើយ” ។ តែក្រោយមកទៀត បាននាងខ្ញុំរស់ពីស្លាប់ ហើយខ្ញុំទៅស្រុកនៅឆ្នាំ១៩៨២ ។ ទៅបងប្អូនខ្ញុំទាំងអស់ក៏ផ្អើលជ្រួលច្របល់ថា ខ្ញុំបានស្លាប់ហើយ ហេតុអីបានតែមានមុខនៅរស់? ហើយធ្វើម៉េចបានរស់?-- រត់គេចយ៉ាងម៉េចបានរស់រានមានជីវិត? ទៅនាងខ្ញុំក៏មិនបានលើកហេតុផលហ្នឹងប្រាប់គេទេ ។ នាងខ្ញុំមិននិយាយអីទាំងអស់ គ្រាន់តែថា អរពេកដែលបានជួបឪពុកខ្ញុំ ។ តែគាត់បានអះអាងប្រាប់ខាងបុគ្គលិកមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមថា “រូបនាងខ្ញុំហ្នឹង ពិតជានៅមែន អត់ស្លាប់ទេ កាលមុនមកពីជម្លៀសមក ក៏

វាមកនៅស្រុក ។ តែឥឡូវដោយជីវភាពហ្នឹងវាយ៉ាប់យឺនពេក នាងខ្ញុំក៏បាននាំកូន ហើយនិងប្តីនាងខ្ញុំមករស់នៅកន្លែងគំនរសំរាមនៅស្ទឹងមានជ័យនេះ ដើម្បីប្រកបមុខរបររកស៊ីចិញ្ចឹមជីវិត ។

[០៩:២៥:០០]

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្តី ឥឡូវហ្នឹងមើលរូបមួយដែលមានរង្វង់ គូសរង្វង់នៅបន្ទាត់ពណ៌ក្រហមជុំវិញនេះជាមូលដ្ឋាន ហើយធៀបជាមួយនឹងរូបថតដែលបានបង្ហាញពីម្សិលមិញ ។ បញ្ហាដែលប៉ុនប៉ងនៃការលើកនេះ គឺក្នុងបំណងនៃការពិភាក្សាមួយអំពីភាពពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញ របស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលវាមានអត្ថិភាពនៃរូបថតរបស់គាត់នៅទីនោះ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

លោកប្រធាន! យើងត្រឡប់ទៅរូបថតមួយក្នុងចំណោមរូបថតពីរ ។ នេះជារូបថតដែលយើងបានទទួលថា ជាមុខរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយយើងមិនជំទាស់ទេដែលថា រូបថតនេះបានថតនៅព្រៃស មិនមែនថតនៅស-២១ ទេ ។

ប្រសិនបើរូបថតនេះត្រូវបានយកមកស-២១ ហើយយើងគួរកត់សម្គាល់ថា ប៉ុន្តែយើងគិតថា វាមានចំណុចសំខាន់មួយដើម្បីកត់សម្គាល់ថា រូបថតនៃដើមបណ្តឹងរដ្ឋប្បវេណីនេះ មិនថតនៅស-២១ ទេ តែថតនៅព្រៃ-ស ថាតើព័ត៌មាននេះ គឺថាព័ត៌មាននេះយើងមិនជំទាស់នោះទេ ។ អ៊ីចឹងហើយយើងមិនជំទាស់ទៅនឹងការដាក់រូបថតពីរនេះទៅក្នុងរឿងក្តីនោះទេ ។

**ប្រធានអង្គជំនុំ៖**

អរគុណមេធាវីដែលបានធ្វើការកត់សម្គាល់ដូច្នេះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន ។ ដើម្បីឱ្យកត់ត្រានៅក្នុងប្រតិចារឹក យើងសូមឱ្យ-- យើងត្រូវទទួលបាននូវរូបថតទាំងនេះ ដើម្បីយើងដាក់-- អាចដាក់ចូលនៅក្នុងសំណុំរឿងជាផ្លូវការ ហើយក៏មានសារ-ប្រយោជន៍ដែរ សូមឱ្យតាំងរូបថតនេះនៅក្នុងអេក្រង់ ដើម្បីឱ្យភាគីយល់ថា តើយើងនិយាយពីរូបថតណាឱ្យពិតប្រាកដនោះ?

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការយករូបថតពីមេធាវីការពារក្តី ។

[០៩:២៧:៥០]

**លោក គីម ម៉េងឃី៖**

សូមអនុញ្ញាតលោកប្រធាន សូមបញ្ជាក់បន្តិច គឺយើងខ្ញុំមិនមានបំណងប្រឆាំងនឹងការផ្សាយទេ គ្រាន់តែបញ្ជាក់ថា ការអះអាងដែលថា រូបថតនេះថតនៅព្រៃស នោះ គឺមិនទាន់ពិតប្រាកដនៅឡើយទេ ពីព្រោះថា អ្វីដែលការអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់យើងខ្ញុំ គឺរូបថតដែលគាត់ថតនេះ គឺគាត់ថតមុនពេលដែលគេបញ្ជូនគាត់មកមន្ទីរឃុំឃាំង ។ ដូច្នេះ មិនមែនថតនៅព្រៃស ដូចមេធាវីការពារទេ ។ ក៏ប៉ុន្តែយើងក៏មិនទាន់ដឹងថា តើរូបថតហ្នឹង គេបញ្ជូនមកមន្ទីរទួលស្លែងជាមួយគាត់ ឬក៏បញ្ជូនដោយរបៀបណាទេ? ដូច្នេះ ការអះអាងថា រូបថតនេះថតនៅមន្ទីរព្រៃស នោះ គឺដើមបណ្តឹងរដ្ឋប្បវេណីមិនបានបញ្ជាក់ដូច្នោះទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

វាផ្ទុយទៅនឹងអ្វីដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនិយាយនោះ គឺខ្ញុំកត់សម្គាល់ពីម្សិលមិញទាក់ទងនឹងអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយ នៅពេលដែលលោកប្រធានសួរទៅដើមបណ្តឹងរដ្ឋប្បវេណី ថាតើរូបថតនេះថតនៅព្រៃស ឬថតនៅស-២១ នោះ? ដើមបណ្តឹងរដ្ឋប្បវេណីនិយាយយ៉ាងច្បាស់ថា "ត្រូវបានថតនៅព្រៃ-ស" គាត់បានឆ្លើយអ៊ីចឹង ។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយដូច្នោះហើយ ការសង្ស័យទាក់ទងទៅនឹងលក្ខខណ្ឌ ឬក៏កាលៈទេសៈនោះដែលថា រូបថតនេះថតនៅកន្លែងណាមួយនោះ គឺមិនមានទៀតទេ ពីព្រោះថាដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា រូបថតនោះបានថតនៅព្រៃស ។

[០៩:៣០:០០]

**លោកស្រី ម៉ាទីន ហ្សាកហ្វីន៖**

ខ្ញុំមិនឯកភាពទៅនឹងអ្វី ដែលមេធាវីការពារនិយាយនោះទេ ។ ខ្ញុំនឹងជូននូវសេចក្តីពន្យល់បន្ថែមនៅទីនេះ ។

ដើមបណ្តឹងរដ្ឋប្បវេណីផ្អែកទៅលើកំណត់សម្គាល់ដែលយើងប្រមូល គាត់បានប្រកាសថា រូបថតនោះត្រូវបានថតនៅក្នុងអង្គភាពរបស់គាត់ ។ ប៉ុន្តែ នៅពេលដែលគេធ្វើជីវប្រវត្តិនៅក្នុង ប្រវត្តិរូបនៅ

ក្នុងអង្គភាពរបស់គាត់ ប៉ុន្តែ គាត់មិនមានការគិតគូរអ្វីទេនៅពេលនោះ ប៉ុន្តែ ពេលដែលគាត់មកកន្លែងឃុំខ្លួន ប្រវត្តិរូប ហើយនិងរូបថតក៏បាននៅទីនោះ ។ ជនជាប់ចោទបាននិយាយថា ថតនៅព្រៃស ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីបានមកបញ្ជូនមកស-២១ ។ ប៉ុន្តែ រូបថតៗមិនមែនគាត់និយាយថា ថតនៅព្រៃស ឬថតពីមុន ប៉ុន្តែនេះជាអ្វីដែលយើងមាន យើងបានប្រមូលពីអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយពីម្សិលមិញនោះ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ខាងវ៉ាយថ៍ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។ បញ្ហានេះ ខ្ញុំចង់ធ្វើការបំភ្លឺជាមួយនឹងជនជាប់ចោទ ហើយខ្ញុំសូមសួរជនជាប់ចោទនូវសំណួរមួយ ដោយមានការអនុញ្ញាតពីលោកប្រធាន ។

ជនជាប់ចោទលោកបានលើកឡើងពីម្សិលមិញថា រូបថតរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបនេះ ដែលយើងឃើញមានបង្ហាញនៅស-២១ ជាការពិត គឺថតនៅព្រៃសនោះទេ ។ ប៉ុន្តែ លោកមិនបានផ្តល់ការពន្យល់បន្ថែម ហេតុអ្វីបានជាលោកមានជំនឿថា រូបថតនោះវាថតនៅព្រៃសទៅវិញ? ដូច្នេះ សូមឲ្យលោកជនជាប់ចោទធ្វើការពន្យល់បន្ថែមទៅលើចំណុចនេះបានដែរ ឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ ចៅក្រមជំនុំជម្រះជាទីគោរព! រូបថតនេះ ជាសេចក្តីបញ្ជាក់របស់ មិត្តម៉េត ដើមបណ្តឹងរដ្ឋប្បវេណី ។ គាត់ថារូបថត គឺរូបថតគាត់ថតនៅព្រៃស ប្រតិចារឹកម្សិលទុកតឹកតាងជូនអង្គសវនាការស្រាប់ ។ ឯចំណែក ប្រវត្តិរូប មិត្តម៉េត គាត់នៅច្របូកច្របល់ គាត់ថាប្រវត្តិរូបនេះធ្វើនៅអង្គភាពគាត់ ដល់ពេលខ្ញុំលើកឡើង ខ្ញុំងើបឡើង ខ្ញុំបញ្ជាក់ជូនអង្គសវនាការថា ប្រវត្តិរូបនេះធ្វើនៅព្រៃស ។ ភស្តុតាងគឺស-២១ ច្បាស់ថែស នៅត្រង់លេខ ERN ហើយក្នុងនោះដាក់ “កងចាស់៤៥០ បច្ចុប្បន្ននៅអង្គភាព១៧” ហើយមានទាំងថ្ងៃដែល មិត្តម៉េត មកដល់មន្ទីរស-២១មជ្ឈមណ្ឌលព្រៃស ។

[០៩:៣៣:៣២]

ដូច្នេះ ប្រវត្តិរូបមិត្តម៉េត គាត់ច្រឡំ ។ ឯចំណែករូបថត មិត្តម៉េត គាត់ប្រកាសខ្លួនគាត់ច្បាស់ណាស់ ។ នេះសូមជម្រាបប្រសាសន៍លោកជំទាវប៉ុណ្ណេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ ដូច្នេះ ដើម្បីធ្វើការបំភ្លឺ លោកបានធ្វើការសន្និដ្ឋានថា ដើម្បីការសន្និដ្ឋានឲ្យអង្គសវនាការនេះធ្វើការវិភាគ ។ រូបថតនោះបានថតនៅព្រៃសតាមរយៈការឆ្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ ហើយលោកមិនមានហេតុផលណាមួយក្នុងការលើកឡើងដូច្នោះទេ កាលពីម្សិលមិញ ។ តើត្រឹមត្រូវដែរឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ! ម្សិលមិញរូបថតហ្នឹង ខ្ញុំអនុម័តតាមពាក្យរបស់មិត្តម៉េត ។ ខ្ញុំអត់មានបន្ថែមការកត់សម្គាល់របស់ខ្ញុំបាទទៅលើបញ្ហានេះទេ ។ ក៏ប៉ុន្តែបើសិនលោកជំទាវថាត្រូវការឲ្យខ្ញុំបាទកត់សម្គាល់ ខ្ញុំបាទសូមជូនជាការកត់សម្គាល់ដូចតទៅ៖

ពួកអ្នកចូលមកព្រៃសទាំងប៉ុន្មាន ត្រូវថតដោយ មិត្តសុង អត់មានបានពាក់ស្លាកទេ ។ នេះ បើតាមខ្ញុំដឹង គឺមនុស្សផ្សេងទៅថត យូរៗទៅថតម្ដង ទៅជាប់រហូត នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ថាតើនៅព្រៃសគេអនុវត្តយ៉ាងម៉េចចំពោះការថតរូបនោះ?

**ជនជាប់ចោទ៖**

បញ្ហាជាក់ស្ដែងយ៉ាងម៉េច ខ្ញុំបាទក្ដាប់មិនបានទេ ។ ក៏ប៉ុន្តែ អ្នកដែលទទួលភារៈទៅថតនៅព្រៃសជាបុគ្គលិកម្នាក់នៃក្រុមថតរូប គឺជាបុគ្គលទីពីរ មានលំដាប់ទីពីរនៅក្នុងពួកថតរូបគ្នាគេហ្នឹង ។ បុគ្គលទីមួយឈ្មោះ មិត្តសៀង ថតនៅភ្នំពេញ ។ បុគ្គលទីពីរឈ្មោះ មិត្តសុង ចេញទៅថតនៅព្រៃសជាប់ជានិច្ច ។ ដូច្នេះ ការអនុវត្តថតយ៉ាងម៉េចខ្ញុំអត់ចូលជ្រៅដល់បញ្ហានោះទេ ។ សូមជម្រាបប្រសាសន៍លោកជំទាវប៉ុណ្ណោះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ថាតើគេថតរូបថតហ្នឹង ទៅតាមទម្លាប់ ឬតាមពេលវេលាជាក់លាក់ដែរឬទេ ដែលចំពោះអ្នកថតនៅព្រៃស?

[០៩:៣៦:១៩]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកជំទាវ! អ្នកថតនេះទាំងអស់គ្នាប្រាំ ប្រាំមួយនាក់នេះ នៅភ្នំពេញៗ ។

នៅខាងកើតគុកទួលស្លែង គេនៅជុំគ្នា ។ ប្រធានក្រុមរបស់គេឈ្មោះមិត្តសៀង ថតប្រចាំការនៅភ្នំពេញ ឯចំណែកអនុប្រធានក្រុមរបស់គេទៅថតនៅព្រៃស ។ ថ្ងៃណាដែលមានគ្នាច្រើន មិត្តហ៊ី គាត់ចាត់តាំងឲ្យថតម្តង ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ដូច្នេះខ្ញុំអាចសន្និដ្ឋានថា អ្នកដែលជាប់ឃុំទាំងអស់មិនចាំបាច់ថតទាំងអស់នោះទេ គឺមានមួយចំនួនប៉ុណ្ណោះ ដែលត្រូវថតនៅពេលដែលអ្នកថតពីស-២១ ទៅថតពួកគេ?

**ជនជាប់ចោទ៖**

ជាគោលការណ៍ត្រូវថតទាំងអស់ ពួកទៅខាងព្រៃស លើកលែងតែកុមារ បើតាមខ្ញុំចាំ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ គឺសូមអរគុណចំពោះជនជាប់ចោទ ប៉ុន្តែខ្ញុំមានពាក្យចុងក្រោយ ដែលខ្ញុំចង់បញ្ជាក់ ហើយនៅក្នុងភាសាអង់គ្លេសនោះ គឺប្រើពាក្យថា *ម៉ាក់ស្សុត៍* (Mug-short) គឺថតពាក់កណ្តាលខ្លួន យើងប្រើពាក្យនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដាក់បញ្ចាំងរូបថតអម្បាញ់មិញ រូបថតដែលមានចំនួនមនុស្សច្រើននាក់ ។

អញ្ជើញសហព្រះរាជអាជ្ញាក្នុងការសួរដេញដោល ហើយសុំដាក់បង្ហាញនូវរូបថត តើលោកចង់ដេញដោលរឿងអីទៅ? លោកមានពេល សាមសិបមីនុត សម្រាប់ការដេញដោលចាប់ពីពេលនេះទៅ ។

**លោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំអត់មានសំណួរទាក់ទងទៅនឹងរូបថតនេះទេ ហើយជម្រាបសួរលោកស្រី ជិន ម៉េត ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការដកយករូបថតហ្នឹង ចេញវិញ ។ សូមអញ្ជើញបន្តទៀត ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** អរគុណ ។ កាលពីម្សិលមិញលោកស្រីបាននិយាយថា នៅក្នុងកង៤៥០ នៃកងពលទីបី ដែលលោកស្រីធ្វើការនោះ បើសិនជាមាន-- ចង់សួរលោកស្រីថា តើនៅក្នុងកងពល៤៥០ ដែលលោកស្រីធ្វើការនោះ បើសិនជាមានអ្នកណាមួយធ្វើខុស តើគេចាប់បញ្ជូនទៅណាដែរលោកស្រីដឹងទេ?

[០៩:៤១:៤១]

**ឆ៖** ចាស, ខ្ញុំសូមជម្រាបថា នៅក្នុងអង្គភាពរបស់នាងខ្ញុំហ្នឹង នៅឆ្នាំ១៩៧៦ រហូតដល់ ៧៧ បើសិនជាមានមិត្តនារីណាម្នាក់ ធ្វើខុស ខុសឆ្គងក្នុងការនិយាយស្តី ដូចជានិយាយស្តីជាមួយបុរសក្តី ឬក៏អ្នកតូចធំក្តី ដែលជាចរិតមិនសមរម្យ ។ ប្រធានកងហ្នឹង គេហៅយកទៅអប់រំៗម្តងជាពីរដង មិត្តនារីនោះអត់កែប្រែទេ គេក៏ហៅទៅរៀនសូត្រ ។ រៀនសូត្រហើយបាត់ខ្លួនតែម្តង ។

**ស៖** អរគុណ ។ អ៊ីចឹងបានន័យថា លោកស្រីអត់ដឹងថា គេចាប់បញ្ជូនទៅមន្ទីរសន្តិសុខណា ឬក៏មណ្ឌលឃុំឃាំងណាទេ អ៊ីចឹងមែនទេ?

**ឆ៖** ចាស, នាងខ្ញុំមិនបានចាប់អារម្មណ៍ថា ពេលដែលគេហៅអ្នកដែលខុសឆ្គងបន្តិចបន្តួចនោះយកទៅដាក់ឃុំឃាំងនៅសន្តិសុខ ឃុំឃាំងនៅណា គឺពួកនាងខ្ញុំមិនបានចាប់អារម្មណ៍ទេ ចាប់អារម្មណ៍តែការរៀនសូត្រប៉ុណ្ណឹង គេហៅទៅរៀនសូត្រ ។

**ស៖** អរគុណ ។ អ៊ីចឹងតើលោកស្រីដឹងទេ ថានៅក្នុងកង៤៥០ ដែលលោកស្រីធ្វើការហ្នឹងមានកន្លែងឃុំឃាំងដែរទេ?

**ឆ៖** ចាស, នាងខ្ញុំមិនដែលដឹងទេ ព្រោះនៅពេលដែលមិត្តនារី បងៗខ្ញុំបាត់ខ្លួនតាំងពីទួលគោកនៅជ្រោយចង្វា នៅគីឡូលេខ៦ ពេលដែលខ្ញុំដឹងថាបាត់ហ្នឹង ក៏យើងសួរគេទៅអត់មានយកទៅឃុំ គេអត់មាននិយាយថា ពាក្យថាឃុំឃាំងទេ ។ ដូចខ្ញុំនិយាយពីមុនហើយថា មានតែពាក្យហៅយកទៅអប់រំ និងទៅរៀនសូត្រប៉ុណ្ណឹង ហើយនិងកន្លែងកងពលហ្នឹង ក៏មិនដែលដឹងថា មានមន្ទីរឃុំឃាំង មានកន្លែងសម្រាប់យកទៅ យកអ្នកដែលធ្វើខុសទៅអប់រំ ហើយឃុំឃាំងទេចាស ។ អត់មានដែលបានដឹងទេ ។

**ស៖** អរគុណ ។ និយាយមកដល់ពេលកន្លែងដែលគេចាប់លោកស្រីដាក់ឡាន លោកស្រីដឹងទេថាឡាននោះជាឡានរបស់អង្គភាពណា? ហើយមានអីសម្គាល់ទេ?

**ឆ៖** ចាស, នៅពេលដែលគេចាប់នាងខ្ញុំដាក់ឡានពីកន្លែងឃ្លាំងស្រូវគីឡូលេខ៦ មកដាក់ដល់ផ្ទះបងរិន នៅស្ពានជ្រោយចង្វា គឺខ្ញុំអត់មានបានចាប់អារម្មណ៍មើលឡាន មើលអីទេ ។ តែឡានហ្នឹង ព៌ណជា ព៌ណស្លែ ហើយឡានបើសិនជាឡាននេះ ឡានហ្នឹងសម្រាប់ដឹកទ័ពតែម្តង ។ ហើយឡានហ្នឹង បើឡានហ្នឹង ពួកនារីខ្ញុំច្រើនតែហៅថា ឡានអា*សេរសេ*កង់១០ ។

**ស៖** អរគុណ ។ នៅពេលដែលគេបញ្ជូនលោកស្រីចេញពីមន្ទីរឃុំឃាំងមួយនោះ ហើយគេបញ្ជូនលោកស្រីទៅព្រៃស ។ តើគេមានប្រាប់លោកស្រីថាមូលហេតុអីទេ? ហើយលោកស្រីដឹងទេ ថា

អ្នកណាជាអ្នកសម្រេចបញ្ជូនលោកស្រីទៅហ្នឹង?

**ឆ៖** ចាស, នៅពេលដែលគេបញ្ជូនខ្ញុំពីមន្ទីរឃុំឃាំងទៅព្រៃស នាងខ្ញុំក៏មិនបានដឹងថាជាព្រៃសដែរ ។ ហើយអ្នកដែលគេបញ្ជូនក៏គេអត់មាននិយាយអីទាំងអស់ ។ ពេលដែលគេហៅពួកនាងខ្ញុំទាំងបីនាក់ដាក់ឡានទៅ គេចងយើងយ៉ាងតឹង ហើយគេចងភ្នែកបិទទៀត ។ ពួកយើងទាំងអស់គ្នាគ្មានអ្នកណាមានសិទ្ធិនិយាយស្តីអីទាំងអស់ ។

ពេលដល់កន្លែងហើយបានឡានគេឈប់ហើយ មានបងស្រីម្នាក់រត់មកទទួលពេលនោះពួកខ្ញុំគេអត់មានសួរនាំថា យើងគេទុកយើងឲ្យនៅហ្នឹងក៏គេអត់មាននិយាយដែរ គឺគ្រាន់តែប្រាប់ថា មកទទួលយកនារីបីនាក់នេះទៅ ។ ខ្ញុំឮគេនិយាយអ៊ីចឹង ។

**ស៖** អរគុណ ។ នៅក្នុងពាក្យបណ្តឹងរបស់លោកស្រី លោកស្រីបានរៀបរាប់ថា ទាក់ទងទៅនឹងការដកសំណាប គេដាក់ផែនការឲ្យធ្វើមួយព្រឹកឲ្យបានពីរស្លឹកក្នុងមួយនាក់ ។ ចំណែកឯស្ទូងវិញ គឺក្នុងមួយថ្ងៃត្រូវស្ទូងឲ្យបានមួយហិចតា ហើយឲ្យមានក្រឡាឈើត្រង់ផង ។ សំណួរសួរថា តើនរណាជាអ្នកដាក់ផែនការនេះ លោកស្រីដឹងទេ? ហើយតើលោកស្រីមានដឹងទេថា នៅកងផ្សេងក្រៅពីកង១៧របស់លោកស្រីនោះ តើគេមានដាក់ផែនការបែបនេះដែរទេ?

[០៩:៤៦:៥២]

**ឆ៖** ចាស, តាមការ-- តាមដែលខ្ញុំរស់នៅ នៅក្នុងកង១៧ហ្នឹង ជាផែនការទូទៅនៅក្នុងកង១៦ កង១៧ ផែនការដូចគ្នាស្ទូងឲ្យមានក្រឡាឈើត្រង់ ហើយបើដកសំណាបទេឲ្យពួកយើងទៅដល់ម៉ោងបួនហ្នឹងគេឲ្យយើងដកក្នុងមួយព្រឹកពីម៉ោងបួនដល់ម៉ោងដប់មួយថ្ងៃត្រង់ឲ្យបានពីរស្លឹក ។ ផែនការដូចគ្នាតែគឺជាប្រធានកងទេអ្នកដាក់ប្រាប់ពួកខ្ញុំ តែបើអ្នកណាដាក់ពីលើទៀតខ្ញុំអត់ដឹងទេ គឺយើងទទួលពីបញ្ជាប្រធានក្រុមប្រធានកងមក ។

**ស៖** អរគុណ ។ នៅពេលដែលគេបង្ខំលោកស្រីឲ្យធ្វើការខ្លាំងហើយពេលមួយនោះលោកស្រីបានសន្លប់ តើមានគេនាំលោកស្រីទៅសង្គ្រោះអីទេពេលនោះ?

[០៩:៤៧:៥០]

**ឆ៖** ចាស, គ្មានទេ ។ ពេលនោះដូចខ្ញុំបាននិយាយជាមួយលោកប្រធានខាងដើមហើយថា នៅក្នុងកន្លែងខ្ញុំគ្មានថ្នាំព្យាបាល គ្មានកន្លែងមើលថែខាងផ្នែកសុខភាពទេ គឺយើងពេលណាដែលពេលយើងធ្វើការហត់ហេវពេក ហើយភ័យខ្លាចពេលនោះអារម្មណ៍យើងមានការភ័យខ្លាចហើយខ្លះទៅជាគាំងបេះ

ដូងខ្លះទៅជាសន្លប់ គឺនិយាយរួមទៅនៅក្នុងកងរបស់ខ្ញុំ១៧ ចង់គ្រប់ៗតែម្តង មិនមែនថាតែរូបខ្ញុំទេ ចង់គ្រប់គ្នាទាំងអស់ ។

**ស៖** អរគុណ អ៊ីចឹងមានន័យថានៅទីនោះគ្មានគ្រូពេទ្យប្រចាំសម្រាប់មើលអ្នកជំងឺអីទេ អ៊ីចឹង ។ តើនៅព្រៃសនោះ តើលោកស្រីត្រូវបានគេនាំយកទៅសួរចម្លើយ ឬក៏ធ្វើទារុណកម្មដូចនៅកន្លែងឃុំឃាំងមុនដែរទេ?

**ឆ៖** ចាស, អត់មានអ្នកណាគេហៅយើងទៅសួរចម្លើយទៀតទេ ទៅដល់កន្លែងកង១៧ ហ្នឹង គឺមានតែផែនការធ្វើការងារ ។ បើថាផែនការដាក់ឲ្យស្ទូងក្នុងមួយថ្ងៃ ក្នុងដប់នាក់ដប់ប្រាំនាក់ឲ្យបានមួយហិចតា គឺឲ្យបានមួយហិតាតែម្តង ។ ហើយបើថាធ្វើអី គឺដឹងតែធ្វើនុ៎ង តែបើហៅទៅសួរចម្លើយអត់មានទៀតទេ ។

**ស៖** អរគុណ ។ នៅក្នុងកងរបស់លោកស្រី តើលោកស្រីធ្លាប់ដែលបាននិយាយគ្នាជាមួយអ្នកផ្សេងទៀតថា មូលហេតុអីបានជាគេចាប់ខ្លួនមកកាន់កន្លែងនុ៎ងដែរទេ? លោកស្រីដែលធ្លាប់សួរគ្នាទេ?

**ឆ៖** ចាស, នាងខ្ញុំធ្លាប់សួរគេដែរ ព្រោះនាងខ្ញុំកាលនៅក្មេងហ្នឹងប៉ិនរប៉ិលរប៉ូចខ្លាំងដែរហ្នឹង តែពេលដល់តែសួរទៅមានអ្នកនារីៗហ្នឹងគេរាងអាយុច្រើនខ្ញុំ គេថា "មិត្តឯងកុំសូវនិយាយច្រើន កុំសួរនាំពេក កាលណាយើងចង់ដឹងរឿងច្រើនប្រយ័ត្នបាត់ខ្លួន ព្រោះយើងឃើញស្រាប់ហើយ ពីរថ្ងៃមួយឡានពីរឡានចូលមកពីបីថ្ងៃក្រោយមកបាត់អស់ ។ ដូច្នេះរឿងហ្នឹងយើងមិនចាំបាច់ចង់ដឹងទេ ឲ្យនាំគ្នាដាំដើមគទៅបានសុខ" ។

**ស៖** អរគុណ ។ លោកស្រីអាចជម្រាបបានទេ អំពីនៅ-- ទាំងនៅកន្លែងឃុំឃាំងមុននោះ ហើយនិងនៅព្រៃស តើលោកស្រីធ្លាប់ឃើញមនុស្សស្លាប់ដោយសារជំងឺ ឬក៏ដោយសារទារុណកម្មអីដែរទេ?

**ឆ៖** ចាស, នៅក្នុងមន្ទីរឃុំឃាំងខ្ញុំមិនដែលបានឃើញអ្នកណារងគ្រោះដល់ស្លាប់ទេ ហើយរហូតមកដល់នៅកង១៧ ក៏មិនដែលបានឃើញអ្នកណាស្លាប់ដោយសារនែ៎! រងគ្រោះការបង្ខិតបង្ខំធ្វើការងារដែរ តែបើឃើញសន្លប់ៗហើយពួកបងៗហ្នឹង គេយកមកទុកដាក់តែក្រោយមកទៀតក៏ពួកមិត្តទាំងអស់នោះបាត់ខ្លួនរហូត អត់ដែលឃើញមុខរហូត ។

**ស៖** តើលោកស្រីដឹងទេថា អ្នកណាជាអ្នកគ្រប់គ្រងធំជាងគេនៅព្រៃសនោះ?

**ឆ៖** នាងខ្ញុំមិនដែលដឹងទេ គឺស្គាល់មួយតែប្រធានកងនៅគ្រប់គ្រងខ្ញុំផ្ទាល់ហ្នឹង ស្គាល់តែឈ្មោះ បងញ៉ ហើយនិង បងអាង ដែលគាត់ជាមេកងរបស់យើងនៅក្នុងកង១៧ ហ្នឹង ។

[០៩:៥១:៤៦]

**លោក សេង ប៊ុនឃាង៖**

អរគុណ លោកប្រធានខ្ញុំអត់មានសំណួរទៅលើដើមបណ្តឹងរដ្ឋប្បវេណីនេះទៀតទេ ។ ប៉ុន្តែ សូមអនុញ្ញាតពីលោកប្រធាន ដើម្បីសួរសំណួរមួយ ឬក៏ច្រើនបើសិនជាមានពាក់ព័ន្ធទៅជនជាប់ចោទ ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត ។ ជនជាប់ចោទ គឺស្តាប់នៅសំណួររបស់តំណាងសហព្រះរាជអាជ្ញា ហើយឆ្លើយតបនឹងសំណួរ ។

**លោក សេង ប៊ុនឃាង៖**

អរគុណលោកប្រធាន ។ តាមការបញ្ជាក់របស់លោកស្រី ជិន ម៉េត ម្សិលមិញនោះ គាត់ថាគាត់បានឃើញរូបថតរបស់គាត់បិទនៅសារមន្ទីរទួលស្លែង ហើយរូបថតនោះអត់មានលេខសម្គាល់អ្វីទេ ។ អ៊ីចឹងតើលោកយល់យ៉ាងណាដែរ ចំពោះបញ្ហានេះ?

[០៩:៥២:៤៥]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! រូបថត ហើយនិងប្រវត្តិរូបសង្ខេប ។ ខ្ញុំសូមវិភាគជូនទាំងពីរនេះទន្ទឹមគ្នា ។ រូបថតទៅថតមនុស្សនៅឯព្រៃស តែយកមកផ្តិតនៅភ្នំពេញ ហើយអត់រក្សាទុកនៅព្រៃសទេ គឺរក្សាទុកនៅភ្នំពេញ ។ ប្រវត្តិរូបសង្ខេបដែល មិត្តហ៊ុយ គាត់ធ្វើហើយដែលយើងមានរាល់ថ្ងៃនេះ ដែលយើងមកប្រើនៅពេលនេះ គាត់ធ្វើនៅព្រៃស តែយកមកតម្កល់ទុកនៅភ្នំពេញមានលេខ TSLហ្នឹងជាភស្តុតាងស្រាប់ ។ ដូច្នេះ អត់ទៅប្រមូលយកពីព្រៃសទេ ប្រមូលនៅភ្នំពេញ ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**លោក សេង ប៊ុនឃាង៖**

អរគុណ លោកប្រធានខ្ញុំអស់សំណួរហើយ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ ។

មីក្រូទេដែលអត់បើក--

**លោក អានីស អះម៉េត៖**

លោកស្រី ជិន ម៉េត លោក-- បានផ្តល់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅពេលដែលលោកស្រីចុះបញ្ជី ។ ឯកសារនេះមាននៅក្នុងសំណុំរឿង ដូច្នេះហើយខ្ញុំសូមឲ្យសហការី និងសេវឹករបស់ខ្ញុំបង្ហាញនៅក្នុងអេក្រង់ គឺមានលេខ ERN00281156 ដល់លេខ 00281162 ដែលជាលេខ ERN ជាភាសាខ្មែរ ។ ដូច្នេះ សូមឲ្យមន្ត្រីតុលាការធ្វើការបញ្ចាំងទៅលើចំណុចនេះ ឯកសារនេះ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ បង្ហាញនៅឯកសារនេះលើកញ្ញក់អេក្រង់ទូរទស្សន៍ ។ បានបើកក្បាលមីក្រូ អត់បានបកប្រែទេ ស្តាប់អត់បានម៉េច? សូមសហព្រះរាជអាជ្ញានិយាយឲ្យបានយឺតជាងហ្នឹងបន្តិចដើម្បីមានការបកប្រែបាន ហើយនិយាយកុំភ្លេចបើកក្បាលមីក្រូ ។ អ៊ីចឹង ពេលវេលាអាចអស់ហើយដោយសារអត់បានបើកក្បាលមេក្រូហ្នឹងជិតអស់ហើយម៉ោង ។

[០៩:៥៥:៣៩]

**សួរដោយលោក អានីស អះម៉េត៖**

**ស៖** (តើខ្ញុំអាចសួរសំណួរដែរនៅពេលនេះ?) តើលោកស្រីអាចឃើញឯកសារនៅលើអេក្រង់នេះដែរឬទេ? ហើយលោកស្រីអាចបញ្ជាក់ថា លោកស្រីបានអានឯកសារហ្នឹងហើយ បានចុះហត្ថលេខា និងផ្តិតមេដៃដែរឬទេ? សូមឲ្យធ្វើការរុញវាឲ្យទៅដល់ចំណុចឯកសារ ទំព័រចុងក្រោយ ។ ឯកសារនេះ គឺទាក់ទងទៅនឹងឯកសារដែលលោកស្រីបាននិយាយទៅកាន់មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ដើម្បីចុះឈ្មោះ និងចុះបញ្ជីជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

**ឆ៖** ចាស, ខ្ញុំបានដាក់ពាក្យហ្នឹងពិតប្រាកដមែន ហើយមានស្នាមមេដៃរបស់នាងខ្ញុំពិតមែន ។

**ស៖** ហើយលោកស្រីបានអានឯកសារទាំងអស់នេះ ហើយបានធ្វើការចុះហត្ថលេខា ហើយ-លោកបានជឿជាក់ទៅលើខ្លឹមសារនេះ ថាវាពិតទាំងអស់ ។

**ឆ៖** ចាស, ខ្លឹមសារអស់ទាំងនេះ គឺខ្ញុំសរសេរដោយដៃផ្ទាល់ខ្លួនឯងតែម្តងទាំងអស់ គឺជាខ្លឹមសារដែលនាងខ្ញុំបានតាំងធ្វើ តាំងចិត្តថាធ្វើហ្នឹង ។ អត់មានខុសអ្វីទាំងអស់ គឺជាសរសេរដោយដៃខ្លួនឯង ហើយសរសេរពីអារម្មណ៍ខ្លួនទាំងអស់ ។

[០៩:៥៧:២៣]

**ស៖** ខ្ញុំអត់មានសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ ប៉ុន្តែជាស្នើសុំឲ្យអង្គសវនាការធ្វើការទទួលយកឯកសារនេះជាភស្តុតាង ។ គឺខ្ញុំដឹងហើយថា ខ្ញុំអស់ពេលហើយ ដូច្នេះ ទើបខ្ញុំនិយាយដូច្នេះ ។

លោកស្រី ជិន ម៉េត សំណួរខ្ញុំសួរបន្ទាប់ទៀតនោះ គឺថានៅក្នុងឯកសារដែលលោកស្រីទើបតែអាននេះ ទើបតែឃើញនេះ លោកស្រីបានលើកឡើងថា នៅថ្ងៃទី២ លោកស្រីបានដឹងថាលោកស្រីនៅទួលស្លែង តើលោកស្រីអាចបញ្ជាក់ទៅលើចំណុចលោកស្រីលើកឡើងដូច្នេះដែរឬទេ?

**ឆ៖** ចាស, នៅថ្ងៃដែលនាងខ្ញុំបានដឹងថា នាងខ្ញុំនៅនឹងទួលស្លែងនេះ នាងខ្ញុំមិនដឹងថាកាលដែលគេចាប់នាងខ្ញុំយកទៅឃុំនៅទួលស្លែង នាងខ្ញុំអត់ស្គាល់ទេ ។ តែដឹងហ្នឹង គឺដឹងនៅពេលដែលខាងមជ្ឈ-មណ្ឌលអភិវឌ្ឍន៍សង្គមហ្នឹង គេយកឯកសារទាំងអស់នេះ ហើយនិងរូបថតផ្ទាល់គេបានអញ្ជើញខ្ញុំមកមើលរូបថតផ្ទាល់ទៅបានខ្ញុំដឹងខ្លួនថា នាងខ្ញុំបានចូលគុកមន្ទីរឃុំឃាំងមែន តែមន្ទីរនោះមិនដឹងជាកន្លែងណាទេ ។ តែនាងខ្ញុំចាំបានថាឃុំ-- មន្ទីរកន្លែងឃុំឃាំងហ្នឹងជាអគារមួយដែលរាងបណ្តោយថ្ងៃ ។

**ស៖** នៅក្នុងឯកសារនេះ លោកស្រីបានលើកឡើង លោកស្រីបានដឹងថា ឌុច គឺជាប្រធាននៃគុកនោះ ហើយចំណុចនេះបានលើកឡើងនៅក្នុងទំព័រទី៤ ។

**ឆ៖** ចាស, ខ្ញុំបានដឹងហ្នឹង គឺមិនមែនខ្ញុំស្គាល់មុខ តាឌុច ហ្នឹងដោយផ្ទាល់-- បានឃើញបានស្គាល់ខ្ញុំមិនដែលស្គាល់គាត់ទេ តែឈ្មោះ មិត្តមឿន១ ដែលគាត់បានចូលឃុំជាមួយខ្ញុំនឹងគាត់នៅស្រុកស្ទោង ។ នៅស្រុកស្ទោងគាត់នៅដល់ធ្លាប់ដើរ ដល់ពៅរើយ ពាមបាង កន្លែងនុ៎ង គាត់ថា តាឌុច ហ្នឹងធ្លាប់នៅស្រុកជាមួយគាត់ ហើយគាត់បានស្គាល់ច្បាស់ ហើយឥឡូវហ្នឹងគាត់បានមកកាន់កាប់នៅកន្លែងគាត់ធ្វើជាមេសន្តិសុខនៅមន្ទីរទួលស្លែងហ្នឹង ។ តែយើងដឹងហ្នឹង ដឹងដែលពួកខ្ញុំទៅនៅព្រៃសហើយទេកាលដែលនៅមន្ទីរឃុំឃាំង យើងអត់បាននិយាយគ្នាអ្វីទាំងអស់ ហើយគេសួរខ្ញុំថា តើអ្នកស្គាល់តាឌុចទេ? ខ្ញុំថា ខ្ញុំអត់ដែលស្គាល់មុខគាត់ទេ តែឮតែឈ្មោះ តាំងពីនៅក្នុងអង្គភាពម្ល៉េះ ។

**ស៖** នៅក្នុងឯកសារដដែលនេះ លោកស្រីបានលើកឡើងថា គេធ្វើទារុណកម្មលោកស្រី គេបង្អត់បាយ ហើយគេដាក់ឲ្យលោកស្រីហាលភ្លៀង និងហាលខ្យល់ ហាលថ្ងៃ ។ តើលោកស្រីអាចបញ្ជាក់ថាចំណុចដែលថា គេដាក់ឲ្យលោកស្រីហាលថ្ងៃ ហើយនិងហាលភ្លៀងដែរឬទេ នៅលើចំណុចនេះ?

**ឆ៖** ចាស, គេដាក់ គេបានហៅយើងឲ្យចេញពីបន្ទប់ហើយ ប៉ុន្តែគេអត់មានបើកភ្នែក បើកមុខយើងទេ គេចងជាប់រហូត ហើយគេមាន គេអង្គុយសងខាង គេឲ្យយើងឈរហាលក្ដៅ គេអង្គុយដឹងម្ដប់ដឹងក្ដៅយើងអត់ដឹងទេ ព្រោះមើលអត់ឃើញ ប៉ុន្តែ នាងខ្ញុំឈររយៈអស់ប្រហែលជាពីរម៉ោងជាងមិនដឹងទេ ព្រោះពេលយូរៗទៅ យើងនឹងដួល ងងឹតមុខដួល ។ ពេលនោះហើយ អារម្មណ៍នាងខ្ញុំហ្នឹងចេះតែភ័យខ្លាចថាតើ គេឲ្យឈរនេះ ឈរដើម្បីអ្វី ឬមួយក៏នឹកឃើញក្នុងចិត្តថា គេឲ្យយើងឈរដើម្បីអ្វី ខ្ញុំនឹកឃើញថា ប្រហែលជាគេឲ្យយើងឈរដោយមិនមានដាក់ច្រវាក់មិនមានដាក់អ្វីទាំងអស់ ហើយគេថាឲ្យ បើសិនជាយើងរត់ គេនឹងបាញ់បំបាក់ជើង ឬគេបាញ់សម្លាប់ចោល អាហ្នឹងក្នុងអារម្មណ៍របស់នាងខ្ញុំ ។ តែក្រោយមកទៀត នាងខ្ញុំបានដួលស្រឹបទៅ អ្នកដែលគេមើលការពារយើងហ្នឹង គេក៏បានអូសយើងមកដាក់ក្នុងបន្ទប់វិញ ។

**ស៖** លោក លោកស្រីចៅក្រម នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ។ ម្សិលមិញលោកស្រីបានរៀបរាប់ប្រាប់អង្គសវនាការថា នៅពេលដែលអ្នកជាប់ឃុំរបស់លោកស្រីទៅងូតទឹក ហើយត្រឡប់មកវិញ គាត់បាននិយាយថា “កុំទៅងូតទឹកអី សុខចិត្តស្លាប់ជាងទៅ” តើលោកស្រីដឹងទេ តាមដែលលោកស្រីហ្នឹង ហេតុអ្វី តើមូលហេតុអីបានជាអ្នកជាប់ឃុំជាមួយលោកស្រី និយាយប្រាប់លោកស្រីដូច្នេះ?

**ឆ៖** ចាស, នៅពេលដែលគេយក មិត្តមឿន ឲ្យទៅមុជទឹកហើយ ពេលដែល មិត្តមឿន គាត់ត្រឡប់មកវិញ គាត់ក៏ដូចមានអារម្មណ៍ថា យំហើយ មានអារម្មណ៍ដូចឈឺចាប់ ហើយនាងខ្ញុំក៏បានចេះតែលួចមើលទៅថា វាយ៉ាងម៉េចឯង ចេញទៅមុជទឹកស្រួលខ្លួនទេ? វាគ្រវីក្បាលហើយ វាថា “អញប្រាប់ឲ្យហើយថា បើសិនជាសន្តិសុខហ្នឹង ហៅឯងឲ្យទៅងូតទឹក មិនម៉េចទៅទេ ទោះបីរាកអាចម៍រាកនោមម៉េចក៏ដោយ មិនបាច់ទៅទេ! សុខចិត្តនៅស្អុយក្នុងខ្លួនហ្នឹង” ។ ដល់ពេលនោះ ខ្ញុំក៏មានមិនមានចាប់អារម្មណ៍ថាយ៉ាងម៉េចទេ នឹកឃើញមួយខ្លាចថា “ចុះហេតុបានជាគេឲ្យទៅងូតទឹកសម្អាតខ្លួន កុំឲ្យធុំក្លិន ហើយឯងបែរជាយំវិញ?” តែរឿងផ្សេងទៀត នាងខ្ញុំមិនបានចាប់អារម្មណ៍ទេ ។ ហើយវាក៏អត់មាននិយាយរឿងអីប្រាប់យើងទាំងអស់ រហូតទៅដល់នៅព្រៃសដេកជាមួយគ្នាពីរយប់ វាអត់មាននិយាយទាំងអស់រហូតដល់វាបាត់ខ្លួនទៀត ។

**លោក អានីស អះម៉េត៖**

លោក លោកស្រីចៅក្រម ខ្ញុំពុំមានសំណួរទៀតទេ សូមអរគុណ ។

[១០:០៤:០៥]

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍បង្វែររូបទៅជាប្រក្រតីឡើងវិញ ។ តទៅនេះ ដល់វេទិកានៃមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រហែលជាក្រុមបី សូមអញ្ជើញ ។ ហើយលោកនិយាយអំពីលក្ខខណ្ឌនៃការសួរនេះផង ព្រោះតើលោកធ្វើដូចជាម្សិលមិញ បានន័យថាលោកចំណាយពេលវេលាជាច្រើននៅក្នុងការសួរ ឬក៏សួរតាមការកំណត់របស់អង្គជំនុំជម្រះ?

**លោក គីម ម៉េងឃី៖**

ជម្រាបប្រសាសន៍លោកប្រធាន លោក លោកស្រីចៅក្រម! គឺមេធាវីក្រុមបីរ គឺនឹងផ្តើមសំណួរដូចកាលពីម្សិលមិញដែរ គឺចំណាយពេលមួយចំនួនសម្រាប់ការតាំងសំណួរទៅកាន់ជនរងគ្រោះលោកស្រី ជិន ម៉េត ហើយការចាប់ផ្តើមការតាំងសំណួរនេះ គឺចាប់ផ្តើមដោយសហមេធាវីបរទេស គឺលោកស្រី ម៉ាទីនហ្សាកកាំង បន្ទាប់មកគឺរូបខ្ញុំបាទ ហើយម៉ោងដែលសេសសល់ និងទុកឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀត ។ សូមអរគុណលោកប្រធាន ។

[១០:០៥:២២]

**សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ហើយនិងជម្រាបសួរលោកស្រី ជិន ម៉េត។

**ស៖** ខ្ញុំនឹងសួរសំណួរមួយចំនួនទាក់ទងទៅនឹងប្រវត្តិរូប ដែលឲ្យមានព័ត៌មានបំភ្លឺថែមទៀត ។ ប៉ុន្តែ ជាដំបូងហេតុអ្វីបានលោកស្រីរស់នៅក្នុងជនបទមុនពេលដែលចូលរួមធ្វើកងទ័ពខ្មែរក្រហមនោះ?

**ឆ៖** ចាស,លោកស្រីមេធាវី! មុនដែលពេលចូលបម្រើឲ្យកងទ័ពបដិវត្តន៍ហ្នឹង នាងខ្ញុំរស់នៅជាមួយជីដូន ហើយនិងឪពុកមា ម្តាយមីងនាងខ្ញុំ នៅក្នុងភូមិជម្ពូស សង្កាត់ទួលគ្រើន ហ្នឹង គាត់មើលថែខ្ញុំដោយសារមានការផ្តល់ជាសម្ភារៈប្រាក់កាស មកចិញ្ចឹមខ្ញុំ ហើយឪពុកម្តាយខ្ញុំ ជីដូនខ្ញុំហ្នឹង គាត់បានផ្គត់ផ្គង់ឲ្យខ្ញុំរៀនសូត្រ ខ្ញុំបានខិតខំរៀនសូត្រហើយ មើលគោ មើលក្របីនៅហ្នឹង បងប្អូន និងជីដូនហ្នឹង ។

តែក្រោយដែលឆ្នាំ១៩៧០ គេទម្លាក់សម្តេច សីហនុ ទៅ ពួកនាងខ្ញុំលែងបានឈប់ អត់បានរៀនបន្តទៀតទេ ហើយក៏រស់នៅក្នុងភូមិធម្មតា ។ ដល់ក្រោយមកទៀតនៅឆ្នាំ១៩៧៤ហ្នឹង នៅក្នុងមូលដ្ឋានរបស់នាងខ្ញុំហ្នឹង ឈ្មោះ បងដែន គាត់បានដើរប្រមូលក្រុមនារីយុវជន នៅក្នុងភូមិនាងខ្ញុំបន្តបន្ទាប់ជារៀងរាល់ខែឲ្យចូលធ្វើការ អាខ្លះធ្វើទៅខាងមន្ទីរ អាខ្លះទៅខាងក្រសួង ។ ដល់ពេលប៉ះក្រុមនាងខ្ញុំក្រោយគេម្តែនាក់ហ្នឹង គេបញ្ជូនខ្ញុំឲ្យមកធ្វើជាកងទ័ពនារីវិញ មកនៅឈរជើងនៅខេត្តកំពង់ចាម ស្រុក

ជើងព្រៃ ។ ចាស, មេធាវី ។

**ស៖** ហេតុអ្វីពេលដែលលោកស្រីនៅក្មេង ហេតុអ្វីលោកស្រី និងម្ដាយ ហើយឪពុករបស់លោកស្រីធ្វើអ្វីដោយពិតប្រាកដនៅពេលនោះ?

**ឆ៖** ចាស, លោកស្រីមេធាវី! ឪពុកនាងខ្ញុំកាលហ្នឹង នាងខ្ញុំមិនដែលស្គាល់ ហើយមិនដែលឃើញគ្រាន់តែឮជីដូនជីតាខ្ញុំហ្នឹង បានប្រាប់ថា ឪពុកនាងខ្ញុំ តាំងពីធំដឹងក្ដីឡើង គាត់រៀនរហូតៗ ដល់ជីតាខាងឪពុក-ម្ដាយគាត់ ឪពុកគាត់ហ្នឹងលក់អស់កេរអាករ គោក្របី ដីស្រែហ្នឹង ដើម្បីឲ្យគាត់ខំរៀនឲ្យមានចំណេះ ហើយនិងបានធ្វើការ ។ ពេលដែលឪពុកខ្ញុំបានធ្វើជាប៉ូលិសហើយ អ៊ឺ! ជីដូនជីតាខាងឪពុកខ្ញុំហ្នឹង គាត់បានលក់ៗអស់កេរខាងគាត់ ដើម្បីឲ្យគាត់បានមានស័ក្ដិពាក់ ហើយរហូតដល់គាត់បានធ្វើការ រហូតបានម្ដាយខ្ញុំហ្នឹង ។ ហើយខ្ញុំតាំងពីកើតមក ខ្ញុំអត់ដែលស្គាល់មុខឪពុកខ្ញុំទេ យ៉ាងម៉េចទេ ខ្ញុំស្គាល់តែតាមរូបថតទេ ។

**ស៖** ចុះម្ដាយលោកស្រីវិញ ដូចម្ដេចដែរ?

[១០:០៩:០៩]

**ឆ៖** ចាស, លោកស្រីមេធាវី! ឯចំណែកម្ដាយខ្ញុំ ក៏មិនដែលបានឃើញមុខគាត់ដែរ ។

**លោកស្រី ម៉ាទីន ហ្សួកកាំង៖**

ជម្រាបប្រសាសន៍លោកប្រធាន! ប្រហែលយើងត្រូវការសម្រាកពីរបីនាទី ដើម្បីឲ្យអនុញ្ញាតឲ្យលោកស្រី ជិន ម៉េត ឲ្យគាត់គ្រប់គ្រង ឬក៏ថាមានអារម្មណ៍ស្ងប់បន្តិច ។

**ប្រធានអង្គជំនុំ៖**

លោកស្រី ជិន ម៉េត ឥឡូវហ្នឹងត្រូវការសម្រាក ឬក៏អាចបន្តសវនាការទៀត ។ ឥឡូវ ជម្រើសយកមួយណា?

**លោកស្រី ជិន ម៉េត៖**

**ឆ៖** ចាស,លោកប្រធានខ្ញុំអាចបន្តបានទៀត ។ ចំពោះម្ដាយនាងខ្ញុំ គឺនាងខ្ញុំមិនដែលបានស្គាល់មុខគាត់ទេ ព្រោះកាលដែលគាត់ទៅកើតខ្ញុំហ្នឹង ឪពុកខ្ញុំនៅឈរនៅស្រុកស្ទោង ។ ទៅ ម្ដាយខ្ញុំទៅលេងជាមួយឪពុកខ្ញុំទៅ ហើយម្ដាយខ្ញុំក៏បានកើតខ្ញុំនៅស្រុកស្ទោងនៅកន្លែង ផ្ទះឪពុកខ្ញុំនៅកន្លែងមេព្រៃចាស់នៅស្រុកស្ទោងហ្នឹងហើយ បានរយៈបីខែ ហើយម្ដាយខ្ញុំគាត់ទាស់ស្លាប់ទៅ ។ សូម្បីតែរូបថត ក៏ម្ដាយខ្ញុំអត់មានបានបន្សល់ទុកឲ្យខ្ញុំឃើញមុខដែរ ។ ហើយពេលដែលម្ដាយខ្ញុំបានស្លាប់ទៅ អ៊ឺ!ជីដូនជីតាខាង

ម្តាយខ្ញុំហ្នឹង គាត់ទៅយកខ្ញុំមកចិញ្ចឹមនៅឯភូមិជម្ពូស ស្រុកប្រាសាទបល្ល័ង្គ រហូតដល់ខ្ញុំធំពេញវ័យ ។

**ប្រធានអង្គជំនុំ៖**

សូមរំឭកមេធាវីថា សូមប្រឹងប្រែងដើម្បីរៀបចំសំណួរឲ្យពាក់ព័ន្ធជាមួយនឹងអង្គហេតុ ការសួរសាវតារប្រវត្តិវែងឆ្ងាយហ្នឹង គឺមិនការមិនពាក់ព័ន្ធទៅនឹងអង្គហេតុនេះទេ ពីព្រោះអង្គហេតុនេះ គឺជាប់ពាក់ព័ន្ធនឹងការឃុំឃាំងគាត់នៅ ដែលសង្ស័យថានៅក្នុងមន្ទីរស-២១ មជ្ឈមណ្ឌលភ្នំពេញ ហើយក្រោយមកនៅព្រៃស ហើយឥឡូវនេះ ក៏បានសួរព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងព្រៃសហើយ ។ អ៊ីចឹងសូមពាក់ព័ន្ធនឹងសំណួរដែលពាក់ព័ន្ធនឹងអង្គហេតុ ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោកប្រធាន ។ សំណួរពីមុនដែលខ្ញុំសួរនោះ គឺដើម្បីផ្សាភ្ជាប់ទៅនឹងសំណួរដូចតទៅនេះ ដែលជាសំណួរមួយចំនួន ដើម្បីឲ្យយល់ព័ត៌មានបានច្បាស់ ។

**ស៖** តើលោកស្រី ជិន ម៉េត ចូលរួមក្នុងខ្មែរក្រហមដោយស្ម័គ្រចិត្តដែរឬទេ? ថាតើក្នុងលក្ខខណ្ឌណាដែលគាត់ចូលរួមនោះ ។ នេះហើយដែលខ្ញុំសួរទាក់ទងទៅនឹងកាលពីគាត់នៅយុវវ័យនោះ ។

**ឆ៖** ចាស,លោកស្រីមេធាវី! នៅពេលដែលខ្ញុំចូលក្នុងកងទ័ពនារីហ្នឹង ជាលើកទីពីរ អង្កាល់ដែលគេប្រមូលលើកទីមួយ នាងខ្ញុំមានគ្នាប្រាំនាក់ គេប្រមូលពួកនាងខ្ញុំឲ្យធ្វើជានារីបដិវត្តន៍ហ្នឹង ហើយគេបាននាំយកមកដាក់ភូមិម្រោក់ ។ ភូមិម្រោក់ហ្នឹងសុទ្ធជាជនជាតិគួយទាំងអស់ ហើយគេឲ្យពួកខ្ញុំមកនៅហ្នឹង ។ ពួកខ្ញុំរស់នៅបានបីយប់ បងប្អូនទាំងប្រាំនាក់ ស្រីៗទាំងអស់គ្នា តែពេលនោះពួកយើងទាំងអស់គ្នា មិនទាន់គ្រប់ការទេ ចាស! ហើយរស់នៅដោយអត់មាន ភាពកក់ក្តៅពីអ្នកដែលគ្រប់គ្រងមើលថែពួកនាងខ្ញុំក៏បានរត់ នាំគ្នារត់នៅពេលយប់រត់មកផ្ទះវិញ ហើយពេលនោះជីដូន ជីតា ម្តាយមីងខ្ញុំ ហើយនិងឪពុកម្តាយមិត្តនារីទាំងអស់គ្នា បានទទួលកូនដោយរីករាយ ពេលដែលឃើញកូនមកវិញ ។ តែជាលើកទីពីរ ដល់លើកទីពីរហ្នឹង ពួកមូលដ្ឋានដូចបងដែន បងសែម អីហ្នឹង គាត់ជាមូលដ្ឋាននៅក្នុងភូមិហ្នឹង គាត់ធ្វើការតឹងតែងយ៉ាងខ្លាំង ។ គាត់ថា ជាលើកទីពីរ បើសិនជាមិត្តនារីឯងប៊ានត្រឡប់មកវិញទេ គេនឹង គេមិនដឹងថា យកយើងទៅណាទេ គេថាអាហ្នឹង យកទៅដាក់កន្លែងផ្សេង ។ ពេលនោះពួកនាងខ្ញុំ គេបានបញ្ជូនមកដល់សាលារីសែ ជូនដល់សាលារីសែហើយ ក៏បញ្ជូនពួកនាងខ្ញុំមកភូមិ ស្រុកជើងព្រៃ ខេត្តកំពង់ចាមហ្នឹង ។ គឺមិនមែនដោយការស្ម័គ្រចិត្តទេ គឺដោយការភ័យខ្លាចផង ។

[១០:១៤:១៤]

**ស៖** សូមអរគុណ ។ ខ្ញុំចង់ឲ្យលោកស្រី ជិន ម៉េត លើកឡើងពីអ្វីដែលគាត់បានឆ្លងកាត់នៅពេលដែលគាត់ចូលក្នុងទ័ពខ្មែរក្រហមហ្នឹង គាត់មិនមានជម្រើសរើសអ្វីទេ ។ គាត់បានចូលដោយសារខ្មែរក្រហមទៅភូមិគាត់ ហើយគេកែនគាត់ទេ ។ អ៊ីចឹងខ្ញុំចង់ ឲ្យគាត់បញ្ជាក់ចំណុចមួយទាក់ទងទៅនឹងប្រភពដំបូង ដែលគាត់ចូលរួមក្នុងកងទ័ពខ្មែរក្រហមនោះ?

**ឆ៖** ចាស, លោកស្រីមេធាវី! នៅពេលដែលនាងខ្ញុំបានចូលនៅក្នុងកងនារីពេញសិទ្ធិ ហើយឈរជើងនៅស្រុកជើងព្រៃហ្នឹង ពួកយើងគេឲ្យហាត់ ហាត់ដំបូង ហាត់លូន ហាត់ក្រាប ហាត់ក្នុងមួយថ្ងៃឲ្យចេះមួយក្បាច់ ចេះលូន ចេះក្រាបហើយ ។ បីថ្ងៃក្រោយមក គេឲ្យយើងហាត់រៀនដោះកាំភ្លើងដោះកាំភ្លើងហ្នឹង លាងកាំភ្លើងហ្នឹង ចេះដាក់ចេះដោះៗ កាំភ្លើងអាកាហើយគេឲ្យរៀនដោះមីនៗហ្នឹងពួកខ្ញុំអត់សូវចេះទេ ព្រោះខ្លាច ហើយនិងរៀនគប់គ្រាប់បែក រៀនចេះក្បាច់អស់ទាំងនោះ ចេះលាងចេះដោះ ពិសេសគឺចេះដោះនិងចេះលាងកាំភ្លើងតែម្តង ឲ្យសំខាន់បំផុត ។ ហើយមួយទៀត រៀនបាញ់កាំភ្លើងៗ បាញ់អាកា កាំភ្លើងអៀកែង កាំភ្លើងរ៉េបាដេ អាបង់ក្លាវើគីន ហ្នឹងហើយរហូតដល់ កាំភ្លើងបេ៤០ បេ៤១ បេ៤២ រហូតដល់កាំភ្លើង បេកា៧៥ ។

នៅពេលដែលរៀនចេះចប់រយៈពេលបីខែ គេឲ្យយើងហាត់ ហាត់បាញ់ ដោយប្រើសាកល្បងកម្លាំងនារីៗទាំងអស់នោះ តើនារីណាដែលមានសមត្ថភាព ។ គេមកបាញ់ គឺគេ ពួកយើងខ្ញុំអត់ដឹងថាគេមានអ្វីស្ទង់ដើម្បីបាញ់គ្រាប់ហ្នឹងទៅយ៉ាងណាទេ ខ្លាច ពួកនាងខ្ញុំចេះមានភ័យ មានការភ័យខ្លាចនូវការបាញ់ហ្នឹង បាញ់ហ្នឹងរយៈពេលមួយម៉ោង ឲ្យយើងរៀនបាញ់ ។ នាងខ្ញុំបាញ់ដំបូងកាំភ្លើង បេ៤០ បេ៤១ហ្នឹង អត់មានបញ្ហាអីទាំងអស់ តែដល់ពេលបាញ់ បេកា៧៥ហ្នឹង នាងខ្ញុំមាន ដូចថាមានការស្ទះទៅអត់រួចដូចគេផ្សេងទៀត បាញ់អស់បីគ្រាប់ ក្រដាសត្រចៀកនាងខ្ញុំបែក ហើយហូរឈាមមកបានដឹងមេកងថា នាងខ្ញុំខ្សោយ ។ ដូច្នេះ គេដកខ្ញុំនៅក្រុម ផ្សេងផ្នែកខាងដឹកជញ្ជូន អត់ឲ្យយើងទៅខាងក្រុមបាញ់ទេ គឺដឹកជញ្ជូនគ្រាប់ៗ ជញ្ជូនបាយទៅសមរភូមិ ហើយពេលដែលយុវជននៅសមរភូមិមានរបួស បាក់ជើង បាក់ដៃ ត្រូវគ្រាប់អី យើងនឹង សែងមកដាក់នៅពេទ្យជើងឆ្នុក នៅមន្ទីរពេទ្យជើងឆ្នុក ។

**ប្រធានអង្គជំនុំ៖**

វំពុកមេធាវីម្តងទៀត សំណួរសួរពាក់ព័ន្ធអង្គហេតុ អង្គហេតុដែលចោទប្រកាន់លើជនជាប់ចោទគឺអង្គហេតុពាក់ព័ន្ធជាមួយនឹងស-២១ មានមជ្ឈមណ្ឌលភ្នំពេញ ហើយនិងព្រៃស នៅក្នុងយុត្តាធិការដែលយើងសវនាការនេះ គឺចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

ដោយឡែកអង្គហេតុដែលពាក់ព័ន្ធជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺចាប់ពីថ្ងៃទី១០ ខែ១០ ឆ្នាំ៧៧ ដែលគាត់ត្រូវបានចាប់ខ្លួន បញ្ជូនទៅ ដែលគាត់អះអាងថា មិនច្បាស់លាស់ទៅកន្លែងឃុំខ្លួនដប់ប្រាំថ្ងៃ រួច ហើយបញ្ជូនទៅព្រៃស រហូតដល់គាត់បានទៅដាំបន្លែនៅស្អាង ហើយនិងថ្ងៃរំដោះ ៧មករា ឆ្នាំ ១៩៧៩។ នេះជាការរំឭកចុងក្រោយ ។

[១០:១៨:២០]

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោកប្រធាន ហើយសូមអភ័យទោស ដែលខ្ញុំសួរសំណួរនេះ ដែលអាចអនុញ្ញាត ឲ្យលោកស្រី ជិន ម៉េត បាននឹកឃើញឡើងវិញអំពីអ្វីដែលកើតឡើងក្នុងសម័យនោះ ។

**ស៖** អ៊ីចឹងទាក់ទង ទៅនឹងការឃុំខ្លួន អ៊ីចឹងគឺថាគាត់មានស្នាមនៅលើដៃ ហើយនិងកជើង តើលោកស្រី ជិន ម៉េត អាចប្រាប់យើងបាន ថាតើឧបករណ៍ទារុណកម្មអ្វីខ្លះដែលប្រើមកលើរាងកាយរបស់លោកស្រីនោះ?

**ឆ៖** ចាស, លោកស្រីមេធាវី! ឯចំណែកឧបករណ៍ដែលគេធ្វើទារុណកម្មលើរាងកាយនាងខ្ញុំហ្នឹង គឺនាងខ្ញុំមើលមិនឃើញទេ ព្រោះនាងខ្ញុំបានជម្រាបច្បាស់ខាងដើមហើយ ថានៅពេលដែលគេចាប់ គេចងភ្នែកបិទរហូត នាងខ្ញុំបានសន្និដ្ឋានក្នុងចិត្ត ថាប្រហែលជាអ្នកដែលចងខ្ញុំ បិទភ្នែកខ្ញុំមិនឲ្យឃើញហ្នឹង ប្រហែលជាអ្នកដែលនៅជាមួយខ្ញុំ ធ្លាប់ស្គាល់ខ្ញុំក៏មិនដឹង អាហ្នឹងជាការសន្និដ្ឋានរបស់ខ្ញុំទេ។ ហើយឯសម្ភារៈដែលគេធ្វើហ្នឹង ការគេធ្វើវ៉ៃ លើខ្លួនលើប្រាណហ្នឹង ខ្ញុំចាំបានថា ប្រហែលជាគល់ផ្តៅ បើសិនជាខ្សែតីវិញ វាឮ "ផ្លិចៗ" តែគល់ផ្តៅហ្នឹងវាឮតែ "ឌិបៗ" ហើយមួយទៀតមិនដឹងជាគេចាប់នឹង ដង្កាប់ ឬមួយចាប់នឹងអីទេ បានជាជើងខ្ញុំមានដំបៅស្លាក់ស្នាម ហើយអាខាងជើងម្ខាងដែលមានជាំ ស្នាមជាំហ្នឹងគេវ៉ៃ គេអត់ចាប់ទេ គឺគេវ៉ៃ មិនដឹងជាញញួរ មិនដឹងជាដំបងទេ គេវ៉ៃឡើងចង់បែកសរសៃជើង ។ មិនបានមើលឃើញថា សម្ភារៈហ្នឹងជាអ្វីខ្លះទេ ។

**ស៖** គាត់បានបញ្ជាក់ថានៅពេលដែលគាត់ទៅកន្លែងឃុំខ្លួនវិញ បន្ទាប់ពីការសួរចម្លើយរួចនោះ មិត្តម្នាក់របស់គាត់ គឺថាបានជួយគាត់ដោយប្រើក្រមា ថាតើលោកស្រីអាចបញ្ជាក់បន្ថែមបានទេ ថាមានហូរឈាម ឬក៏ម៉េច នៅពេលនោះ?

**ឆ៖** ចាស, លោកស្រីមេធាវី! នៅពេលនោះគឺមានហូរឈាម ព្រោះពេលដែលគេធ្វើទារុណកម្ម រួចហើយគេឲ្យយើងចូលក្នុងបន្ទប់ គេអត់ចង់ភ្នែកយើងទេ គឺចងភ្នែកជិតតែរយៈពេលបីថ្ងៃ តែក្រោយ

មកទៀត គឺគេស្រាយភ្នែកយើងហើយ ចូលក្នុងបន្ទប់គេស្រាយភ្នែកហើយ គេបិទទ្វារចាក់ដាក់សោរខាង ក្រោយទៅៗ អ៎!ខាងក្រៅជិតទៅ ។ ហើយពួកនាងខ្ញុំដែលនៅខាងក្នុងហ្នឹង មិត្តមឿន ហ្នឹងគាត់ឃើញជើងខ្ញុំហូរឈាម ខ្ញុំអត់បានចាប់អារម្មណ៍ទេ ភ័យខ្លាចពេក ព្រោះយើងវាតក់ស្លុត តក់ស្លុត សឹងថាវាគាំងបេះដូងចង់ស្លាប់ម្ដងៗ បើសិនជាគេកុំចងដៃអី ខ្ញុំប្រហែលជាតដៃហើយ ហើយខ្ញុំសុខចិត្តសម្លាប់ខ្លួនឯង តែពេលនោះយើងជាប់ចំណង ដល់ពេលមិត្តមឿន ថាមិត្តម៉េត ជើងមិត្តឯងហ្នឹងជ្រៅប៉ុនណាទៅ? ឈឺទេ? ហ្នឹងខ្ញុំយំផង អីផងទៅថា យើងបានអីរុំចែកឯង នាងខ្ញុំកាលដែលលីស្រូវនឹងឃ្លាំងហ្នឹងមានក្រមា ហើយខ្ញុំស្លៀកខោពីរជាន់ ព្រោះលីស្រូវខ្លាចស្មៀបហ្នឹង ខ្ញុំស្លៀកពីរជាន់ ដល់ហ្នឹងខ្ញុំមានក្រមា មិត្តមឿន បានយកក្រមាហ្នឹងហែកចងរុំជើងឲ្យនាងខ្ញុំទៅ ។

**ស៖** តើគាត់បានឃើញ តើអ្នកដែលជាប់ឃុំជាមួយលោកស្រីនោះ ត្រូវបានគេយកចេញដោយមានចងមុខដើម្បីទៅកន្លែងណាដែរឬទេ?

**ឆ៖** អ្នកដែលនៅឃុំជាមួយខ្ញុំ មានមិត្តមឿន និងមិត្តយ៉ាត បីនាក់ទាំងរូបខ្ញុំ ។ ពេលដែលសន្តិសុខគេហៅហ្នឹង គេចូលទៅគេហៅយើងមក ហើយគេចងមុខស្រេចៗដូចគ្នាម្ដង ។ ហើយគេបណ្ដើរចេញមក តែបើគេយកទៅណាទៀត យើងអត់ដឹងទេ តែអស់រយៈប្រហែលជាមិនដល់មួយម៉ោងទេ គេនាំមកវិញ ពេលនោះមិត្តយើងទាំងអស់គ្នា ។ រាងកាយរៀងទ្រុឌទ្រោម ហើយមុខ ទឹកមុខ គឺភ័យខ្លាចដូចៗគ្នា ដែលពួកខ្ញុំបានទទួលរងគ្រោះដូចគ្នា មើលទៅការធ្វើរងទារុណកម្មហ្នឹងវាតែមួយ មិនខុសគ្នាប៉ុន្មានទេ ។

**ស៖** តើលោកស្រីមានការហូរឈាមបានឃើញថា ជនរងគ្រោះនោះ មានរងការហូរឈាម ឬក៏ស្នាមរបួសអីទេ នៅពេលដែលគាត់ចេញទៅងូតទឹក ហើយត្រឡប់មកវិញនោះ?

**ឆ៖** ពេលដែល មិត្តមឿន គាត់ចេញទៅងូតទឹក ហើយគាត់ត្រឡប់មកវិញនោះ ពួកនាងខ្ញុំ មិនបានចាប់អារម្មណ៍មើលថា មានស្នាមអ្វីទាំងអស់ ព្រោះពេលនោះ គឺយើងមានអារម្មណ៍ភ័យខ្លាចតែរៀងៗខ្លួន មិនបានឃើញភាពអ្វីឲ្យខុសប្លែកទេ ព្រោះម្នាក់សុទ្ធតែអង្គុយតៀត អត់មានអង្គុយចោងហោងឬអង្គុយបង់ជំទែងអីទេ ម្នាក់សុទ្ធតែអង្គុយជើងផ្ទឹបម្ដង ។

**ស៖** គាត់បានប្រាប់ថា នៅពេលដែល នៅក្នុងពេលឃុំឃាំងលោកស្រីបានឮសម្រែកថ្ងូរយំ ថាតើលោកស្រីដឹងទេ ថាមានអ្នកផ្សេងត្រូវបានឃុំខ្លួននៅកន្លែងហ្នឹងដែរទេនៅពេលដែលឮសំឡេងហ្នឹងនោះ?

**ឆ៖** ពេលដែលនាងខ្ញុំចូលទៅដល់ហ្នឹង ឮនៅពេលយប់ ពេលយើងដេក ឮស្នូរសំឡេងស្រែកថ្ងូរ អ៊ី យើងក៏បានសួរគ្នាថា ប្រហែលជាគេចាប់អ្នកមុនៗនៅក្នុងកងរបស់យើង ប្រហែលគេយកមកធ្វើទារុណកម្មដូចគ្នាអីដឹង បានជាអ្នកខ្លះឮតែថ្ងូរ ឬតែមិនមែនយកទៅឲ្យរៀនសូត្រទេ ប្រហែលគេយកមកឃុំឃាំងយកមកដាក់គុកដូចតែគ្នាហ្នឹង ។ ពេលនោះ ពួកខ្ញុំទាំងបីហ្នឹងមានអារម្មណ៍ ហើយបានសួរគ្នាដោយខ្សឹបខ្សៀវដូចខ្ញុំនិយាយអំមិញ ថាប្រហែលជាគេយកមកដាក់គុក មិនមែនយកឲ្យរៀនសូត្រទេ ។

[១០:២៥:១០]

**ស៖** តើលោកស្រី ហើយនិងអ្នកដែលជាប់ឃុំជាមួយលោកស្រីហ្នឹង បានគិតគូថា នឹងធ្វើអត្តឃាតដែរឬទេ?

**ឆ៖** នៅពេលដែលពួកយើងនៅក្នុងបន្ទប់ទាំងបីនាក់ហ្នឹង បាននិយាយគ្នាថា បើសិនជាគេអាចស្រាយចំណងដៃយើង គេចងតែជើង ដៃយើងទាំងពីរអាចមាន មិនជាប់ចំណងទេ ពេលនោះពួក នាងខ្ញុំថា បើមានកន្លែងឯណាគួរសម ឬមួយក៏មានអ្វីមួយនៅជិតខ្លួនយើងទាំងអស់គ្នា បានរួមចិត្តរួមថ្លើមគ្នាថា យើងនឹងអាចសម្លាប់ខ្លួន ឬក៏ធ្វើឃាតជាអ្វីមួយ ។ តែនៅក្នុងបន្ទប់នោះ វាអត់មានអ្វីទាំងអស់ ទៅខាងលើវាស្មើផិញ មកសងខាង គឺស្មើទាំងអស់ ។ ដូច្នេះ ពេលនោះក្នុងចិត្តមួយ គឺថាចង់ធ្វើឃាត តែវាអត់មានឱកាស ។

**ស៖** បន្ទាប់មកទៀត ខ្ញុំចង់សួរសំណួរពីរបីទាក់ទងទៅនឹង នៅពេលដែលលោកស្រីនៅក្នុងអង្គភាព១៧នោះ គឺថាបើនរណាមិនធ្វើការល្អទេ គេនឹងរងការវាយដំ ហើយអ្នកខ្លះ គេវាយរហូតដល់ស្លាប់ តើគេប្រើឧបករណ៍អ្វី ឬដំបងអ្វីដើម្បីវាយអ្នកនោះ?

**ឆ៖** ចាស, លោកស្រីមេធាវី! នៅពេលដែលនាងខ្ញុំបានទៅនៅក្នុងកង១៧ ដែលនាងខ្ញុំបានឃើញផ្ទាល់ គឺវាមិនដល់ស្លាប់ទេ នៅពេលដែលគេប្រើឲ្យយើងអូសនង្គ័លធ្វើថ្នាលសំណាប ពេលនោះ មិត្តមឿន និងមិត្តគៀន ហ្នឹងគាត់អូសម្ខាង ខ្ញុំពីរនាក់ហ្នឹងអូសម្ខាង ។ មិត្តមឿន អ៎!មិត្តគៀន ហ្នឹងៗគាត់ឈឺ ជើងៗគាត់ហើយចេញទឹកដោយសារទឹករោល ពេលដែលយើងអូសនង្គ័លហ្នឹងបានមួយជុំពីរជុំអត់អីទេ ដល់ឡើងលើកទីបីទីបួន បងពីរនាក់ហ្នឹងគាត់បាន ដូចថា ទាញហ្នឹង ព្រាត់ម្ខាង ទាញអានឹមម្ខាងមកទៅដួលទាំងអស់គ្នាទៅ ខ្ញុំម្ខាងស្តាំហ្នឹង ដួលសង្កត់ពីលើគេទៅ ហើយពេលនោះពូដែលគាត់កាន់យាមនង្គ័លហ្នឹង គាត់បានស្ទុះ ស្ទុះទៅវ៉ៃបង គៀន ហ្នឹងតែគាត់មិនវ៉ៃខាងខ្សែតីទេ គាត់វ៉ៃខាងខាងមោងវ៉ៃខាងគល់មោង មិនដឹងជាវ៉ៃចំត្រូវត្រង់ណា បងគៀន គាត់ប្រកាច់ៗនៅញ័រជើងញ័រដៃនៅនឹងកន្លែង

ហើយពួកខ្ញុំពេលនោះឃើញ ឃើញទិដ្ឋភាពយ៉ាងដូច្នោះ យើងខ្ញុំទាំងអស់គ្នាទាំងបីនាក់ខំលត់ជង្គង់ថ្វាយបង្គំ តាហ្នឹង ដោយសុំទោសគាត់ឲ្យជួយមើលផង ជ្រុលដៃ ជ្រុលជើងហើយ ពូអើយជួយមើលគាត់ផងប្រហែលជាស្លាប់ តែគាត់អត់មានយកចិត្តទុកដាក់មើលទេ គាត់បែរជាដាក់យើងមួយមោងៗ ម្នាក់ទៀតហើយអូស បងគៀន ហ្នឹងដាក់មកភ្លីស្រែមក ។ តែត្រង់ស្លាប់ មិនស្លាប់ហ្នឹង ខ្ញុំអត់បានដឹងទេ ព្រោះគេយកគាត់ទៅកន្លែងផ្សេងទៀត ។

[១០:២៨:២៩]

**ស៖** សំណួរចុងក្រោយមុនពេលនឹងខ្ញុំឲ្យសហសេវិកខ្ញុំសួរសំណួរ លោកស្រីបានពន្យល់ខ្ញុំថាឪពុករបស់លោកស្រីទៅសាលារៀន ហើយគាត់មកកើត ស្រុកកំណើតនៅ ស្រុកកំណើតជាមួយជនជាប់ចោទ ថាតើជនជាប់ចោទអាចដឹងថា ឪពុករបស់គាត់ហ្នឹងនៅក្នុងស្រុកភូមិជាមួយគ្នាដែរឬទេ?

**ឆ៖** នាងខ្ញុំមិនដែលដឹងថា ពូឌុច ហ្នឹងគាត់ស្គាល់ឪពុកខ្ញុំអត់ទេ តែតាមការសន្និដ្ឋានរបស់នាងខ្ញុំថា ធម្មតាឪពុកខ្ញុំគាត់ធ្វើប៉ូលិស គាត់ដើរឈរគ្រប់ស្រុកទាំងអស់ក្នុងមួយខេត្តកំពង់ធំ គឺឈរគ្រប់ស្រុករហូតដល់ ពៅរើយ, ពាមបាង ជាអចិន្ត្រៃយ៍ ។ ដូច្នេះគឺ ពូឌុច គាត់នៅខាងស្រុកហ្នឹងតើគាត់អាចស្គាល់ឈ្មោះ ស៊ែប ជិនៗ នេះដែរឬទេ? នាងខ្ញុំអត់ដឹងទេ គ្រាន់តែក្នុងអារម្មណ៍ហ្នឹងថា ប្រហែល ជាអាចស្គាល់ឬមួយយ៉ាងម៉េច អត់ដឹងទេ ទាល់តែគាត់និយាយខ្លួនគាត់ ព្រោះជំនាន់មួយស្រុករគ្នា ឪពុកខ្ញុំនិងគាត់នោះ ។

**សួរដោយលោក គឹម ម៉េងឃី៖**

សូមគោរពអង្គសវនាការទាំងមូល! សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ទាំងអស់ ជម្រាបសួរលោកស្រី ជិន ម៉េត ។

**ស៖** ខ្ញុំមានសំណួរបន្តអំពីសហមេធាវីអន្តរជាតិសួរទៅលោកស្រី អំពីតើលោកស្រីអាចចាំបានទេ មុនពេលដែលមុនការចាប់ខ្លួនលោកស្រីតើលោកស្រីមានទម្ងន់ ឬក៏រូបរាងភិនភាគយ៉ាងដូចម្តេចដែរ? អាចសម្គាល់បានទេ?

**ឆ៖** មុនដែលពេលគេចាប់ខ្លួននាងខ្ញុំ ។ នាងខ្ញុំនៅឯអង្គភាពចាស់ កងពល៣១០, ៤៥០ហ្នឹងកងនារីនាងខ្ញុំហ្នឹង ហូបបាយលត់ដំដែរលាយគល់ចេកគល់ល្ហុងដែរ តែក្នុងនោះ គឺយើងហូបបានគ្រប់គ្រាន់ ។ មិនខ្វះខាតប៉ុន្មានទេនៅក្នុងអង្គភាពហ្នឹង ព្រោះតាស្នួង និងតាយ៉ាន់ ហ្នឹងគាត់យកចិត្តទុកដាក់នឹងនារីៗដែលធ្វើស្រែខ្លាំងណាស់ ។ ហើយពេលហ្នឹងគាត់ថា ទោះបីជាហូបបាយលាយគល់ចេក គល់

ល្អុងយ៉ាងម៉េចក៏ដោយ តែសុំកុំឲ្យដាំជ្រាយដាំឲ្យរឹង ហើយរាងកាយហ្នឹងរូបភាពរបស់-- រូបរាងរបស់នាងខ្ញុំក៏ដូចជានារីផ្សេងៗទៀតហ្នឹង មិនមានការស្រុតចុះទេ គឺនៅសភាពធម្មតា ។

**ស៖** តើអាចកត់សម្គាល់ថា ប្រហាក់ប្រហែល ឬក៏ជាទៅនឹងរូបថតដែលបានថតទេ គឺនៅពេលនោះ រូបថតដែលលោកស្រីបានបង្ហាញក្នុងអង្គសវនាការហ្នឹង?

**ឆ៖** គឺដូចគ្នាតែគ្រាន់តែថា នៅពេលដែលគេហៅយើងថត ធ្វើប្រវត្តិរូបហ្នឹង ទឹកមុខរបស់នាងខ្ញុំហ្នឹង គឺមានការភ័យខ្លាច ។ ដូច្នេះ ក្នុងរូបថតហ្នឹងគឺមានទឹកមុខធ្លាក់ចុះ គឺមិនរីករាយទេ ព្រោះមានការភ័យខ្លាចពេលដែលគេហៅធ្វើប្រវត្តិរូបរួចហើយ គេថតទៀត តែសាច់ឈាមហើយនិងមុខមាត់ហ្នឹងប្រហែលគ្នានឹងរូបថតហ្នឹត តែគ្រាន់តែថានាងខ្ញុំធ្លាក់ទឹកមុខបន្តិច ដោយការមានភ័យខ្លាច ដោយការភ័យខ្លាច ។

**ស៖** សូមអរគុណលោកស្រី ។ លោកស្រីអាចបញ្ជាក់បន្ថែមទៀតបានទេ ថាតើក្រៅពីគេហៅលោកស្រីទៅថតរូប ឬក៏ធ្វើប្រវត្តិរូបហ្នឹង ប្រហែលជារយៈពេលប៉ុន្មានរហូតដល់ថ្ងៃដែលគេចាប់លោកស្រីបញ្ជូនមកឃុំឃាំងនោះ?

**ឆ៖** នៅពេលដែលគេហៅយើងធ្វើប្រវត្តិរូបហ្នឹង គឺបងយ៉ាន់ បានហៅខ្ញុំធ្វើប្រវត្តិរូបនោះនៅក្នុងខែ០៦ ខែ០៧ ក្នុងពីរខែហ្នឹង គាត់ហៅជាញឹកញាប់ មកធ្វើប្រវត្តិរូបហើយថត ។ ហើយខ្ញុំក៏បានសួរថា អ៊ូ! បង យ៉ាន់ បងឯងក៏ថតផង ធ្វើប្រវត្តិរូបផងញឹកញាប់ម្ល៉េះ បើថាចាប់ខ្លួនចាប់ឲ្យហើយទៅកុំឲ្យពិបាកពេក ខ្ញុំក៏បាននិយាយថា អ៊ីចេះទៀត ។ នៅក្នុងខែ០៦ ខែ០៧ ឆ្នាំ១៩៧៧ ។

[១០:៣២:៥៦]

**ស៖** សូមអរគុណ ។ កាលពីម្សិលមិញ លោកស្រី ហើយក៏ដូចថ្ងៃនេះ លោកស្រីបាននិយាយដដែលៗជម្រាបលោកប្រធានផង ហើយនិងសហព្រះរាជអាជ្ញា ក៏ដូចជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផងដែរ ថាលោកស្រីបាន-- ហើយនិងមិត្តភក្តិរបស់លោកស្រី តែងតែប៉ុនប៉ងធ្វើអត្តឃាតម្តងហើយម្តងទៀត តែងតែមានគំនិតថាចង់ស្លាប់ ។ តើអារម្មណ៍ពេលនោះលោកស្រីចាត់ទុកថា ជីវិតរបស់ខ្លួនលែងរស់ ឬក៏អារម្មណ៍លោកស្រីយ៉ាងម៉េច នៅពេលដែលស្ថិតនៅក្នុងស្ថានភាពបែបនោះ?

**ឆ៖** កាលដែលនាងខ្ញុំទាំងបីនាក់រស់នៅជាមួយគ្នាហ្នឹង គឺតាំងពីនៅក្នុងសមរភូមិរហូតដល់មកយើងនៅគីឡូលេខ៦ លេខ៧ រហូតដល់យើងជាប់គុកទៀត គឺទឹកចិត្តតែមួយដូចគ្នាពេលដែលបានរងគ្រោះដូចគ្នាហ្នឹងមានចិត្តតែមួយថានឹងចង់ធ្វើឃាតសម្លាប់ខ្លួនឯង ដោយមិនចង់រស់នៅ ព្រោះជីវិតតស៊ូ

តាំងពីចេះបាញ់កាំភ្លើងវាយខ្មាំងរហូតដល់រំដោះ សមតែថាបានរស់នៅដោយសុខស្រួលជួបជុំឪពុកម្តាយ តែផ្ទុយទៅវិញបែរជាទៅជាអ្នកទោសវិញ ។ ដូច្នេះ យើងទាំងអស់គ្នាមានចិត្តដូចគ្នាចង់សម្លាប់ខ្លួន ។ តែក្រោយដែលគេបញ្ជូននាងខ្ញុំទៅនៅព្រៃស បានបីថ្ងៃបាត់មិត្តមឿន និងមិត្តយ៉ាត រយៈពីរយប់បីថ្ងៃបាត់មិត្តមឿន និងមិត្តយ៉ាត ទៅនាងខ្ញុំមានអារម្មណ៍មួយថា មិត្តពីរនាក់ហ្នឹងប្រហែលជាគេយកទៅសម្លាប់ឬមួយយ៉ាងម៉េច ព្រោះសួរមេកងគេថា យកទៅរៀនសូត្រតែនាងខ្ញុំក៏បាននឹកក្នុងចិត្តថា ប្រហែលជាគេយកទៅសម្លាប់ចោលហើយ ។

ដូច្នេះ ជីវិតទាំងបីហ្នឹងនៅសល់តែមួយនាងខ្ញុំ នៅតែម្នាក់ឯងគត់ ។ ដល់ក្រោយមកទៀត ដូចនាងខ្ញុំបានលើកពីម្សិលហើយថា នាងខ្ញុំឮគេថាសំបកកន្ទួតហ្នឹងពូកែណាស់ផឹកទៅនឹងស្លាប់មួយរំពេច។ រួចហើយនាងខ្ញុំក៏បានយកសំបកកន្ទួតហ្នឹងនៅវត្តហា ហ្នឹងយកមកត្រាំពេលដែលគេឲ្យយើងទៅជំរះស្មៅដំឡូងនោះ យកមកត្រាំផឹក តែពេលដែលផឹកទៅវាមិនស្លាប់វាទៅជាមានកម្លាំងវិញ ។ ដូច្នេះ មានបងស្រីមួយហ្នឹងគាត់ថា មិត្តម៉េត ឯងកុំឆ្កួតពេក ជីវិតមនុស្សម្នាក់ៗមិនងាយរកបានទេ គឺជីវិតយើងជាជីវិតម្នាក់ៗ គឺជាការតស៊ូរបស់យើង ។ ដូច្នេះ យើងកុំគិតខ្លីពេក ត្រូវតែចង់រស់ទៅមុខទៀតដើម្បីអនាគតរបស់យើង ។ ក្រោយមកទៀត មកបាននាងខ្ញុំមានចិត្តថា បើសិនជាយើងស្លាប់ក៏វាអត់ន័យដែរ បើស្លាប់ដោយមិនមានមូលហេតុ ក៏វាល្អមើលដែរ ។ តែបើស្លាប់ដោយសារសម្លាប់ខ្លួនឯង ធ្វើឃាតខ្លួនឯងអាហ្នឹងតាមដែលចាស់ៗនិយាយនៅក្នុងកងនារី ដូចកង បងភី ដែលខ្ញុំគាត់ គាត់ថាបើអ្នកណាសម្លាប់ខ្លួនឯងព្រះមិនអាចប្រោសបាន ។

[១០:៣៥:៤៣]

ពេលនោះបានខ្ញុំនឹកឃើញថា លែងចង់ស្លាប់ហើយ ទោះបីគេប្រើទីណាត់ទីណែងយ៉ាងណា ក៏នាងខ្ញុំតាំងចិត្តថា ធ្វើទៅមិនរួចអង្គុយអត់ធ្វើតែម្តង ទោះគេវ៉ៃយ៉ាងម៉េចក៏ដោយ ។ ពេលដែលនាងខ្ញុំមានកម្លាំងបាននាងខ្ញុំធ្វើបន្តទៀត ។

**លោក គីម ម៉េងឃី៖**

សូមអរគុណ នូវការបំភ្លឺរបស់លោកស្រី ដោយសារពេលវេលាមានកំណត់ខ្ញុំសូមជម្រាបជូនលោកស្រីបន្តិច នៅក្នុងអង្គសវនាការនេះ ក៏ដូចជាលើកមុនដែរ លោកស្រីអាចលើកសំណូមពររបស់លោកស្រីជូនទៅតុលាការ នៅពេលដែលបញ្ចប់ការតាំងសំណួររបស់យើងខ្ញុំ ។ ហើយលោកស្រីអាចបញ្ជាក់អំពីសំណូមពរដែលលោកស្រីចង់បាន ។ ហើយលោកស្រីអាចសួរសំណួរ អំពីទុក្ខសោករបស់

លោកស្រីផ្ទាល់ទៅកាន់លោក កាំង ហ្គេកអ៊ាវ ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅមន្ទីរស-២១ នេះបាន ។

ហើយជាចុងក្រោយនេះគឺខ្ញុំសូមអនុញ្ញាតលោកប្រធាន មេត្តាឲ្យខ្ញុំសួរសំណួរខ្លះទៅកាន់ជនជាប់ចោទលោក កាំង ហ្គេកអ៊ាវ អំពីករណីមួយចំនួនដែលលោកបានលើកឡើង ។ បើសិនជា លោកប្រធានអនុញ្ញាត ខ្ញុំនឹងរៀបរាប់សំណួរខ្ញុំជូនលោក កាំង ហ្គេកអ៊ាវ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ ។ លោក កាំង ហ្គេកអ៊ាវ ចាំស្តាប់សំណួរ ហើយនិងឆ្លើយតបនឹងសំណួររបស់មេធាវី អ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។

**លោក គឹម ម៉េងឃី៖**

មុននឹងសួរសំណួលោកប្រធាន តើការសួរសំណួររបស់ខ្ញុំវាអាចប៉ះពាល់ទៅដល់ការតាំងសំណួររបស់មេធាវី ឬក៏ម៉ោងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀតដែរឬទេ? បើសិនក្នុងការឆ្លើយតបទៅនឹងការតាំងសំណួររបស់ខ្ញុំជូនលោក កាំង ហ្គេកអ៊ាវ ។ សូមបញ្ជាក់ ។

[១០:៣៧:៤៨]

**ប្រធានអង្គជំនុំ៖**

ការសួរដេញដោលនេះ ចំណាយនៅក្នុងម៉ោងដែលបានចែកឲ្យ ។

**សួរដោយលោក គឹម ម៉េងឃី៖**

សូមអរគុណ លោកប្រធាន ។ ជម្រាបសួរអង្គសវនាការទាំងមូល ។

**ស៖** លោក កាំង ហ្គេកអ៊ាវ លោកក្នុងការឆ្លើយបំភ្លឺរបស់លោកទៅសំណួររបស់ក្រុមយើងខ្ញុំកាលពីសវនាការលើកមុន ពាក់ព័ន្ធទៅនឹងសំណួរដែលសួរថា ការកាត់ក្បាលដោយមិនមានការថតរូបហើយលោកបានមានប្រសាសន៍ថា ជម្រាបអង្គសវនាការថា ការថតរូបនោះគឺ ដើម្បីជាការសក្ខីភាពនៃបញ្ជាក់ថា មនុស្សហ្នឹងត្រូវបានសម្លាប់ហើយ ដើម្បីយកទៅជូនថ្នាក់លើ ។ ហេតុដូច្នេះ សំណួររបស់ខ្ញុំសួរទៅកាន់លោក សួរថាតើរូបថតរបស់លោកស្រី ជិន ម៉េត ដែលបានដាក់តាំងនៅលើ*តាប្លូ*របស់មន្ទីរស-២១ ទួលស្លែងហ្នឹង ជាសក្ខីកម្មដែលលោកបង្ហាញថានេះជាការដែលខ្មាំង ដែលត្រូវបានកម្ទេចរួចហើយឬក៏មែនទេ? បន្តទៅទៀត ខ្ញុំមានសំណួរមួយទៀត បន្តទៀតគឺថា ដើមបណ្តឹងរដ្ឋប្បវេណី គាត់បានលើកហើយអំពីឪពុករបស់គាត់ឈ្មោះស៊ែប ជិន ។ អ៊ីចឹងតើលោកស្គាល់ ស៊ែបជិន ហ្នឹងទេ? ហើយ

លោកអាចបង្ហាញបានពន្យល់ប្រាប់យើងខ្ញុំបានទេ ថាមូលហេតុអ្វីបានជាមានអ្នកដែលឃុំខ្លួន ដែលដូចជាករណីលោកស្រី ជិន ម៉េត ដែលមានស្រុកកំណើតរបស់គាត់នៅជាមួយក្នុងស្រុកកំណើតរបស់លោកផ្ទាល់ដែរត្រូវបានបញ្ជូនទៅព្រៃស ទៅធ្វើទាសករនៅទីនោះ ។

បន្តមកទៀត លោកបានជម្រាបប្រាប់អង្គសវនាការថា ចំពោះការសួរចម្លើយទៅលើមិត្តនារីនៅមន្ទីរស-២១ គឺមានតែអ្នកសួរចម្លើយស្រីទេ ក្រោយពីមានការរំលោភសេពសន្ថវៈ ។ តើលោកការបញ្ចូលឈើទៅក្នុង (សុំទោស) គឺការបញ្ចូលឈើទៅក្នុងប្រដាប់ភេទរបស់អ្នកគ្រូម្នាក់របស់លោក? ហើយតើលោកនៅតែប្រកាន់គោលជំហរបែបនេះថា មានតែអ្នកសួរស្រីនៅសម្រាប់សួរអ្នកទោសស្រីនៅទីនោះអ៊ីចឹងទៀតដែរឬទេ?

សំណួរបន្តទៅទៀត --

**ប្រធានអង្គជំនុំ៖**

លោកគិតថាសួរបៀបនេះ តើជនជាប់ចោទអាចចាំសំណួរលោក ហើយឆ្លើយតបនឹងលោកបានដែរទេ? ប្រសិនបើគេសួរលោកវិញ តើលោកគិតថាចាំដែរទេ? ឥឡូវនេះ ជនជាប់ចោទឆ្លើយនឹងសំណួរគាត់សិន ។ ហើយបើសំណួរណាមិនចាំ ជនជាប់ចោទអាចឲ្យគាត់សួរសាជាថ្មីម្ដងទៀត ហើយសំណួរសេសសល់គឺចាំឆ្លើយក្រោយ ។ ចាំសួរក្រោយ ហើយសឹមឆ្លើយ ។ បើសំណួរដំបូង បើសិនជាលោកមិនចាំ លោកអាចសួរម្ដងទៀត ដើម្បីឲ្យគាត់សួរលោកសាជាថ្មី ហើយនិងលោកឆ្លើយតប ។ បើលោកចាំ លោកអាចឆ្លើយតបបាននាពេលនេះ ។

[១០:៤១:៣១]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកមេធាវី! ទីមួយ រឿងថតរូប ។ ថតរូបនេះ គឺថតតាមបញ្ជារបស់ខាងលើដោយចំពោះ បានន័យថា បុគ្គលណាដែលខាងលើចង់ដឹង គឺយើងខ្ញុំថតជូន ។ ទីពីរ ពីរឿងកាត់ក្បាល ។ ខ្ញុំទើបនឹងឃើញឯកសារហ្នឹងទេ មិនដឹងប្រភពយ៉ាងម៉េចទេ ខ្ញុំនៅតែរក្សាបញ្ហានេះ ។ ទីបីរឿងលោក ជិន ស្អី ជិន អ៊ីចេះភ្លេចទៅហើយ ខឹម ជិន គាត់អញ្ជើញទៅនៅស្ទោងពីអង្កាល់ ខ្ញុំអត់ដឹងទេ ។ ខ្ញុំសូមបញ្ជាក់ជូនថា ខ្ញុំចេញមករៀន មកនៅកំពង់ធំមួយឆ្នាំទៅផ្ទះតែបីខែទេ តាំងពីឆ្នាំ១៩៥៨ ហើយក្រោយមកក៏លែងបានទៅផ្ទះរហូតទៅ ។ ខ្ញុំគ្រាន់តែចាំថា រវាងឆ្នាំ១៩៦៤ ប៉ូលិសដែលទៅនៅស្ទោង ហើយ ជាពិសេសតាមស្រុកគ្រប់ស្រុក មានសក្តិ២ សក្តិមួយ គេហៅថា *អាំងស្ពេចទ័រ* ប៉ូលិស

នោះទៅកាន់កាប់កិច្ចការនៅតាមស្រុក ខ្ញុំអត់ស្គាល់ទេ ។ អង្កាល់ដែលខ្ញុំនៅស្ទោងនៅឡើយមានដោយបីជាន់នៅកាន់កាន់ឈ្មោះលោកតាស៊ែប គុង ។ ដូច្នេះ ខ្ញុំអត់ស្គាល់មិត្តម៉េត ខ្ញុំអត់ស្គាល់លោក ជិន ទេ ។ ហ្នឹងជម្រាបដោយត្រង់ ខ្ញុំអត់ស្គាល់ទេ ។ នេះខ្ញុំឆ្លើយបានតែសំណួរបីហ្នឹងទេ ។ សំណួរពីរទៀត សូមលោកសួរម្តងមួយម្តងៗ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមានពេលបីមីនុតទៀត មិនមែនបីមីនុតសម្រាប់សួរទេ ទាំងឆ្លើយផង បើសួរហើយអស់ម៉ោងមិនឲ្យឆ្លើយទេ ។

**លោក គីម ម៉េងឃី៖**

សូមអរគុណលោកប្រធាន ។ ដូច្នេះ ខ្ញុំសួរសំណួរមួយជាចុងក្រោយសំខាន់នៅក្នុងនាមឲ្យដើមបណ្តឹងរដ្ឋប្បវេណីរបស់រូបខ្ញុំ រូបយើងខ្ញុំក្រុមបីនេះ គឺសំណួរកាន់លោក កាំង ហ្គេកអ៊ាវ លោកបានមានប្រសាសន៍ថា នៅក្នុងករណីណាក៏ដោយ លោកទទួលខុសត្រូវចំពោះផ្លូវចិត្តរបស់ជនរងគ្រោះ ឬក៏អ្នករស់រានមានជីវិតទាំងអស់ ។ តើលោកអាចពន្យល់ ឬក៏ជម្រាបប្រាប់លោកស្រី ជិន ម៉េត នៅពេលនេះបានទេ ថាតើលោកទទួលខុសត្រូវផ្លូវចិត្តនោះ មានន័យយ៉ាងណាដែរ? សូមអរគុណ ។

[១០:៤៤:១៨]

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកមេធាវី! ចំពោះករណី មិត្តម៉េត ខ្ញុំអត់ទទួលខុសត្រូវខាងផ្លូវចិត្តទេ ខ្ញុំទទួលខុសត្រូវពេញមុខ ចំពោះឧក្រិដ្ឋកម្មនេះតាមផ្លូវច្បាប់ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណោះ ។ សូមចប់ ។

**ប្រធានអង្គជំនុំ៖**

ខាងដើមបណ្តឹងរដ្ឋប្បវេណីអស់ម៉ោងហើយ សម្រាប់សួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ តែដោយដល់ពេលម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំពីរនាទី ឈប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញដើម្បីបន្តដំណើរការសវនាការ ។

ហើយមន្ត្រីតុលាការសម្របសម្រួល រកកន្លែងសមរម្យសម្រាប់ឲ្យលោកស្រី ជិន ម៉េត បានសម្រាកស្រួលបួល ។

*[សវនាការសម្រាកពីម៉ោង ១០:៤៦នាទី ដល់ម៉ោង ១១:០៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការនីតិវិធីសវនាការដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ជិន ម៉េត។ ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅមេធាវីការពារក្តីប្រសិនបើ មានសំណួរសួរពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ។ សូមអញ្ជើញ។

មានអីទៀតហើយនុ៎ង?

**លោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមនៃអង្គជំនុំជម្រះ។ តាងនាមឲ្យដើមបណ្តឹងរដ្ឋប្បវេណី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី ហើយនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមផ្សេងទៀត យើងខ្ញុំមានសំណើពាក់ព័ន្ធទៅនឹងការបែងចែកពេលវេលានេះ ។ កាលពីអង្គសវនាការមុនៗលោកប្រធានបានបញ្ជាក់ប្រាប់ខាងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីរួចហើយថា ការគិតនៃរយៈពេលនៃការតាំងសំណួរទៅកាន់ជនជាប់ចោទ ហើយនិងសាក្សីហ្នឹងគឺមិនរាប់បញ្ចូលនៅក្នុងពេលវេលាដែលត្រូវចំណាយសម្រាប់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានសួរទេ ។ ហើយដូច្នេះ គឺខ្ញុំគិតទៅប្រហែលថាសល់ពេលប្រាំនាទី សម្រាប់ក្រុមផ្សេងទៀតនៅក្នុងការតាំងសំណួរនេះ ។ ដូច្នេះ សុំឲ្យលោកប្រធានមេត្តាអនុញ្ញាតឲ្យមេធាវីផ្សេងទៀតមានរយៈពេលប្រាំនាទី ព្រោះដោយគិតថា លោកស្រី ជិន ម៉េត គាត់ចំណាយពេលនៅក្នុងការឆ្លើយសំណួរបីនាទី ទៅហើយ ហើយជនជាប់ចោទ គាត់ចំណាយពេលនៅក្នុងការឆ្លើយសំណួររបស់ក្រុមខ្ញុំបាទនោះក៏មានរយៈពេលច្រើននាទីដែរ ដែលធ្វើឲ្យប៉ះពាល់ដល់ម៉ោងរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត ។ ហេតុដូច្នេះ ខ្ញុំសូមស្នើសុំលោកប្រធានអនុញ្ញាតឲ្យក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតប្រាំនាទី ដើម្បីការតាំងសំណួរ។ បាទ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតទេ ។ សូមប្រគល់វេទិកានេះទៅមេធាវីការពារក្តី សូម បើសិនជាមានសំណួរអាចបន្តសួរ អាចសួរដល់ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី ។

[១១:០៨:២០]

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

*(មេធាវីហ្សាកកាំង ប៉ុនប៉ងនិយាយ)*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយមិនអនុញ្ញាតទេ។ សូមអង្គុយចុះមេធាវី ។

អង្គជំនុំជម្រះមិនអនុញ្ញាតទេ អស់ម៉ោងហើយ ។ សូមអញ្ជើញមេធាវីការពារក្តី ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមគោរពលោកប្រធាន សូមគោរពលោកចៅក្រមជាតិ និង អន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល ។

**ស៖** លោកស្រី ជិន ម៉េត នៅក្នុងពាក្យបណ្តឹងរបស់លោកស្រី ដែលលោកស្រីបានអះអាងថា លោកស្រីសរសេរដោយផ្ទាល់ដៃ លោកស្រីបាននិយាយថា គេបញ្ច្រកទឹកត្រី បញ្ច្រកទឹកសាប៊ូ ទៅលើលោកស្រី ។ តែនៅពេលនិយាយប្រាប់ លោកប្រធានពីម្សិលមិញនេះ លោកស្រីថា គេបានជះទឹកសាប៊ូ ទឹកត្រីតែប៉ុណ្ណោះ ដោយលោកស្រីបានបញ្ជាក់ជូនលោកប្រធានថា លិឍទៅប្រែៗ ហើយផុំទឹកសាប៊ូ ប៉ុន្តែបញ្ហានេះសូមលោកស្រីមេត្តាជ្រាបថា បញ្ច្រកទឹកសាប៊ូ ទឹកត្រីចូលមាត់ វាខុសគ្នាពីជះ អាជះនេះ វាស្រាលជាង អាបញ្ច្រកនេះវាធ្ងន់ណាស់ ។ អ៊ីចឹងហេតុអីបានជាក្នុងពាក្យបណ្តឹងរបស់លោកស្រីថា បញ្ច្រក ដល់ពេលលោកស្រីជម្រាបលោកប្រធានថា គ្រាន់តែជះទេ ។ អាការខុសគ្នាហ្នឹងមកពីហេតុអី? សូមលោកស្រីបញ្ជាក់ប្រាប់សូមអរគុណ ។

**ឆ៖** សូមជម្រាបលោកមេធាវី! ចំពោះរូបនាងខ្ញុំ គឺគេបានជះដាក់ តែបើមិត្តមឿន និងមិត្តយ៉ាត គាត់និយាយមកគាត់ថា គាត់គេចាប់បញ្ច្រកតែម្តង ។ ដូច្នេះ ពាក្យហ្នឹងខ្ញុំបានដាក់ហ្នឹង ខ្ញុំអះអាងថាមិត្តខ្ញុំទាំងបីហ្នឹងវាខុសគ្នា ។ ដូច្នេះ អ្នកទាំងបីហ្នឹងមានគេបញ្ច្រក និងមានគេជះទឹកដាក់ ។ សូមជ្រាប ។

**ស៖** ពាក្យបណ្តឹងនេះគឺពាក្យបណ្តឹងតែលោកស្រីម្នាក់ឯងគត់ ដែលគេថាលោកស្រីបានសរសេរដោយផ្ទាល់ដៃ គេបានបញ្ច្រកទឹកត្រី បញ្ច្រកទឹកសាប៊ូ ទៅលើលោកស្រី។ លោកស្រីមិនថាគេបញ្ច្រកទៅលើមិត្តនារីពីរនាក់នោះទេ ។ សំណួរទីពីរ នៅក្នុងពាក្យបណ្តឹងរបស់លោកស្រីដដែល លោកស្រីអះអាងថា បានសរសេរដោយផ្ទាល់ដៃលោកស្រីដដែលសរសេរថា គេបានឆក់ខ្សែភ្លើងថែមទៀតផង ដល់ពេលលោកប្រធានសួរម្សិលមិញនេះ លោកស្រីថាអត់មានឆក់ខ្សែភ្លើងទេ ។ អ៊ីចឹងហេតុអីបានជាខុសគ្នាអ៊ីចឹង? សូមលោកស្រីបញ្ជាក់ឲ្យបានច្បាស់ ។

**ឆ៖** នៅក្នុងកន្លែងមន្ទីរឃុំឃាំងហ្នឹង គេអត់បានឆក់ខ្សែភ្លើងខ្ញុំទេ តែនៅក្នុងអង្គភាពរបស់ខ្ញុំគឺគេឆក់ គេបានឆក់នាងខ្ញុំនៅពេលដែលគេសួរខ្ញុំធ្វើប្រវត្តិរូប ព្រោះ បងយ៉ាន់ គាត់បាននាំខ្ញុំទៅសួរផ្ទាល់ ។

តែនៅ ក្នុងមន្ទីរឃុំឃាំងគេអត់ឆក់ទេ គេគ្រាន់តែវាយដំ ហើយនិងជះទឹកសាប៊ូ ទឹកត្រីដាក់លើរាងកាយនាងខ្ញុំ ហើយនិងធ្វើទារុណកម្មដំហើយនិងចាប់ មិនដឹងចាប់នឹងស្អីទេបានជាខ្ញុំដាច់សរសៃជើងហើយចេញឈាម ។

**ស៖** សូមអរគុណ ។ អ៊ីចឹងនៅព្រៃសគេអត់បានឆក់ខ្សែភ្លើងលោកស្រីទេ គេឆក់ខ្សែភ្លើងនៅឯអង្គភាពលោកស្រីទេ អ៊ីចឹងហ្អេ?

**ឆ៖** ចាស។

**ស៖** សូមអរគុណ ។

[១១:១៣:៣១]

**ឆ៖** ចាស, លោកមេធាវី។ នៅឯកងព្រៃសហ្នឹង អត់មានឆក់ទេ គឺនៅអង្គភាពចាស់ ។

**ស៖** សូមអរគុណ។ សូមលោកស្រីបញ្ជាក់ថែមទៀត។ នៅកន្លែងដាំបន្លែនៅស្អាង ដែលលោកស្រីបានដាំបន្លែនៅនុ៎ង អ៊ីចឹងសូមលោកស្រីបញ្ជាក់មើល តើលោកស្រីសម្គាល់លើស្អីដែលថា កន្លែងដាំបន្លែនោះជាស្អាង ?

**ឆ៖** នាងខ្ញុំសម្គាល់កន្លែងហ្នឹងគឺមានកោះមួយ ហើយនៅក្បែរហ្នឹងមានស្ទឹងជាប់នឹងកន្លែងដាំបន្លែហ្នឹងនៅជុំវិញហ្នឹងមានដើមស្វាយធំៗ ហើយមានរោងតូចៗគេសម្រាប់រស់នៅដាំបន្លែហ្នឹងសម្រាប់អ្នកដែលស្នាក់នៅទីនោះ។ ហើយមានគេបណ្ដុះគ្រាប់ល្ពៅ គ្រាប់ត្រឡាច ហើយមានដាំបន្លែគ្រប់មុខតែម្ដង ។ ពេលដែលយើងបង្កបង្កើតបាន ពេលប្រមូលផលមានឡានហ្នឹងចូលមកដឹកយកទៅឲ្យតាមកងនោះ ។ ទីតាំងរបស់ខ្ញុំគឺ គេហៅថា ស្រុកស្អាង ។

**ស៖** សូមអរគុណ ខ្ញុំចង់ដឹងតែប៉ុណ្ណឹងទេ ។ ឥឡូវ ខ្ញុំសួរកន្លែងហ្នឹងតទៅទៀត ។ ដល់ពេលលោកស្រីដាំបន្លែដល់ពេលវៀតណាមចូលមកលោកស្រីរត់មិនអ៊ីចឹង? ដល់ពេលរត់ទៅ លោកស្រីរត់ទៅជាមួយអ្នកណាខ្លះនៅដាំបន្លែ? ហើយតើក្នុងនោះមានពួកព្រៃស ឬស-២១ ទៅជាមួយឬក៏អត់?

**ឆ៖** ចាស, នៅពេលដែលរត់ចេញពីកន្លែងដាំបន្លែងហ្នឹង ពួកយើងបានរត់ទៅជាមួយគ្នា តែដល់ពេលរថក្រោះយួនរត់ដេញតាមពីក្រោយច្រើនពេកទៅ មានតាំងពីអ្នករោងចក្រកែវ កម្មករផ្សេងៗទៀតខាង--

**ស៖** សូមៗអរគុណ ខ្ញុំចង់បានតែប៉ុណ្ណឹងទេ ថារត់ទៅទាំងអស់គ្នា ។ ទាំងអស់គ្នាហ្នឹងអ្នកណាខ្លះ មិនចង់បានចំនួនទេ ចង់ដឹងថាអ្នកណាខ្លះ សមាសភាពដែលរត់ជាមួយគ្នាហ្នឹង ។

**ឆ៖** សមាសភាពដែររត់ជាមួយគ្នាហ្នឹងនៅក្នុងក្រុមខ្ញុំ ដែលដាំបន្លែមានប្រាំនាក់ គឺបងឡេង បងខែម ហើយពីរនាក់ទៀតខ្ញុំអត់បានស្គាល់ទេ ប្រាំនាក់ទាំងរូបខ្ញុំ គឺទៅជាមួយគ្នា ។ តែទៅដល់កំពង់ត្រឡាច គេបានបែកគ្នាអស់ហើយ ។

**ស៖** អ៊ីចឹង អត់រត់ទៅជាមួយពួកព្រៃស ទេ?

**ឆ៖** អត់មានរត់ទៅទេ ពួកព្រៃស ដឹងគេនៅទៅខាងណា នាងខ្ញុំអត់បានជួបទេ តែគ្រាន់តែទៅមានគ្នាច្រើន ។

**ស៖** សូមអរគុណ ។ មួយសំណួរទៀត ពេលគេចាប់លោកស្រីពីអង្គភាពរបស់លោកស្រីមក លោកស្រីសន្និដ្ឋានថា ចូលស-២១ ដប់ប្រាំថ្ងៃ ដប់ប្រាំយប់ ។ អ៊ីចឹងកន្លែងហ្នឹង កន្លែងដែលលោកស្រីថា ស-២១ ហ្នឹងលោកស្រីមានឆ្ងល់ទេ ហេតុអ្វីក្នុងបន្ទប់នោះមានតែឈ្មោះ មឿន និង យ៉ាត ដែលជាមិត្តរបស់លោកស្រីដែលធ្លាប់ស្គាល់គ្នានោះ? អត់មានឃើញអ្នកដទៃទៀតទេ មួយស្រុកខ្មែរអត់មានចូលទៅក្នុងនុ៎ងទេ អង្គភាពដទៃទៀតអត់មានចូលទៅក្នុងនុ៎ងទេ វាឃើញតែអង្គភាពរបស់លោកស្រីមានតែគ្នាបីនាក់ ។ អ៊ីចឹងលោកស្រីមានឆ្ងល់ទេ កន្លែងហ្នឹង?

**ឆ៖** ចាស, លោកមេធាវី ខ្ញុំបានជម្រាបខាងដើមហើយថា ការដែលគេចាប់នាងខ្ញុំហ្នឹង នាងខ្ញុំមិនបានស្គាល់ថាមន្ទីរឃុំឃាំងហ្នឹងជាព្រៃស ជាទួលស្លែង ជាស-២១ទេ តែនាងខ្ញុំបានចូលកន្លែងឃុំឃាំងជាប់គុកមែន តែខ្ញុំអត់ដឹងថាគុកហ្នឹងជាគុកស-២១ ឬជាគុកទួលស្លែងទេ ។ ដូចខ្ញុំជម្រាបលោកប្រធានខាងដើមហើយ ។

**ស៖** សូមអរគុណ ដែលខ្ញុំសួរបញ្ជាក់លោកស្រីហ្នឹង ពីព្រោះខ្លាចលោកស្រីច្រឡំៗអាគុកនៅអង្គភាព និងស-២១ នោះ ក្រែងលោកស្រីច្រឡំ ពីព្រោះលោកស្រីទៅជាប់ក្នុងនុ៎ង វាមានតែអង្គភាពរបស់លោកស្រីគ្នាបីនាក់ ។ បើនៅព្រៃស វាមានមួយគគោកមួយដី វាឃើញគេឃើញឯងក្រៅពីអង្គភាពរបស់លោកស្រី ។ អាហ្នឹងវាអាចអ៊ីចឹង ដែលខ្ញុំសួរហ្នឹង ចង់ដឹងត្រង់ហ្នឹងទេ ។

សូមអរគុណលោកចៅក្រម ខ្ញុំអស់សំណួរ ។

[១១:១៧:៥៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**សួរដោយលោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

**ស៖** លោកស្រីបានបញ្ជាក់ថា នៅពេលនោះលោកស្រីមិនដឹងថាលោកស្រីនៅទួលស្លែងនោះទេ
ប៉ុន្តែនៅពេលថ្មីៗ លោកស្រីទៅលេងទួលស្លែងជាមួយនឹងអ្នកតំណាងមកពីអង្គការមជ្ឈមណ្ឌលឯកសារ
កម្ពុជា ។ តើលោកស្រីអាចរកឃើញនិងពិនិត្យមើលទៅលើបន្ទប់ដែលគេឃុំខ្លួនលោកស្រី និងធ្វើទារុណ-
កម្មលោកស្រីនៅពេលនោះដែរឬទេ នៅពេលទៅលេងទួលស្លែងនោះ?

**ឆ៖** ចាស, លោកស្រីមេធាវី ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

មេធាវីខ្ញុំសុំជំទាស់ទៅលើសំណួរនេះ គឺមិនមែនមជ្ឈមណ្ឌលឯកសារកម្ពុជាទេ គឺមជ្ឈមណ្ឌល
អភិវឌ្ឍកម្ពុជា ។ ដូច្នេះហើយខ្ញុំស្នើសុំឲ្យមេធាវីការពារក្ដីធ្វើការតាំងសំណួរឲ្យបានត្រឹមត្រូវទៅកាន់ដើម
បណ្ដឹងរដ្ឋប្បវេណី ។

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្ដីតាំងសំណួរសាជាថ្មីឲ្យបានត្រឹមត្រូវ ។

**សួរដោយលោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

**ស៖** ប្រហែលជាខ្ញុំបញ្ជាក់ខុសទៅលើចំណុចនេះ ។ ខ្ញុំអត់ដឹងថាជាបញ្ហានៃការបកប្រែ ឬក៏
យ៉ាងម៉េច? ប៉ុន្តែសំណួររបស់ខ្ញុំ ខ្ញុំដឹងថា ខ្ញុំសួរច្បាស់ណាស់ ។ លោកស្រីបានបញ្ជាក់ថាលោកស្រីមិន
បានដឹងថា លោកស្រីនៅទួលស្លែងទេ កាលពីលោកស្រីនៅជាប់ឃុំនោះ ។ ប៉ុន្តែ ថ្មីៗនេះនៅពេលដែល
លោកស្រីត្រឡប់ទៅទួលស្លែងវិញជាមួយនឹងអ្នកតំណាងមកពីអង្គការមួយ ។ ថាតើលោកស្រីអាចពិនិត្យ
និងមើលឃើញបន្ទប់ដែលលោកស្រីជាប់ឃុំដែរឬទេ? ហើយលោកស្រីអាចពិនិត្យនិងរកឃើញស្គាល់
បន្ទប់ដែលគេធ្លាប់ធ្វើទារុណកម្មលោកស្រីដែរឬទេ?

[១១:២០:០៧]

**ឆ៖** ចាស, លោកស្រីមេធាវី! នៅពេលដែលនាងខ្ញុំបានទៅចូលនៅកន្លែងមន្ទីរឃុំ អ៊ំកន្លែងដាក់
តាំងរូបថតនៅក្នុងទួលស្លែងហ្នឹង នាងខ្ញុំមិនអាចមើលដឹង មើលស្គាល់ថាកន្លែងដែលនាងខ្ញុំជាប់ឃុំឃាំង
ហ្នឹងទីនោះ ឬទីណាទេ ។ ព្រោះពេលដែលយើងគេចាប់ឃុំឃាំងហ្នឹង គេមិនដែលបើកភ្នែកយើងទេ គឺ
ចងភ្នែកជាប់រហូត ។ ដូច្នេះ បានជានាងខ្ញុំមិនអាចសម្គាល់ថា អ្វីជាកន្លែងដែលនាងខ្ញុំរស់នៅជាប់ឃុំ
ហើយសួរចម្លើយកន្លែងណា ព្រោះមើលមិនឃើញ ។

**ស៖** ដូច្នេះ តើយើងអាចនិយាយបានទេថា សមាសធាតុ ឬចំណុចទាំងឡាយដែរអាចឲ្យនាំលោកស្រីថា លោកស្រីជាប់នៅឃុំទួលស្លែងនោះ គឺមានតែរូបថតទេ ដែលនាំឲ្យលោកស្រីគិតថាលោកស្រីជាប់នៅទួលស្លែង?

**ឆ៖** ចាស, ពេលដែលឃើញរូបថត រូបនាងខ្ញុំ ក៏ដូចជារូបថតមិត្តនារីនៅក្នុងអង្គភាពហ្នឹង នាងខ្ញុំមិនបានគិតថាខ្ញុំហ្នឹងបានចូលក្នុងទួលស្លែងទេ តែនាងខ្ញុំគិតថា ប្រហែលជាបងៗនៅក្នុងអង្គភាពនាងខ្ញុំពិសេស គឺប្រធានកង ប្រធានវរៈរបស់នាងខ្ញុំហ្នឹងប្រហែលនៅក្នុងទួលស្លែងហើយ ព្រោះកន្លែងហ្នឹងជាគុកធំជាងគេនៅក្នុងស្រុកខ្មែរ ។ ដូច្នេះ បាននាងខ្ញុំដាក់ក្នុងពាក្យបណ្តឹងហ្នឹងថា "បងៗទាំងបួននាក់ហ្នឹងពិតជាបានស្លាប់នៅក្នុងទួលស្លែងមែន" ព្រោះបាត់រហូតទាល់តឡូវបច្ចុប្បន្នអត់ឃើញអ្នកណាទៅស្រុកសោះ ។

**ស៖** ប្រសិនបើខ្ញុំយល់ចម្លើយរបស់លោកស្រីនោះ ទោះបីជាលោកស្រីមើលឃើញរូបថតលោកស្រីថ្មីៗនេះនៅទួលស្លែងក៏ដោយ ការឃើញរូបថតនោះ គឺមិនអាចនាំឲ្យលោកស្រីជឿថា លោកស្រីត្រូវបានគេឃុំខ្លួននៅទួលស្លែងនោះទេ ។

**ឆ៖** ចាស, ខ្ញុំបានជម្រាបហើយថា ខ្ញុំមិនបានសន្និដ្ឋានថា ខ្លួនខ្ញុំនៅក្នុងគុកទួលស្លែងទេ តែគ្រាន់ថា ខ្ញុំបាននៅក្នុងមន្ទីរឃុំឃាំង តែខ្ញុំអត់ស្គាល់ថាទួលស្លែង ឬជាស-២១ ទេ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណី គាត់បានបញ្ជាក់ហើយ គាត់មិនបានដឹងថាគាត់នៅទួលស្លែង ឬក៏យ៉ាងម៉េចនោះ ។ ដូច្នេះ ខ្ញុំមិនមានសំណួរក្នុងការតាំងសួរដើមបណ្តឹងរដ្ឋប្បវេណីនេះទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ការ សាវុត្ថ ។

[១១:២៣:១៥]

**សួរដោយលោក ការ សាវុត្ថ៖**

**ស៖** សូមគោរពលោកប្រធាន ដោយខ្ញុំបានស្តាប់ចម្លើយរបស់លោកស្រី លោកស្រីថាលោកស្រីនៅក្នុងរយៈពេលដប់ប្រាំថ្ងៃ ដែលឆ្លើយទៅនឹងមេធាវីអន្តរជាតិអំមិញនេះ លោកស្រីអត់បានមើលអីឃើញទេ ដោយសារគេចងមុខលោកស្រីជិត ។

អ៊ីចឹងជានាំឲ្យខ្ញុំឆ្ងល់តទៅទៀត ថាបើគេចងមុខជិតអ្នកចូលហ្នឹងគេចងជិត ពេលលោកស្រីដាច់ជើង បើគេចងមុខជិត ម៉េចក៏ម្នាក់ទៀតនោះដឹងថាលោកស្រីហូរឈាម? បើចងមុខហើយ ហើយបើចងមុខជិតហើយ ម្ដេចក៏ម្នាក់នោះទៅយកស្ព៊ីក្រម៉ាអីណាទៅហែកចងកើត បើវាមើលអីមិនឃើញផងចងមុខជិតហើយ ។ ដូច្នេះ សូមឲ្យលោកស្រីបញ្ជាក់អាទិដ្ឋភាពហ្នឹងឡើងវិញមើលវាយ៉ាងម៉េច?

**ឆ៖** ចាស, មេធាវី ខ្ញុំជម្រាប! នៅពេលដែលគេធ្វើទារុណកម្មយើង គេចងមុខមែន តែពេលដែលសន្តិសុខយកពួកខ្ញុំមកដាក់ក្នុងបន្ទប់ គេអត់ចងមុខទេ គេចងមុខតែមុនពេលបីថ្ងៃ ។ ក្រោយពីបីថ្ងៃមកទៀតគេស្រាយមុខយើងរហូតពេលដែលធ្វើទារុណកម្មរួច គេស្រាយមុខយើង រុញចូលក្នុងបន្ទប់ហើយអត់មានចង់មុខទេ ។

**សៈ** សូមអរគុណលោកស្រី តែអម្បាញ់មិញនេះលោកស្រីបានឆ្លើយទៅលោកមេធាវីអន្តរជាតិនេះថា គេចងមុខលោកស្រីជិត លោកស្រីអត់បានដឹងអីទេ អត់មើលឃើញអីទេ បានជាខ្ញុំឆ្ងល់ហ្នឹង ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកស្រី ជិន ម៉េត អង្គជំនុំជម្រះក៏បានយល់ដែលថា លោកស្រីមានការលំបាកណាស់ក្នុងការដែរប្រឈមនឹងការឆ្លើយនឹងសំណួរជាច្រើនពីអង្គជំនុំជម្រះនិងភាគី ។ ហើយរឿងហេតុកើតឡើងយូរមកហើយ ហើយជាពិសេស គឺលោកស្រីបានឆ្លងកាត់នូវការលំបាកវេទនាដែលនាំឲ្យមានការរំភើបចិត្ត នៅពេលដែលរំឭកឡើងវិញពីអំពើទាំងឡាយដែលប៉ះពាល់មកលើលោកស្រី លោកស្រីឆ្លងកាត់នៅក្នុងរបបបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃនោះ ។ ហើយករណីខ្លះអង្គជំនុំជម្រះបានស្ដាប់ទៅ ប្រវត្តិលោកស្រីមានការកម្សត់តាំងពីមុនមក មុនឆ្នាំ១៩៧០ ទៅទៀត ដោយសារជាកំព្រា ហើយរស់នៅតែជាមួយជីដូនជីតានោះ ។

[១១:២៥:៣៩]

ហើយទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោកស្រីបានប្រឹងប្រែងហើយបានឆ្លើយយ៉ាងច្បាស់លាស់គ្រប់សព្វជូនដល់អង្គជំនុំជម្រះ ។ ហើយអង្គជំនុំជម្រះ គឺអស់សំណួរដែលត្រូវមានការពាក់ព័ន្ធជាមួយនឹងលោកស្រីទៀតហើយ គឺលោកស្រីអាចអញ្ជើញត្រឡប់ទៅលំនៅដ្ឋានវិញបានហើយ ។

មន្ត្រីតុលាការសម្របសម្រួលជូនលោកស្រីទៅសហការជាមួយនឹងខាងអង្គភាពគាំពារជនរងគ្រោះ

ដើម្បីបានជូនគាត់ត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ ហើយឲ្យអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី E2-32 ចូលមកបន្ទប់សវនាការដើម្បីបន្តកិច្ចពិភាក្សាដេញដោល ។

**លោកស្រី ស៊ីលយីស្វូត ហ្សីនស្តី៖**

លោកប្រធាន ខ្ញុំសុំដាក់ជាយោបល់បឋមទាក់ទងទៅនឹងដើមបណ្តឹងរដ្ឋប្បវេណី E2/80 ។ ខ្ញុំមានការព្រួយបារម្ភបន្តិច ដោយសារតែស្ត្រីរូបនេះ គឺហើយដើមបណ្តឹងរូបនេះចាកចេញពីបន្ទប់ព្រឹកមិញ។ ដូច្នេះហើយ គឺខ្ញុំសូមលើកឡើងថា ខ្ញុំសូមនិយាយជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ដោយសារតែគាត់មានអារម្មណ៍មួយដែលថាមិនស្រួល មានអារម្មណ៍មួយដែលធូរស្រាលចំពោះសតិអារម្មណ៍របស់គាត់ ។ ដូច្នេះហើយគឺខ្ញុំសូមធ្វើការកត់សម្គាល់ខ្លីតូចមួយជាបឋម ដែលលើកឡើងតែប្រាំនាទីតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ចង់និយាយថាម៉េច ចង់លោកស្រីនិយាយមុន មុនពេលអញ្ជើញគាត់ចូលមកសាលសវនាការ? មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បញ្ជាក់សាជាថ្មី និយាយឲ្យបានច្បាស់មើល វាយ៉ាងម៉េច ឆ្លងកាត់ការបកប្រែផង ។ ប្រធានអង្គជំនុំជម្រះស្តាប់មិនយល់អំពីប៉ុនប៉ងរបស់លោកស្រីទេ ។ លោកស្រីនិយាយឲ្យច្បាស់ ហើយសាមញ្ញបានហើយ តែនិយាយជ្រៅពេក គឺប្រធានអង្គជំនុំជម្រះស្តាប់មិនយល់ទេ ។

[១១:២៨:២៧]

**លោកស្រី ស៊ីលយីស្វូត ហ្សីនស្តី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមធ្វើការលើកជាយោបល់បឋមទាក់ទងទៅនឹងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី E2/80 ។ ហើយខ្ញុំនឹងមិនចំណាយពេលលើសពីប្រាំនាទីទេ ក្នុងការលើកជាយោបល់បឋមរបស់ខ្ញុំនៅពេលនេះ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

តើលោកស្រីកំពុងនិយាយពីដើមបណ្តឹងរដ្ឋប្បវេណី E2/80 ឬ32 ។

**លោកស្រី ស៊ីលយីស្វូត ហ្សីនស្តី៖**

ខ្ញុំសូមអភ័យទោស គឺខ្ញុំនិយាយអំពីដើមបណ្តឹងរដ្ឋប្បវេណី E2/32 ។

សូមអភ័យទោស ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោកស្រី ស៊ីលយ៉ស្វត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។ នៅក្នុងថ្ងៃនេះដើម-- កូនក្តីរបស់ខ្ញុំ គឺនៅទីនេះដើម្បីផ្តល់ និងលាតត្រដាងជាដំបូងអំពីរឿងរ៉ាវរបស់គាត់ដែលវាមានរឿងរ៉ាវហួសពីអ្វីដែលនៅក្នុងលើកឡើងនៅក្នុងចម្លើយរបស់គាត់ ។ គឺគាត់បានលើកឡើង ហើយបានចាប់ផ្តើមរៀបរាប់អំពីរឿងរ៉ាវទាំងឡាយរបស់គាត់ ។ គាត់មិនដែលបានលើកឡើងរឿងនេះពីមុនទេ លើកលែងតែ ទើបតែនិយាយថ្មីជាមួយនឹងមេធាវីរបស់ខ្លួន។ រឿងរ៉ាវរបស់ស្ត្រីរូបនេះក្នុងចំណោមរឿងរ៉ាវដទៃៗទៀត គឺវាទាក់ទងទៅនឹងអង្គហេតុ ។ ជាបឋមគឺគាត់បានលើកឡើងអំពីទំនាក់ទំនងផ្ទាល់របស់គាត់ជាមួយនឹងពូ ឬខ្សែស្រឡាយខ្មែរក្រហមដែលយើងដែលមានឈ្មោះ ហ៊ឹម គឺជាលេខាកងពល ៣១០ ។

ទីពីរ គាត់នឹងនិយាយអំពីអង្គហេតុ ដែលគាត់ជាពេទ្យ ហើយបន្ទាប់មកគាត់ធ្វើការនៅទួលស្លែងជាពេទ្យ ។ ទីបី សាក្សីរូបនេះ នឹងចូលមកផ្តល់នេះ នឹងនិយាយអំពីអង្គហេតុទាក់ទងទៅនឹងការរបស់គាត់នៅទួលស្លែង ។ ទីបួន គាត់នឹងនិយាយអំពីជនជាប់ចោទ ហើយគាត់នឹងលើកឡើងអំពីការសង្កេតរបស់គាត់ថា តើជនជាប់ចោទ ទាំងផ្លូវចិត្ត ទាំងនិងផ្លូវកាយពាក់ព័ន្ធទៅនឹងការប្រព្រឹត្តយ៉ាងម៉េច? ដែលបានប្រព្រឹត្តឡើងទៅលើបងប្អូនរបស់គាត់ពីរនាក់នៅទួលស្លែង ។ កូនក្តីរបស់ខ្ញុំ ដូច្នេះ គាត់មានភាពរីករាយ ហើយមានភាពស្មារតី ដែលថា គាត់នឹងពិបាកក្នុងការលើកឡើងនៅក្នុងសវនាការរបស់យើង ។ ប៉ុន្តែយ៉ាងណាក៏ដោយ គាត់នឹងមកផ្តល់សក្ខីកម្មពេញលេញរបស់គាត់ ដោយសារតែគាត់នៅពេលនេះគាត់មិនមានការភ័យខ្លាចនោះទេ នូវអ្វីដែលគាត់ចង់និយាយនៅពេលដែលគាត់បានដាក់ពាក្យ ឬក៏បានរៀបរាប់នៅក្នុងពាក្យសុំរបស់គាត់ ដែលពាក្យសុំទាំងអស់នោះ គឺលោក លោកស្រីចៅក្រម និងភាគីបានដឹងថា យើងបានបញ្ចូលទៅក្នុងសំណុំរឿងនោះហើយ ។

ដូច្នេះ យើងរំពឹងថាកូនក្តីនេះនឹងនៅពេលមួយចំនួនគាត់នឹងមានអារម្មណ៍រំជើបរំជួល ហើយគាត់មានភាពលំបាកលំបិននៅក្នុងការបន្តផ្តល់សក្ខីកម្ម ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យអង្គជំនុំជម្រះធ្វើការពិចារណាទៅលើលក្ខណៈស្ថានភាពពិសេសមួយចំនួនដែលថា គ្រួសាររបស់គាត់នឹងស្តាប់នូវអ្វីទាំងអស់នេះ និងរឿងរ៉ាវរបស់គាត់ជាលើកដំបូង ។

ដូច្នេះ ខ្ញុំសូមអនុញ្ញាតអង្គសវនាការ ប្រសិនបើមានករណីទាក់ទងនឹងគាត់កើតឡើង គឺគាត់ត្រូវ

ការពេលវេលាសម្រួលអារម្មណ៍ ហើយឲ្យគាត់សម្រួលអារម្មណ៍ ដោយមិនចាំបាច់ប្រកាស ឬក៏ណែនាំគាត់ឲ្យគ្រប់គ្រងទៅលើអារម្មណ៍របស់គាត់ក្នុងការបន្តការផ្តល់សក្ខីកម្ម ឬក៏មិនបន្ត ។ ដោយសារតែសក្ខីកម្មទាំងអស់នេះជាភស្តុតាង ហើយយើងនឹងយកមកពិចារណា ។ ហើយយើងពេលខ្លះត្រូវការរង់ចាំទៅលើស្ថានភាព ដែលថាដើមបណ្តឹងរដ្ឋប្បវេណី គាត់អាចសម្រួលអារម្មណ៍ ដើម្បីស្តាប់សក្ខីកម្ម ដូចដែលលោកប្រធានធ្លាប់ដឹកនាំសវនាការ ដូចដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សីមុនៗ ។

[១១:៣៤:១២]

ទាំងអស់នេះ គឺជាសេចក្តីលើកឡើងរបស់ខ្ញុំ ហើយខ្ញុំបានបញ្ជាក់ជូនលោក លោកស្រីចៅក្រម ហើយ អំពីអង្គហេតុដែលកូនក្តីរបស់ខ្ញុំ គាត់នឹងមកផ្តល់សក្ខីកម្ម ។ អង្គហេតុទាំងអស់នេះ មិនជាអង្គហេតុទាំងអស់នោះទេ គ្រាន់តែជាអង្គហេតុសង្ខេបមួយចំនួនដែលខ្ញុំលើកឡើង ដែលថា យើងទាំងអស់ និងអង្គសវនាការ ភាគី និងសាធារណៈ នឹងស្តាប់សក្ខីកម្មរបស់កូនក្តីរបស់ខ្ញុំ ។ ទាំងអស់នេះគឺជាសេចក្តីសង្កេតរបស់ខ្ញុំ ។ សូមអរគុណច្រើន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកស្រីចៅក្រម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន សូមអរគុណលោកស្រី ស្ទួតហ្វ្រីនស្តី ដែលបានគូសបញ្ជាក់ទៅលើចំណុចទាំងអស់នេះ ហើយបានធ្វើការពន្យល់ ដែលថា លោកស្រីបានធ្វើការពិភាក្សា ឬក៏និយាយជាមួយគាត់អំពីសក្ខីកម្ម ដែលគាត់ផ្តល់ឲ្យ ។ ហើយលោកស្រីយល់អំពីស្ថានភាពរបស់កូនក្តីរបស់លោកស្រី ។

លោកស្រីអាចជម្រាបទេ ថាតើនៅពេលណា ដែលលោកស្រីជួបជាមួយនឹងសាក្សី E2/32 នេះ ក៏សមាជិករបស់លោកស្រីហ្នឹងជួយនឹងកូនក្តីនេះ? នៅពេលណាដើម្បីជួយគាត់ទៅលើ-- ហើយស្វែងយល់អំពីអារម្មណ៍ ហើយជួយគាត់បំពេញទៅលើពាក្យសុំទាំងអស់នេះ?

**លោកស្រី ស៊ីលឃី ស្ទួតហ្វ្រីនស្តី៖**

គឺវាយូរហើយយើងបានជួបគាត់ ខ្ញុំអត់ចាំ ខ្ញុំមិនចាំកាលបរិច្ឆេទថ្ងៃខែឆ្នាំនោះទេ ដែលខ្ញុំបានពិភាក្សាជាដំបូងទៅលើរឿងរ៉ាវរបស់កូនក្តីរបស់ខ្ញុំ ។ ប៉ុន្តែ គឺបញ្ហានេះ គឺខ្ញុំបានដឹងនាពេលថ្មីៗ មុនពេលដែលសវនាការនឹងស្តាប់សក្ខីកម្មគាត់នេះ ប្រហែលជាដប់ថ្ងៃមុន ។

ដូច្នេះហើយទើបខ្ញុំស្នើសុំពេលវេលាបន្ថែមចំពោះដើមបណ្តឹងរដ្ឋប្បវេណីមួយនេះ ។ ដូច្នេះហើយ

គឺខ្ញុំដឹងប្រហែលជាដប់ថ្ងៃមុនតែប៉ុណ្ណោះ ។ ហើយតាំងពីមុនមក គាត់ហាក់ដូចជាមិនដែលបានបញ្ជាក់ទៅលើចំណុចនេះទេ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

តើមេធាវីអាចបញ្ជាក់ដែរឬទេ ថានេះជាកូនក្ដីនៅក្នុងក្រុមរបស់លោកស្រី ដែលថាគាត់នឹង គឺជាសាក្សីដើមបណ្ដឹងរដ្ឋប្បវេណីមួយដែលសំខាន់? ថានេះជាសំណើរបស់លោកស្រី ឬក៏យ៉ាងម៉េច?

[១១:៣៧:១៦]

**លោកស្រី ស៊ីលឃី ស្ទូតហ្វ៊ីនស្ដី៖**

វាជាការពិត ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ខ្ញុំចង់សួរសំណួរមួយទៀត បើសិនដូច្នោះ ។ នៅពេលដែលលោកស្រីដាក់ថាជាសាក្សី លោកស្រីមិនបានមើលឲ្យបានដិតដល់ទៅលើពាក្យសុំ ឬក៏ចម្លើយផ្សេងៗនោះទេ ដូចដែលលោកស្រីទើបតែបានមើលឲ្យបានជាក់លាក់ និងដិតដល់ក្នុងពេលថ្មីៗតែប៉ុណ្ណោះ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្វ៊ីនស្ដី៖**

ខ្ញុំបានពិភាក្សាជាមួយគាត់ ប៉ុន្តែនៅពេលនោះគាត់មិនបានបញ្ជាក់ឲ្យខ្ញុំដឹង ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ដូច្នេះ លោកស្រីបានជួបជាមួយនឹងកូនក្ដីពីរ ឬក៏បីដង មែនទេ?

**លោកស្រី ស៊ីលឃីស្ទូត ហ្វ៊ីនស្ដី៖**

គឺយើងពិភាក្សាពីរដង ម្ដងយូរហើយ ហើយថ្មីៗនេះប្រហែលជាខ្ញុំពិភាក្សាដប់ថ្ងៃមុន ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ដើម្បីជាផលប្រយោជន៍ទៅដល់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី វាអាចឲ្យយើងដឹងថា-- ឲ្យអង្គសវនាការដឹងប៉ុន្មានអាទិត្យមុន ប្រសិនបើមានការវិភាគវាយតម្លៃទៅលើសាក្សី ថាតើសាក្សីនោះ គឺគាត់អាចតាមផ្លូវអារម្មណ៍ ឬផ្លូវការរបស់គាត់អាចមកផ្ដល់សក្ខីកម្មក្នុងតុលាការដែរឬទេ? យើងគួរតែដឹងឲ្យបានមុន ហើយគួរតែសូមយោបល់ថា តើយើងគួរតែធ្វើយ៉ាងម៉េច ឲ្យបានសមរម្យទៅដល់សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី? ហើយការដែលលើកឡើងទៅលើចំណុចនេះ គឺដាក់ដូចជាយើងមិនទាន់បានទទួលព័ត៌មានពីមុន ។ ដូច្នេះ ហើយយើងជាចៅក្រម ដែលមានបទពិសោធន៍ យើងគួរតែទទួលបាននូវ

យោបល់ ឬក៏ព័ត៌មានទៅលើបញ្ហាទាំងអស់នេះជាមុន ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ណាំ ម៉ុន ចូលមកកាន់បន្ទប់សវនាការ ។

អញ្ជើញ ។

[១១:៤០:១៨]

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

លោកប្រធាន សូមលោកប្រធានអនុញ្ញាតឱ្យខ្ញុំសួរសំណួរមួយ ។ តើលោកប្រធានអាចសួរមេធាវីដើមបណ្តឹងរដ្ឋប្បវេណីមានឯកសារ ដែលខុសពីឯកសារទាំងអស់នេះទេ ឬក៏មានឯកសារផ្សេងណាទៀត ចង់ដាក់នៅពេលដែលយើងដេញដោលទៅលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ?

**ប្រធានអង្គជំនុំ៖**

មេធាវី ស្ទូតហ្សីនស្គី តើមានឯកសារអ្វីចង់ដាក់ដែរទេ? បើតាមយើងស្តាប់មក គឺមិនមានការដាក់ទេ គ្រាន់តែជាការបង្ហាញនូវអង្គហេតុផ្សេងៗទៀតក្រៅពីខ្លឹមសារដែលបានសរសេរនៅក្នុងពាក្យបណ្តឹង ដោយដើមបណ្តឹងរដ្ឋប្បវេណីចំពោះមេធាវីតែប៉ុណ្ណោះ ។

តើមានឯកសារអ្វីទេ? តាមធម្មតាឯកសារភាគីជាអ្នកស្នើសុំដាក់ ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

សូមអរគុណលោកប្រធាន មិនមានឯកសារអ្វីបន្ថែមទេ ហើយខ្ញុំនឹងមានតែឯកសារដែលមានស្រាប់រហូតមកដល់ពេលនេះ មិនមានឯកសារលាយលក្ខណ៍អក្សរអ្វីទេ ។ គឺថាអាចនឹងដំណាក់កាលចុងក្រោយ អាចនឹងមានឯកសារអ្វីទៀត ប៉ុន្តែដល់ពេលនេះ គឺយើងមិនមានឯកសារអ្វីលាយលក្ខណ៍អក្សរបន្ថែមទេ ។ សូមអរគុណ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកស្រីឈ្មោះ ណាំ ម៉ុន អ៊ីចឹង មែនដែរឬទេ?

**ឆ៖** ចាស, មែន ខ្ញុំឈ្មោះ ណាំ ម៉ុន ។

**ស៖** ក្រៅពីឈ្មោះ ណាំ ម៉ុន តើលោកស្រីប្រើឈ្មោះអ្វីផ្សេងទេ ក្រៅពីឈ្មោះ ម៉ុន? តើមានឈ្មោះអ្វីធ្លាប់ប្រើកន្លងមកដែរឬទេ?

**ឆ៖** ក្រៅពីឈ្មោះ ណាំ ម៉ុន រួច ខ្ញុំឈ្មោះ រឿន ចន្ថា ។

**ស៖** លោកស្រីប្រើពាក្យ-- ប្រើឈ្មោះ រឿន ចន្ថា ហ្នឹងនៅអំឡុងពេលណា?

**ឆ៖** ខ្ញុំប្រើឈ្មោះ រឿន ចន្ថា នេះនៅក្នុងអំឡុងពេលឆ្នាំ៧៥ ។

[១១:៤៣:០៩]

**ស៖** ចុះឈ្មោះ ណាំ ម៉ុន លោកស្រីប្រើនៅពេលណា?

**ឆ៖** ខ្ញុំប្រើឈ្មោះ ណាំ ម៉ុន នេះ ខ្ញុំប្រើនៅជាមួយឪពុកម្ដាយខ្ញុំ ។ តទៅទៀត ខ្ញុំបានមកនៅរួមរស់នៅជាមួយឪពុកម្ដាយខ្ញុំ នៅឯទីក្រុងភ្នំពេញនេះ គឺខ្ញុំដំបូង ខ្ញុំឈ្មោះ ណាំ ម៉ុន បន្តបន្ទាប់ ខ្ញុំឈ្មោះ រឿន ចន្ថា ។

**ស៖** ហើយចុះសព្វថ្ងៃ លោកស្រីប្រើឈ្មោះផ្លូវការនៅមូលដ្ឋានភូមិ ឃុំ របស់លោកស្រីរស់នៅហ្នឹង ប្រើឈ្មោះ រឿន ចន្ថា ឬក៏ប្រើឈ្មោះ ណាំ ម៉ុន ?

**ឆ៖** ខ្ញុំប្រើឈ្មោះ ណាំ ម៉ុន សព្វថ្ងៃ ។

**ស៖** ក្រៅពីឈ្មោះ ណាំ ម៉ុន និងឈ្មោះ-- ឈ្មោះ ម៉ុន និងឈ្មោះ ចន្ថា ហ្នឹង តើលោកស្រីមានប្រើឈ្មោះអ្វីផ្សេងទៀតដែរឬទេ?

**ឆ៖** អត់មានទេ មានតែឈ្មោះពីរហ្នឹងទេ ។

**ស៖** លោកស្រីដល់ឆ្នាំនេះ លោកស្រីមានអាយុប៉ុន្មានឆ្នាំហើយ?

**ឆ៖** មកដល់ពេលឆ្នាំនេះខ្ញុំបានអាយុ៤៨ឆ្នាំ ។

**ស៖** លោកស្រីមានទីលំនៅសព្វថ្ងៃនៅឯណា? ហើយប្រកបមុខរបររកស៊ីអ្វីដែរ?

**ឆ៖** សព្វថ្ងៃខ្ញុំនៅភូមិខ្យា ស្រុកកំពង់សៀម កំពង់ចាម ។ ខ្ញុំប្រកបរបររកស៊ីកសិករ ធ្វើស្រែ ។

**ស៖** ទីកន្លែងកំណើតរបស់លោកស្រីនៅទីកន្លែងណា?

**ឆ៖** ទីកន្លែងកំណើតតាំងពេលខ្ញុំកើតជាមក គឺខ្ញុំនៅភូមិរមាស ស្រុកកំពង់សៀម ខេត្តកំពង់ចាមដូចគ្នា ។

**ស៖** ឪពុកបង្កើតរបស់លោកស្រីគាត់ឈ្មោះអ្វីដែរ?

**ឆ៖** ឪពុកខ្ញុំបច្ចុប្បន្នមុន គឺគាត់ឈ្មោះ យ៉ន មកដល់ពេលជំនាន់នៅក្នុងទីក្រុងភ្នំពេញ ដែលគាត់នៅទីក្រុងភ្នំពេញជាមួយយើងខ្ញុំគាត់ឈ្មោះ ប្រាក់ ។

**ស៖** ឈ្មោះអី យ៉ន ទៅ មានត្រកូលអីទៅត្រកូល?

**ឆ៖** ត្រកូលពុកខ្ញុំកាលគាត់ចុះនៅក្នុងគុកទួលស្លែងនេះ គឺគាត់ ចួន យ៉ន ។

**ស៖** ចុះពេលដែលគាត់នៅភ្នំពេញ ហើយគាត់ដាក់ឈ្មោះ ប្រាក់ ហ្នឹង គាត់ប្រើត្រកូលអ្វីដែរ?

**ផ៖** គាត់ប្រើត្រកូល យិត យ៉ន-- យិត ប្រាក់ ។

**ស៖** យិត ប្រាក់ អ៊ីចឹងទេ? លោកស្រីដឹងថាគាត់កើតនៅឆ្នាំណាដែរទេ ឆ្នាំកំណើតរបស់គាត់របស់ឪពុកលោកស្រី?

**ផ៖** គឺខ្ញុំអត់បានដឹងទេ ។

**ស៖** ចុះម្ដាយរបស់លោកស្រីវិញ គាត់ឈ្មោះអ្វីដែរ?

**ផ៖** ម្ដាយខ្ញុំបច្ចុប្បន្ននៅក្នុងទីស្ថានរបស់គាត់ គាត់ឈ្មោះ តោក ដល់ពេលមកនៅទីក្រុងភ្នំពេញគាត់ឈ្មោះ សាន ។

**ស៖** គាត់មានត្រកូលអ្វីដែរ? ត្រកូលដែលគាត់ធ្លាប់ប្រើ ម្ដាយៗរបស់លោកស្រី?

**ផ៖** គាត់មានត្រកូល ឃិន តោក ដល់បច្ចុប្បន្ន ឃិន សាន ។

**ស៖** ម្ដងទៀត ឃិន សុះ អ៊ីចឹង? ឥឡូវម្ដាយឈ្មោះអី ឈ្មោះតែម្ដាយបានហើយ ។

**ផ៖** ម្ដាយខ្ញុំឈ្មោះ តោក ។

**ស៖** ឈ្មោះតុស?

[១១:៤៨:១២]

**ស៖** ឆ្នាំកំណើតរបស់គាត់លោកស្រីដឹងដែរទេ ម្ដាយកតើឆ្នាំណា?

**ផ៖** គឺខ្ញុំអត់បានដឹងផង ។

**ស៖** លោកស្រីមានបងប្អូនបង្កើតប៉ុន្មាននាក់? ប្រុសប៉ុន្មានស្រីប៉ុន្មាន?

**ផ៖** យើងខ្ញុំមានបងប្អូនប្រាំនាក់ ប្រុសបួន ស្រីមួយទាំងខ្ញុំនេះ ។

**ស៖** លោកស្រីជាកូនទៅប៉ុន្មាននៅក្នុងគ្រួសាររបស់លោកស្រី?

**ផ៖** យើងខ្ញុំជាកូនទីបី ។

**ស៖** លោកស្រីអាចរៀបរាប់អំពីឈ្មោះរបស់បងប្អូនលោកស្រី ដល់អង្គសវនាការបានស្គាល់នាពេលនេះដែរឬទេ? រាប់តាមលំដាប់បងគេ ហើយរហូតដល់ទៅកូន-- ប្អូនពៅគេបង្អស់ ។

**ផ៖** រាប់បានលោកតុលាការ បងខ្ញុំឈ្មោះ រឿន បន្ទាប់មកឈ្មោះ នឿន បន្ទាប់មកឈ្មោះ ឃឿន បន្ទាប់មកយើងខ្ញុំនេះតែម្ដង ហើយប្អូនពៅគេឈ្មោះ យ៉ុន ។

**ស៖** អំមិញលោកស្រីបាននិយាយថា បងប្អូនហ្នឹងមានគ្នាប្រាំនាក់ ដល់ពេលរាប់ទៅ លោកស្រីថា ទីបីគឺរឿន, នឿន, យឿន ។ យឿនហ្នឹងមួយទៀតណា? អ៊ីចឹងយឿនហ្នឹងទីបី ហើយបន្ទាប់មកបានលោកស្រីទីបួន ឬក៏ទីបី? អ៊ីចឹងលោកស្រីទីបួនមែនទេ? បងរបស់លោកស្រីទាំងបីនាក់ហ្នឹង គាត់ប្រើត្រកូលអ្វីដែរ? ត្រកូល នាមត្រកូលរបស់គាត់ ។

**ឆ៖** បងប្រុសខ្ញុំទាំងអស់ ទាំងបីហ្នឹងគាត់ប្រើត្រកូលយៀត ។ យៀត នឿន, យៀត រឿន, យៀត យឿន ។

**ស៖** ចុះប្អូនរបស់លោកស្រីពៅគេបង្អស់ហ្នឹងគាត់ប្រើត្រកូលអ្វីដែរ?

**ឆ៖** ប្អូនពៅរបស់ខ្ញុំគាត់ប្រើត្រកូល ប្រាក់ យ៉ុន ។

**ស៖** អង្គជំនុំជម្រះបានទទួលនូវពាក្យបណ្តឹងរបស់លោកស្រី បានប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំណួរនាពេលនេះសួរថា តើលោកស្រីប្តឹងទាមទារនូវសំណងរដ្ឋប្បវេណីដោយខ្លួនឯងផ្ទាល់ ឬក៏លោកស្រីទុកការប្តឹងទាមទារសំណងនេះទៅមេធាវីអ្នកតំណាងលោកស្រី នៅក្នុងការប្តឹងទាមទារជំនួសលោកស្រី?

**ឆ៖** ខ្ញុំប្តឹងយកជាសំណងនេះគឺ ទុកប្រគល់ភារកិច្ចនេះឲ្យលោកមេធាវីរបស់ខ្ញុំ ។

[១១:៥២:៣៥]

**ស៖** អំពីស្ថានភាពព្យសនកម្ម គឺស្ថានភាពដែលប៉ះពាល់ទៅលើរូបរាងកាយ ឬក៏ផ្លូវចិត្តរបស់លោកស្រី នៅដល់បច្ចុប្បន្ននេះយ៉ាងម៉េចដែរ? ផ្នែកខាងរាងកាយ ហើយបន្ទាប់មកគឺខាងផ្លូវស្មារតី ខាងផ្លូវចិត្តនេះ តើយ៉ាងម៉េចដែរ?

**ឆ៖** រាងកាយ និងផ្លូវចិត្តរបស់ខ្ញុំ ខ្ញុំនៅគិតខំប្រឹងប្រែងដើម្បីរកយុត្តធម៌ជូនពុកម៉ែខ្ញុំទាំងអស់ ។

**ស៖** ការដែលលោកស្រីសម្រេចដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ តើលោកស្រីមានទំនាក់ទំនងយ៉ាងដូចម្តេចទៅនឹងអង្គហេតុដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ?

**ឆ៖** ខ្ញុំមកដាប់ពាក្យប្តឹងនេះ ដើម្បីខ្ញុំឈឺចាប់ដោយសារឪពុកខ្ញុំជាប់គុក រួមទាំងខ្ញុំទៀត បងប្អូនឪពុកខ្ញុំទាំងអស់ ដើម្បីនៅជាប់នៅក្នុងគុកទួលស្លែងនេះតែម្តង ។ ហើយខ្ញុំសូមថា ឪពុកខ្ញុំខំតស៊ូពីនោះមក មកដល់នេះ ដែលគាត់-- យកគាត់ទៅដាក់គុកអស់ តើមូលហេតុអី?

**ស៖** អ៊ីចឹងបានយើងសរុបមកវិញ ថាលោកស្រីដែលបានដាក់ពាក្យប្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងរឿងក្ដីនេះ គឺអង្គហេតុដែលមានការ-- ពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ចំពោះជនជាប់ចោទ គឺអង្គហេតុនៅពាក់ព័ន្ធជាមួយនឹងមន្ទីរស-២១ ដែលបច្ចុប្បន្ននេះគឺជា គេហៅស្គាល់ជាទូទៅថាគុកទួលស្លែង ។ ហើយបញ្ហាទីពីរ គឺពាក់ព័ន្ធនឹងមន្ទីរនៃសន្តិសុខស-២១ នោះ គឺបានចាប់ឪពុកម្ដាយរបស់លោកស្រីយកមកដាក់គុកនៅទីនោះ ។ ហើយលោកស្រីក៏ត្រូវបានគេចាប់ខ្លួនយកមកដាក់ដែរ មកដាក់នៅទីនោះដែរ ។ អ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយលោក ។

**ស៖** ចុះបងប្អូនរបស់លោកស្រីមានការពាក់ព័ន្ធនៅក្នុងមន្ទីរស-២១ ឬក៏ដែលគេស្គាល់ជាទូទៅថាគុកទួលស្លែងហ្នឹងដែរឬទេ?

**ឆ៖** បងប្អូនខ្ញុំ ពុកម្ដាយខ្ញុំ រួមទាំងខ្ញុំនៅគុកទួលស្លែងផ្ទាល់តែម្ដង ។ បានថាខ្ញុំស្គាល់គុកទួលស្លែង គុកទួលស្លែងនេះដែលខ្ញុំធ្លាប់ធ្វើពីដើមមក ។ ខ្ញុំនៅពេទ្យក៏នៅនឹងក្នុងគុកទួលស្លែងនេះដែរ ។

**ស៖** ឥឡូវយើងអត់ទាន់ថាស្គាល់ ឬមិនស្គាល់ទេ ព្រោះលោកស្រីបានបញ្ជាក់ច្បាស់នៅក្នុងពាក្យបណ្ដឹង ហើយនៅក្នុងសម្ដីរបស់លោកស្រីនិយាយនៅពេលនេះ គឺបានបញ្ជាក់ទីតាំងច្បាស់ជាក់លាក់ គឺគុកទួលស្លែង-- មន្ទីសន្តិសុខស-២១ ដែលបច្ចុប្បន្នគេស្គាល់ជាទូទៅថាគុកទួលស្លែង ។ អាន់ុងអង្គជំនុំជម្រះមិនទាន់សួរដេញដោលដល់ទេ គ្រាន់តែនេះជាការបង្ហាញរបស់លោកស្រី ។

សំណួរតហ្នឹងសួរថា នៅក្នុងការដែលលោកស្រីប្ដឹងដូច្នេះនេះ តើមានការពាក់ព័ន្ធយ៉ាងម៉េចផ្ទាល់ទៅនឹងឪពុកម្ដាយរបស់លោកស្រី ទៅនឹងអង្គហេតុដែលកើតឡើងចំពោះគាត់នៅក្នុងមន្ទីរស-២១ ឬក៏គុកទួលស្លែង ចំពោះបងរបស់លោកស្រីពីរបីនាក់ តើវាមានហេតុការណ៍យ៉ាងម៉េចកើតចំពោះគាត់នៅទីនោះ? ហើយវាកើតយ៉ាងម៉េចដែរចំពោះខ្លួនរបស់លោកស្រីផ្ទាល់ ហើយនិងប្អូនរបស់លោកស្រីម្នាក់ទៀតដែលលោកស្រីថាឈ្មោះ ប្រាក់ យ៉ុន នោះ? លោកស្រីយល់ទេសំណួរនេះ តើវាមានកើតហេតុយ៉ាងម៉េចចំពោះឪពុកម្ដាយរបស់លោកស្រី? វាកើតហេតុយ៉ាងម៉េចចំពោះបងប្អូនរបស់លោកស្រី? បងបីនាក់ហើយនិងប្អូនម្នាក់ឈ្មោះ ប្រាក់ យ៉ុន? ហើយវាកើតហេតុយ៉ាងម៉េចចំពោះខ្លួនលោកស្រីផ្ទាល់ ដែលជំរុញឲ្យលោកស្រីតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះ ដើម្បីប្រឹងប្រែងទាមទារយុត្តិធម៌សម្រាប់ឪពុកម្ដាយបងប្អូនរបស់លោកស្រីនោះ?

**ផ៖** ខ្ញុំមកដាក់ពាក្យបណ្ដឹងនេះដោយឲ្យសុំលោកតុលាការជួយពិចារណា ។ ឪពុកខ្ញុំតស៊ូនៅក្នុង-- គាត់មកនៅទីក្រុងភ្នំពេញតាំងពីឆ្នាំ១៩៧៤ មកកប់ធ្វើផ្ទៃក្នុង ពុកខ្ញុំតស៊ូខ្មែរក្រហមរហូតតាំងពីខ្ញុំនៅតូចៗទាល់តែខ្ញុំធំ ។ គាត់បានមកបង្កប់ខ្លួននៅឆ្នាំ១៩៧៤ដល់ឆ្នាំ១៩៧៥ ដាច់ហើយក៏ជម្លៀសគាត់ចេញហើយគាត់ចូលមកប្រមូលនូវព័ស្ដុភារ នៅទីក្រុងភ្នំពេញនេះ ។

**ស៖** ឈប់ៗ ឥឡូវកំអាលៗរៀបរាប់យើងហេតុ យើងអត់ទាន់ចង់ទេ យើងចង់ដឹងព័ត៌មានមួយចំនួនសិន ថាតើគាត់មានបញ្ហាអី? គាត់ស្លាប់ ឬក៏គេគ្រាន់តែជាប់ឃុំឃាំង ហើយដោះលែង ហើយទៅរស់នៅទីណាឥឡូវឪពុកម្ដាយរបស់លោកស្រីនោះ ឬក៏គេសម្លាប់នៅទីនោះ? ហើយបងបីនាក់ទៀតហ្នឹងគេសម្លាប់ដែរទេ? ហើយលោកស្រីជាប់ឃុំឃាំង ហើយគេដោះលែង ឬក៏គេអត់ដាក់ឃុំឃាំងទេ? អង្គជំនុំជម្រះចង់ដឹងព័ត៌មានដើមសិន ពីព្រោះពេលវេលាខ្លី មិនទាន់ឲ្យលោកស្រីហ្នឹងរៀបរាប់ពីរឿងហេតុទេ ព្រោះរឿងហេតុប្រវត្តិហ្នឹងវាវែង អ៊ីចឹងទុកពេលវេលាវែងសម្រាប់ចង់ដឹង សម្រាប់លោកស្រីមានឱកាសក្នុងការនិយាយនៅរសៀល ។ លោកស្រីបញ្ជាក់មើលបញ្ហាហ្នឹង តើឪពុកម្ដាយរបស់លោកស្រីហ្នឹងមានយ៉ាងម៉េចនៅក្នុងគុកនោះឯង? ហើយបងប្អូនបីនាក់ទៀតយ៉ាងម៉េចដែរ? បងប្រុសរបស់លោកស្រីបីនាក់ទៀត ។

[១១:៥៨:៥៨]

**ផ៖** ចាស, លោកប្រធាន! អង្គហេតុដែលឪពុកខ្ញុំមកជាប់គុកទួលស្លែងនេះ គឺកាលនោះកាត់ធ្វើប្រធានព័ស្ដុភារនៅទីក្រុងភ្នំពេញ ។ នៅឆ្នាំ៧៧ គេចាប់គាត់មកដាក់គុកទួលស្លែង ព្រមទាំងបងប្អូនខ្ញុំទាំងអស់ ឪពុកម្ដាយទាំងអស់ យកមកដាក់ទីនេះ រួមទាំងខ្ញុំទៀតជាប់ខ្នោះនៅគុកទួលស្លែង ហើយគេបញ្ជាបងខ្ញុំឲ្យសម្លាប់ឪពុកខ្ញុំទៀត ។

**ស៖** អ៊ីចឹងបានន័យថា ឪពុកម្ដាយរបស់លោកស្រីហ្នឹងត្រូវបានគេចាប់បញ្ជូនមកគុកទួលស្លែង ហើយសម្លាប់ ហើយត្រូវគេសម្លាប់ហើយ ។ ចុះបងប្រុសរបស់លោកស្រីចំនួនបីនាក់ទៀត តើវាសនារបស់គាត់យ៉ាងម៉េចដែរ?

**ផ៖** បងប្រុសខ្ញុំចំនួនបីនាក់នេះ បងពីរនៅឃាមគុកទួលស្លែង គេបញ្ជាបងខ្ញុំឲ្យវ៉ៃឪពុកខ្ញុំរួចគេវ៉ៃបងខ្ញុំទៅតែម្ដង នេះដែលខ្ញុំឃើញផ្ទាល់ហ្នឹងភ្នែក ។

**ស៖** ចុះប្អូនពៅរបស់លោកស្រី គាត់នៅរស់ទេសព្វថ្ងៃ ឬក៏គាត់ត្រូវគេសម្លាប់ដែរ?

**ឆ៖** ប្អូនប្រុសរបស់ខ្ញុំគេចាប់ទៅជាមួយម្តាយខ្ញុំនៅគុកទួលស្លែងដែរ ប៉ុន្តែខ្ញុំចេញពីគុកទួលស្លែងនោះ-- គាត់ស្លាប់រួចទៅហើយ បានគេចាប់ខ្ញុំនៅក្នុងគុកទួលស្លែងនោះដែរ គាត់ក៏ស្លាប់នៅគុកទួលស្លែងនោះដែរ ជាមួយនឹងប្អូនខ្ញុំ ប៉ុន្តែស្លាប់ពេលវេលាខុសគ្នា ។

**ស៖** ហើយខ្លួនលោកស្រីផ្ទាល់គេចាប់បញ្ជូនទៅឃុំឃាំងនៅទួលស្លែង ប្រហែលជាអស់រយៈពេលប៉ុន្មានដែរទើបគេដោះលែងវិញ ហើយគេដោះលែងលោកស្រីឲ្យលោកស្រីទៅកាន់ទីណាដែរ?

**ឆ៖** ឯចំពោះយើងខ្ញុំគេចាប់នៅគុកទួលស្លែងហ្នឹងគេដាក់រយៈប្រហែលបីខែ គេបញ្ជូនខ្ញុំទៅគុកព្រៃស គេដាក់ខ្នោះជើងខ្ញុំ ដេកនៅបន្ទប់មួយតែឯង ។

**ស៖** ហើយរហូតដល់ពេលណាបានលោកស្រីបានចាកចេញពីគុកព្រៃស?

**ឆ៖** ចុងឆ្នាំ១៩៧៨ គេជូនខ្ញុំទៅគុកព្រៃទទឹង ខេត្តកំពង់ចាម បានយួនចូលរំដោះខ្ញុំបាន ។

**ស៖** អរគុណលោកស្រី ណាំ ម៉ុន ដែលបានផ្តល់ព័ត៌មានមួយចំនួនដែលជាដើមដំបូងនៃដំណើរការពិភាក្សាដេញដោលនេះ ដោយហេតុពេលវេលាដល់ពេលត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះនឹងបន្តដំណើរពិភាក្សាដេញដោលចាប់ពីវេលាម៉ោងមួយសាមសិបនាទីរសៀលនេះ ។ មន្ត្រីតុលាការសូមជូនលោកស្រី ណាំ ម៉ុន ដើម្បីធ្វើការសម្របសម្រួលឲ្យគាត់បានទទួលកន្លែងសម្រាកសមរម្យ ដោយសហការជាមួយនឹងអង្គភាពគាំពារជនរងគ្រោះ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់ទីនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី ។

*[សវនាការសម្រាកពីម៉ោង ១២:០៣នាទី ដល់ម៉ោង ១៣:៣០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី ណាំ ម៉ុន ។ មុននឹងចាប់ផ្តើមកិច្ចពិភាក្សាដេញដោលនេះ អង្គជំនុំជម្រះសូមប្រកាសនូវសេចក្តីសម្រេចកំណត់ពេលវេលាសម្រាប់ភាគី ស្តាប់ចម្លើយសាក្សី និងអ្នកជំនាញដែលអង្គជំនុំជម្រះបានចេញដីកាកំណត់កាលវិភាគសម្រាប់ធ្វើសវនាការចាប់ពី ថ្ងៃច័ន្ទ សប្តាហ៍ក្រោយរហូតដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ ដូចខាងក្រោម៖

អង្គជំនុំជម្រះសូមជូនដំណឹងដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះបានកំណត់ពេលវេលារួចហើយ នៅក្នុងតាំងសំណួរទៅសាក្សី ក៏ដូចជាដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវធ្វើសវនាការរយៈពេលមួយថ្ងៃ គឺរយៈពេល សាមសិបនាទីសម្រាប់សហព្រះរាជអាជ្ញា ។ សែសិបនាទី សម្រាប់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ។ សែសិបនាទី សម្រាប់មេធាវីការពារក្តី ។

ហេតុដូច្នេះ អង្គជំនុំជម្រះផ្អែកលើមូលដ្ឋានដែលបានកំណត់នេះ ក្នុងការគណនាពេលវេលាសម្រាប់ភាគីក្នុងការតាំងសំណួរដល់សាក្សី ឬអ្នកជំនាញ ដូចខាងក្រោមនេះ៖

សម្រាប់ការស្តាប់សក្ខីកម្មសាក្សី ឬអ្នកជំនាញ ដែលត្រូវចំណាយពេលវេលាកន្លះថ្ងៃ ពេលវេលាសម្រាប់សហព្រះរាជអាជ្ញាដប់ប្រាំនាទី ។ សម្រាប់មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ម្ភៃនាទី និងមេធាវីការពារក្តី ម្ភៃនាទី ។

សម្រាប់ការស្តាប់សក្ខីកម្មសាក្សី ឬអ្នកជំនាញដែលត្រូវចំណាយពេលវេលាមួយថ្ងៃកន្លះ សហព្រះរាជអាជ្ញាមានរយៈពេលសែសិបប្រាំនាទី ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមមានរយៈពេលហុកសិបនាទី និងមេធាវីការពារក្តីមានរយៈហុកសិបនាទី ។

សម្រាប់ការស្តាប់សក្ខីកម្មសាក្សី និងអ្នកជំនាញដែលត្រូវចំណាយពេលវេលាពីរថ្ងៃ សហព្រះរាជអាជ្ញាមានរយៈពេលហុកសិបនាទី ។ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុមមានរយៈពេល ប៉ែតសិបនាទី និងមេធាវីការពារក្តីមានរយៈពេល ប៉ែសិបនាទី ។ សូមភាគីទាំងអស់ជ្រាប ។

ជាកិច្ចបន្តអង្គជំនុំជម្រះនឹងស្តាប់នូវការពិភាក្សាដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ណាំ ម៉ុន ។

[១៣:១៣:៥៦]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ណាំ ម៉ុន គឺព្រឹកមិញអង្គជំនុំជម្រះបានសួរព័ត៌មានមួយចំនួនជាការចាប់ផ្តើមនៃការចង់ដឹងអំពីព័ត៌មាននានា ពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលជាមូលហេតុនាំឲ្យលោកស្រីប្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរឿងក្តីនេះ ។

ឥឡូវនេះអង្គជំនុំជម្រះចង់ដឹងថា អំពីប្រវត្តិនៃជីវិតលោកស្រី និងគ្រួសារលោកស្រីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រាំបីខែ-- បីឆ្នាំប្រាំបីខែមួយម្ភៃថ្ងៃ ដែលលោកស្រីនិងគ្រួសាររបស់លោកស្រីបានជួបប្រទះយ៉ាងដូចម្តេចខ្លះ ។ ចូរលោកស្រីនិទានរៀបរាប់អំពីដំណើរជីវិតរបស់លោកស្រី និងគ្រួសារ

លោកស្រី ជូនដល់អង្គសវនាការទាំងមូលបានស្តាប់ ។ សូមអញ្ជើញលោកស្រី ណាំ ម៉ុន ។

**ឆ៖** ប្រវត្តិឪពុកម្តាយខ្ញុំព្រមទាំងគ្រួសារខ្ញុំទាំងអស់ គឺពីដើមឡើយឪពុកខ្ញុំ ព្រមទាំងគ្រួសារខ្ញុំទាំងអស់ ឪពុកខ្ញុំរស់នៅតែក្នុងព្រៃទេ មិនបានរស់នៅទីក្រុងហ្នឹងគេទេ ។ គាត់ចេញតស៊ូតាំងពីខ្ញុំនៅតូចៗរហូតទាល់តែដល់ឆ្នាំ១៩៧៤ គាត់បានមកបង្កប់ខ្លួននៅក្នុងទីក្រុងភ្នំពេញនេះ គឺបានយករូបខ្ញុំទាំងម្តាយខ្ញុំមកនៅជាមួយ ។ គាត់មានមុខរបរនៅក្នុងទីក្រុងភ្នំពេញ គាត់លក់ដូរអីវ៉ាន់បន្តិចបន្តួច ទាល់តែឆ្នាំ១៩៧៥ បានគេជម្លៀសខ្ញុំចេញ ។ ហើយបកមកវិញ គឺខ្ញុំអាចនៅទីក្រុងភ្នំពេញនេះ តាំងពីដើមឆ្នាំ៧៥ រហូតដល់ឆ្នាំ៧៨ បានខ្ញុំចេញទៅទៀត ។ ឪពុកម្តាយខ្ញុំគាត់អ្នកតស៊ូតាំងពីខ្ញុំមិនទាន់នឹងដឹងអីផង គាត់ចេញទៅបាត់ហើយគាត់ខំតស៊ូហើយ តស៊ូបានជ័យជម្នះហើយ គឺគេយកគាត់ទៅសម្លាប់ចោលទៀត ។ ប្រវត្តិរបស់គាត់អ៊ីចឹង ។

**ស៖** លោកស្រីអាចនិយាយបានទៀតទេ ព្រោះកាលពីយើងសួរចង់ដឹងអំពីព័ត៌មានមួយចំនួន នៃមូលហេតុដែលពាក់ព័ន្ធជាមួយនឹងការប្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី លោកស្រីហាក់ដូចជាមានទំនោរមួយចង់និយាយរៀបរាប់អំពីប្រវត្តិ អំពីរឿងហេតុ រឿងរ៉ាវទាំងឡាយនៃជីវិតរបស់គ្រួសារលោកស្រី រួមទាំងលោកស្រីផង ដោយឆ្លងកាត់នូវទុក្ខសោកវេទនានៅក្នុងរបបកម្ពុជាប្រជាធិតេយ្យបីឆ្នាំប្រាំបីខែម្ភៃថ្ងៃនោះ ។ អ៊ីចឹង ហើយបានជាអង្គជំនុំជម្រះទុកលទ្ធភាពនេះ ជូនលោកស្រីដើម្បីនិទានរឿងហេតុនោះ ។ តើលោកស្រីអាចនិយាយបានទេ? និយាយឱ្យបានក្បោះក្បាយច្បាស់លាស់ជាងនេះ ។ តាំងពីដើមរហូត ហើយបើចង់សង្កត់ធ្ងន់នោះ គឺចាប់តាំងពីក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ទៅមានការចាប់ខ្លួនគ្រួសាររបស់លោកស្រី ដោយមានទាំងឪពុក ទាំងម្តាយបងប្អូនទាំងអស់ដោយកងកម្លាំងខ្មែរក្រហម ហើយនិងអំពើ ឬក៏សកម្មភាពផ្សេងៗទៀត ដែលកងកម្លាំងខ្មែរក្រហមបានប្រព្រឹត្តចំពោះឪពុកម្តាយបងប្អូនលោកស្រីនិងលោកស្រី ។ ហើយក្រោយមកទៀត គឺលោកបានចាកចេញតែម្នាក់ឯង ឬក៏ជាមួយនឹងប្អូនពៅរបស់លោកស្រីនោះ រហូតដល់ថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩ ។ នេះគឺជាព័ត៌មានដែលអង្គជំនុំជម្រះចង់ដឹង ចង់ឱ្យលោកស្រីនិយាយប្រាប់ដល់អង្គសវនាការទាំងមូលបានយល់អំពីស្ថានភាព អំពីទិដ្ឋភាពទាំងនេះ នៃជីវិតលោកស្រី និងគ្រួសាររបស់លោកស្រី ។ តើលោកស្រីអាចនិយាយតទៀតបានទេ?

**ឆ៖** ខ្ញុំអាចនិយាយបាន ។ ខ្ញុំតាំងពីរស់នៅជាមួយឪពុកខ្ញុំនៅក្នុងទីក្រុងភ្នំពេញ ខ្ញុំរស់នៅគុកទួលស្លែងនេះតែម្តង ។ ខ្ញុំបានធ្វើពេទ្យនៅក្នុងគុកទួលស្លែង ឪពុកខ្ញុំកាន់ព័ស្តុភារនៅខាងជើងគុកទួល

ស្តែង ។ ហើយក៏ខ្ញុំក៏មិនដឹងថាគេហ្នឹង ក៏ចាប់ឪពុក ឬមួយគាត់មានកំហុសអីក៏ខ្ញុំមិនដឹងដែរ ។ ប៉ុន្តែ ខ្ញុំឃើញចាប់ពូខ្ញុំ ព្រមទាំងពូខ្ញុំទាំងពីរយកមកមុន ក៏ខ្ញុំក៏ថា ខ្ញុំក៏មិនដឹង ។ មិនដឹងដែលមានកំហុសអី ដែលចាប់ពួកឪពុកយើងខ្ញុំ ខ្ញុំកើតវេទនានៅក្នុងសម័យនោះ គឺខ្ញុំពិបាកយ៉ាងខ្លាំង ព្រាត់ម្តាយ ព្រាត់ឪពុក ព្រាត់បង ព្រាត់ប្អូន ។ ចាប់ពូខ្ញុំ គាត់គេចាប់មកតាំងពីឆ្នាំ-- ពាក់កណ្តាលឆ្នាំ៧៦ ។ ឯចំណែកឪពុកខ្ញុំគេចាប់មកនៅឆ្នាំ៧៧ ម្តាយខ្ញុំចុងឆ្នាំ៧៧ ។ ព្រមទាំងប្អូនដែលខ្ញុំចាកចេញពីនេះទៅនៅទីលំនៅសព្វនេះ គឺខ្ញុំចាកចេញទៅតែឯងទេ ឯចំណែកប្អូនចិញ្ចឹមខ្ញុំបានជួបគ្នានៅគុកព្រៃទទឹង ។ នោះប្អូនចិញ្ចឹម ឯចំណែកប្អូនបង្កើតរបស់ខ្ញុំ គឺស្លាប់នៅគុកទួលស្លែងជាមួយម្តាយខ្ញុំបាត់ទៅហើយ ។

**ស៖** លោកស្រីចាំស្តាប់សំណួររបស់យើងម្តង ព្រោះលោកស្រីរៀបរាប់ទៅជាការលំបាកមួយដោយសាររឿងហេតុវាកើតឡើងយូរហើយ ជាងសាមសិបឆ្នាំ ហើយជាការប៉ះពាល់មួយផ្នែកខាងសតិអារម្មណ៍របស់លោកស្រី ដោយសារជួបប្រទះនូវរឿងអកុសលមង្គលនៅក្នុងឆាកជីវិតរបស់លោកស្រី និងគ្រួសារអាចជាមូលហេតុនាំឲ្យលោកស្រីមិនអាចធ្វើការរៀបរាប់អំពីប្រវត្តិដ៏ជូរចត់នេះ ជូនអង្គសវនាការបាន ។

សំណួរ ឥឡូវស្តាប់សំណួរយើងនេះ ។ នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើលោកស្រីរស់នៅ ឯណា? ហើយលោកស្រីធ្វើអ្វី?

[១៣:៤១:១៨]

**ឆ៖** នៅមុនឆ្នាំ៧៥ គឺខ្ញុំរស់នៅទីក្រុងភ្នំពេញ ខ្ញុំនៅជាមួយឪពុកម្តាយខ្ញុំ ។ ដល់ទៅឆ្នាំ៧៥ ខ្ញុំ--

**ស៖** ចាំស្តាប់សំណួរសិនណា ។ លោកស្រីអាចមិនអាចនិយាយបានទេ ព្រោះយើងបានសាកល្បងពីរដងហើយ លោកស្រីមិនអាចពិពណ៌នា ឬក៏រៀបរាប់បានច្បាស់លាស់ទេ ។ អ៊ីចឹងបណ្តោយឲ្យលោកស្រីអត្ថាធិប្បាយ ឬពិពណ៌នាហ្នឹង កាន់តែច្របូកច្របល់ ហើយមិនអាចកំណត់បាននូវអង្គហេតុនូវហេតុការណ៍ដែលកើតមានឡើងចំពោះគ្រួសាររបស់លោកស្រីពាក់ព័ន្ធជាមួយនឹងការប្តឹងទាមទារនេះបានទេ ។

ចុះឪពុកម្តាយរបស់លោកស្រីនៅ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ គាត់រស់នៅឯណាដែរ? ហើយគាត់ប្រកបមុខរបរអ្វីដែរ?

**ឆ៖** មុនឆ្នាំ៧៥ គឺគាត់រស់នៅទីក្រុង គាត់លក់ដូរនៅក្រុងភ្នំពេញ ។

**ស៖** គាត់នៅកន្លែងណាទីក្រុងភ្នំពេញ ទីក្រុងភ្នំពេញមានលក្ខណៈធំណាស់ មានសង្កាត់ មានខណ្ឌ តើគាត់នៅសង្កាត់ណា? ខណ្ឌណានៃទីក្រុងភ្នំពេញ ឬទីកន្លែងណាបច្ចុប្បន្នដែលតាមលោកស្រីចងចាំ?

**ឆ៖** គឺខ្ញុំមិនអាចចាំបានទេ ព្រោះខ្ញុំនៅតូច ។

**ស៖** ចុះក្រោយថ្ងៃរំដោះ ១៧ ខែមេសា ឆ្នាំ៧៥ តើលោកស្រីរស់នៅកន្លែងណា? ហើយឪពុកម្តាយ របស់បងប្អូនរបស់លោកស្រីរស់នៅកន្លែងណាដែរ?

**ឆ៖** នៅក្នុងឆ្នាំ៧៥ ខ្ញុំរស់នៅទីក្រុងភ្នំពេញ ព្រមទាំងបងប្អូនឪពុកម្តាយខ្ញុំទាំងអស់ ។ ខ្ញុំបានឪពុកខ្ញុំ ឲ្យខ្ញុំរៀនធ្វើពេទ្យនៅទីក្រុងភ្នំពេញ ។

**ស៖** គ្រួសាររបស់លោកស្រីក្រោយថ្ងៃរំដោះមានទៅដល់ខេត្តកំពង់ចាមវិញដែរទេ?

**ឆ៖** អត់បានទេ ទៅត្រឹមព្រែកក្តាមទេ ហើយបកមកវិញ ។

**ស៖** ពេលឪពុកម្តាយរបស់លោកស្រីនិងគ្រួសាររបស់លោកស្រីត្រឡប់មកចូលក្រុងភ្នំពេញវិញដោយមូលហេតុទៅ? ហើយចូលត្រឡប់មកក្រុងភ្នំពេញនៅថ្ងៃខែឆ្នាំណា? លោកស្រីចាំទេ ត្រឡប់ពីព្រែកក្តាមមកក្រុងភ្នំពេញវិញ?

**ឆ៖** គឺខ្ញុំអត់ដឹងថ្ងៃ អត់ដឹងខែទេ ។ ប៉ុន្តែថា នៅក្នុងឆ្នាំ៧៥ ដែលជម្លៀសពួក៧៥ ចេញអស់ទៅគឺឪពុកមកកាន់ព័ស្តុភារនៅទីក្រុងនេះវិញ ។

[១៣:៤៤:៣៣]

**ស៖** គាត់ធ្វើការនៅពស្តុភារ កាន់ព័ស្តុភារនៅមន្ទីរក្រសួងណា? អង្គភាពណាដែរ?ហើយកន្លែងដែលគាត់ធ្វើការនៅកន្លែងណា? លោកស្រីចាំទេ?

**ឆ៖** គឺខ្ញុំអត់បានស្គាល់កន្លែងទេ ដែលធ្វើហ្នឹង ព្រោះខ្ញុំអាលែងតែទៅ-- ខ្ញុំអត់ទាន់បានដឹងស្គាល់ទីក្រុងភ្នំពេញហ្នឹងវារបៀបម៉េច? ទៅខាងណាៗព្រោះខ្ញុំនៅតូច ។ នៅក្មេងពេកមិនមែនតូចទេ ។

**ស៖** លោកស្រីចាំទេ នៅក្រោយ-- នៅក្នុងឆ្នាំ១៩៧៥ ហ្នឹងលោកស្រីមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ខ្ញុំនៅក្នុងឆ្នាំ៧៥ ខ្ញុំអាយុ១៥ឆ្នាំ ។

**ស៖** ចុះកន្លែងរស់នៅវិញ លោកស្រីពេលដែលខាងកងកម្លាំងរបស់ខ្មែរក្រហមបានឲ្យគ្រួសាររបស់លោកស្រីហ្នឹងមកនៅក្រុងភ្នំពេញហ្នឹង សួរថាមកនៅកន្លែងណា? ម្តុំណាទៅកន្លែងដែលរស់នៅផ្ទះលំនៅដ្ឋានដែលលោកស្រីហ្នឹងឈ្មោះអ្វីដែលទីនោះ? ទួលគោក ទួលសង្កែ ពោធិ៍ចិនតុង ស្ទឹងមានជ័យ

ឧទាហរណ៍អ៊ីចឹង តើក្នុងតំបន់ណាមួយដែលនៃទីក្រុងភ្នំពេញនេះ?

**ឆ៖** ខ្ញុំមិនដឹងខាងណា ប៉ុន្តែខ្ញុំដឹងថា ខ្ញុំជិតខាងត្បូងគុកទួលស្លែង ប៉ុន្តែមិនដឹងគេហៅស្អី?

**ស៖** លោកស្រីដឹងទេ? ថាហេតុអីបានជាគ្រួសាររបស់លោកស្រីហ្នឹងបានត្រឡប់មកវិញ? តើមានខាងណាគេហៅត្រឡប់មកវិញ មកចូលធ្វើការនៅឯទីក្រុងភ្នំពេញពីចំណុចលោកស្រីថាព្រែកក្តាមអំមិញ?

[១៣:៤៦:៥១]

**ឆ៖** គឺខ្ញុំអត់បានដឹងរឿងរ៉ាវដែលគាត់តស៊ូពីមុនមកផង។ ខ្សែរយៈគាត់ដែលគេទាក់ទងគាត់មកនៅទីក្រុងភ្នំពេញក៏ខ្ញុំមិនអាចដឹងគាត់បានដែរ បើគាត់អត់ដែលនិយាយផង ។ ខ្ញុំមកតាមគាត់ដែរ ។

**ស៖** លោកស្រីអះអាងថា លោកស្រី គ្រួសាររបស់លោកស្រីបានរស់នៅខាងត្បូងគុកទួលស្លែងបច្ចុប្បន្ន ។ សំណួរសួរថា អំមិញឪពុកលោកស្រីធ្វើជាព័ស្តុភារ ចុះម្តាយរបស់លោកស្រីគាត់អ្វីដែរ? ធ្វើការអ្វីដែរ?

**ឆ៖** ម្តាយខ្ញុំគាត់នៅជាមួយឪពុកខ្ញុំ គាត់អត់មានធ្វើអីទេ នៅតែផ្ទះ ។

**ស៖** ចុះបងៗទាំងបីនាក់របស់លោកស្រី កាលដែលត្រឡប់មកនៅក្រុងភ្នំពេញ ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ៧៥ នោះ តើគាត់រស់នៅជាមួយនឹងឪពុកម្តាយរបស់លោកស្រីដែរឬទេ? ហើយបងៗទាំងបីនាក់នោះគាត់ធ្វើអ្វីដែរ?

**ឆ៖** បងពីរនាក់នោះរស់នៅយាមគុកទួលស្លែងហ្នឹងពីដើមដំបូងរហូតមក ។ ឯបងម្នាក់ទៀតនៅជាមួយពួខ្ញុំ នៅខាងវាលវង់កប៉ាល់ហោះ ។ ធ្វើជាទាហាននៅយាមគុកទទួលស្លែងតាំងពីឆ្នាំ៧៥រហូត។

**ស៖** ក្នុងចំណោមបងបីនាក់ តើបងពីរនាក់ដែលថានៅគុកទួលស្លែងហ្នឹង បងឈ្មោះអ្វីខ្លះ?

**ឆ៖** បងខ្ញុំឈ្មោះ នឿន មួយ ឈ្មោះ រឿន មួយដែលនៅគុកទួលស្លែងនេះ យាមនៅគុកនេះ ។

[១៣:៤៩:១៣]

**ស៖** ក្នុងអំឡុងពេលដែលបងលោកស្រីធ្វើការនៅក្នុងគុកទួលស្លែង តើគាត់រស់នៅកន្លែងណា? គាត់រស់នៅកន្លែងធ្វើការ ឬក៏គាត់រស់នៅជាមួយនិងឪពុកម្តាយរបស់លោកស្រីនៅខាងត្បូងគុកទួលស្លែង?

**ឆ៖** គាត់រស់នៅកន្លែងគាត់ធ្វើការហ្នឹងតែម្តង ។

**ស៖** ចុះបងម្នាក់ទៀត ដែលថាធ្វើការនៅព្រលានយន្តហោះ? ឈ្មោះអ្វីដែរ? ហើយគាត់ធ្វើការនៅទីនេះធ្វើអ្វី?

**ឆ៖** បងម្នាក់ដែលនៅព្រលានយន្តហោះនោះគាត់ឈ្មោះខឿន គាត់ធ្វើការជាមួយពួខ្ញុំខាងកប៉ាល់ហោះបើកបរទៅវិញទៅមកនៅប្រទេសក្រៅ ។

**សៈ** រឿងរ៉ាវរបស់លោកស្រីលោកស្រីបានលើកឡើងថា ឪពុករបស់លោកស្រីត្រូវបានអង្គការចាប់ខ្លួនមុន សំណួរសួរថា ឪពុករបស់លោកស្រីហ្នឹងត្រូវអង្គការចាប់ខ្លួននៅថ្ងៃខែឆ្នាំណា? ហើយចាប់យកចេញពីកន្លែងណា?

**ឆ៖** ចាប់នៅក្នុងឆ្នាំ៧៧ ប៉ុន្តែថ្ងៃខែយើងខ្ញុំអត់ដឹងទេ ។ ចាប់ចេញពីផ្ទះកន្លែងគាត់ដែលគាត់កាន់កាប់នៅកន្លែងនោះតែម្តង ។

**សៈ** គេចាប់ឪពុករបស់លោកស្រីនឹងនៅពេលយប់ឬក៏ពេលថ្ងៃ ហើយពេលដែលគេមកចាប់នឹងគេប្រើមធ្យោបាយអ្វីដែរ ពេលដែលមកចាប់ឪពុករបស់លោកស្រីនៅហ្នឹងផ្ទះដែលគាត់រស់នៅនោះ?

**ឆ៖** គេចាប់គាត់នៅព្រលប់ៗប្រហែលម៉ោងប្រាំមួយ ប៉ុន្តែខ្ញុំមិនបានជាឃើញគេចាប់ជំរិតចុះពីលើផ្ទះក៏មិនដឹងដែរ ក៏ប៉ុន្តែខ្ញុំឃើញគេបណ្តើរគាត់រុំមុខចូលនៅក្នុងគេតែម្តង ។ ចូលក្នុងផ្ទះគេដាក់នុំងតែម្តង ។

**សៈ** ផ្ទះលោកស្រី ឪពុកលោកស្រី-- ឪពុកម្តាយលោកស្រីដែលថានៅខាងត្បូងគុកនុំង គុកទួលស្លែងហ្នឹងនៅចម្ងាយប៉ុន្មានពីគុកទួលស្លែងបច្ចុប្បន្ននេះ? លោកស្រីស្គាល់ទេ? ស្គាល់គុកទួលស្លែងបច្ចុប្បន្ននេះជាក់ដែរឬទេ?

**ឆ៖** ស្គាល់ ប៉ុន្តែនៅឆ្ងាយណាស់ប្រហែលជាពីរគីឡូពីគុកទួលស្លែង ។

[១៣:៥២:៤៧]

**សៈ** ផ្ទះនៅចម្ងាយពីរគីឡូពីគុកទួលស្លែង ហើយការដែលពួកអង្គការខ្មែរក្រហមមកចាប់ឪពុកលោកស្រីហ្នឹងនៅវេលាម៉ោងប្រាំមួយល្ងាច ។ ហើយហេតុផលយ៉ាងម៉េចទៅបានជាលោកស្រីឃើញថាគេចាប់ឪពុកលោកស្រីរុំមុខ ហើយយកចូលទៅដាក់ក្នុងគុកទួលស្លែងតែម្តង? វាហេតុផលយ៉ាងម៉េចបានជាលោកស្រីដឹងរឿងនេះច្បាស់? ទីមួយគឺចម្ងាយពីរគីឡូ ។ ពីរគីឡូនេះផ្ទះនៅក្រុងភ្នំពេញទៀតមិនមែននៅជនបទទេ ។ ហើយទីពីរ គឺប្រហែលជាម៉ោងប្រាំមួយល្ងាច នេះជាពីរចំណុច ។ លោកស្រីអាចពន្យល់បានច្បាស់លាស់ទេលើចំណុចនេះ?

**ឆ៖** កាលពីខ្ញុំអះអាងថា ម៉ោងប្រាំមួយល្ងាច ឬមួយចាប់ឃ្លុំមុខដាក់នៅក្នុងផ្ទះ ខ្ញុំប៉ានអះអាងថាខ្ញុំរស់នៅនៅក្នុងគុកទួលស្លែងនុំងដែរ ។ ខ្ញុំធ្វើពេទ្យនៅត្រង់នោះបងខ្ញុំក៏យាមនៅត្រង់នោះ ស្រាប់តែ

ក្រឡេកឃើញឪពុក ពីរនាក់បងប្អូនក៏ដឹងពេលវេលានោះទៅ ។

**ស៖** អ៊ីចឹងបានសេចក្តីថា កាលដែលពួកអង្គការចាប់ឪពុកលោកស្រីនោះ មិនមែនលោកស្រីនៅហ្នឹងផ្ទះជាមួយនឹងគាត់ទេ គឺលោកស្រីនៅឯមន្ទីរស-២១ ឬគុកទួលស្លែងបច្ចុប្បន្ននេះទេ ។ ហើយការដែលបានឃើញថា គេចាប់ឪពុកហ្នឹងបញ្ជូនមកដាក់គុកទួលស្លែងហ្នឹងដោយសារលោកស្រីបានជួបដោយចៃដន្យ បានឃើញដោយចៃដន្យនៅពេលដែលគេបញ្ជូនមកដល់គុកហើយ ។ អ៊ីចឹងមែនទេ ដែលលោកស្រីចង់និយាយអម្បាញ់មិញនេះ?

[១៣:៥៤:៥២]

**ឆ៖** ពិតមែនហើយ ។ អ៊ីចឹងមែន ។

**ស៖** លោកស្រីចូលធ្វើពេទ្យនៅគុកទួលស្លែងហ្នឹងចាប់ចូលធ្វើការនៅថ្ងៃខែឆ្នាំណាដែរ? លោកស្រីចាំទេ?

**ឆ៖** គឺខ្ញុំ ខែគឺខ្ញុំអត់បានចាំទេ ចាំឆ្នាំ ពាក់កណ្តាលឆ្នាំ៧៥ គឺខ្ញុំអាចមកធ្វើពេទ្យនៅគុកទួលស្លែងហ្នឹង រហូតដល់ឆ្នាំ៧៧ គេចាប់ឪពុកម្តាយខ្ញុំហើយទើបគេដកខ្ញុំឈប់ឲ្យធ្វើ ។

**ស៖** កាលពីលោកស្រីចូលធ្វើពេទ្យនៅគុកទួលស្លែងបច្ចុប្បន្ន ពីមុនមែនហៅគុកទួលស្លែងទេ គឺមន្ទីរស-២១ នេះជាការអះអាងរបស់លោកស្រី ។ សំណួរសួរថា តើទីតាំងនៃមន្ទីរស-២១ កាលណោះនៅកន្លែងណា? កាលពីលោកស្រីចូលធ្វើពេទ្យក្នុងពាក់កណ្តាលឆ្នាំ១៩៧៥ នោះ?

**ឆ៖** មិនច្បាស់ សូមបញ្ជាក់ម្តងទៀត ។

**ស៖** លោកស្រីបានឆ្លើយហើយថា អំមិញលោកស្រីបានចូលធ្វើពេទ្យនៅក្នុងគុកទួលស្លែងនៅពាក់កណ្តាលឆ្នាំ១៩៧៥ ។ សំណួរសួរថា កាលពីលោកស្រីចូលធ្វើពេទ្យនៅក្នុងគុកទួលស្លែងដែលពីមុនគេមិនមែនហៅគុកទួលស្លែងទេ គឺជាមន្ទីរសន្តិបាលស-២១ សំណួរសួរថា អង្កាល់នោះមន្ទីរសន្តិបាលស-២១ហ្នឹង មានទីតាំងនៅកន្លែងណានៅកន្លែងបច្ចុប្បន្ន ឬនៅកន្លែងណា? មិននៅកន្លែងបច្ចុប្បន្នទេ គឺនៅកន្លែងដែលបច្ចុប្បន្នហ្នឹង គេបានកែប្រែដាក់ជាសារមន្ទីរទួលស្លែង ឬក៏យើងហៅទូទៅគុកទួលស្លែងនៅកន្លែងហ្នឹង ឬនៅកន្លែងណា? កាលពីលោកស្រីចូលធ្វើពេទ្យដំបូងៗនោះ?

[១៣:៥៧:៣១]

**ឆ៖** កាលខ្ញុំចូលដំបូងនោះ គឺខ្ញុំរៀនពេទ្យដំបូងគឺខ្ញុំរៀននៅប៉ុស្តិ៍វ៉ាឌ្យូ ប៉ុស្តិ៍លេខ៥ យើងនេះ ។ ដល់ពេលចុង-- រួចទៅខ្ញុំរៀនចប់ហើយគេឲ្យខ្ញុំមកធ្វើពេទ្យនៅគុកទួលស្លែងយើងសព្វថ្ងៃនេះតែម្តងនៅ

ក្នុងឆ្នាំ៧៥ ។

**ស៖** ក្នុងអំឡុងពេលដែលលោកស្រីធ្វើពេទ្យដែលលោកស្រីអះអាងថា នៅក្នុងគុកទួលស្លែងទីមួយ សួរថា កាលពីណោះ គេហៅកន្លែងហ្នឹងគេហៅថាម៉េច? មន្ទីរដែលលោកស្រីធ្វើការហ្នឹងជាមន្ទីរអ្វីទៅ? ឈ្មោះអ្វីទៅ?

**ឆ៖** ខ្ញុំមិនដឹងជាគេហៅម៉េចទេ? ទាល់តែឮគេនិយាយបន្តបន្ទាប់បន្តថា កន្លែងនេះហើយគេដាក់អ្នកទោស គឺអ្នកធំ បានគេដាក់គុកនេះបាន ។ ដាក់កន្លែងនេះបាន ខ្ញុំមិនដឹងថាគេហៅស្អី បន្តមកទៀតគេហៅថា គុកទួលស្លែងហ្នឹងស-២១ នេះហើយ ។

**ស៖** ក្នុងអំឡុងពេលដែលលោកស្រីទៅធ្វើជាពេទ្យនៅ-- អះអាងថានៅមន្ទីរស-២១ ឬទួលស្លែងនោះ ។ សំណួរទីមួយថា ក្រុមពេទ្យដែលលោកស្រីទៅធ្វើការនុ៎ងមានគ្នាប៉ុន្មាននាក់? ហើយមានឈ្មោះអ្វីខ្លះដែលលោកស្រីនៅចងចាំ?

**ឆ៖** គឺខ្ញុំធ្វើពេទ្យនៅក្នុង-- គេចាត់តាំងឲ្យខ្ញុំមកធ្វើពេទ្យនៅក្នុងស-២១ ក្នុងគុកទួលស្លែងយើងនេះគឺមានចំនួនបីនាក់ ។ ទីមួយ មិត្តលន ទីពីរ ខ្ញុំ ទីបី មិត្តឃីម ។

**ស៖** មិត្តលន ប្រុស ឬក៏ស្រី ហើយមិត្ត ឃីម ប្រុស ឬក៏ស្រី?

**ឆ៖** សុទ្ធតែស្រីទាំងអស់ទេ ។

[១៤:00:00]

**ស៖** និយាយពីការិយាល័យ ឬក៏កន្លែងធ្វើការរបស់លោកស្រី និងមិត្តពីរនាក់ទៀតរបស់លោកស្រី គឺមិត្តលន និងមិត្តឃីម តើកន្លែងធ្វើការរៀងរាល់ថ្ងៃនៃពេទ្យហ្នឹង? តើលោកស្រីធ្វើការនៅកន្លែងណា? តើលោកស្រីអាចចំណាំបានទេ បើចំណាំមិនបាន អាចចង្អុលថាខាងក្នុង ផ្នែកខាងអគារណាមួយ ឬក៏ខាងក្រៅ ខាងកើត ខាងលិច ខាងជើង ខាងត្បូង នៃទួលស្លែងបច្ចុប្បន្នដែលលោកស្រីបានអះអាងថាបានស្គាល់ច្បាស់នោះ?

**ឆ៖** បច្ចុប្បន្នឥឡូវនេះ ខ្ញុំដើរទៅមើលរូបថត ក៏ខ្ញុំ គឺផ្ទះដែលខ្ញុំធ្វើពេទ្យនៅសម្រាកនោះ គឺផ្ទះខាងជើង ទល់មុខគុកទួលស្លែងនេះតែម្តង ។

**ស៖** គុកទួលស្លែងខាងជើង ហើយមុខគុកទួលស្លែង មានន័យថាម៉េចទៅ? គុកទួលស្លែងឥឡូវរាល់ថ្ងៃនេះ លោកស្រីយល់ថា បែរមុខទៅណា គុកទួលស្លែងរាល់ថ្ងៃនេះ?

**ឆ៖** កន្លែងហ្នឹង មិនដឹងថាគេហៅថាខាងអី បើខាងខ្ញុំនោះ គេហៅខាងជើង ខាងទល់មុខគុកទួលស្លែងនេះ កន្លែងច្រកចូលនេះ ។

**ស៖** អ៊ីចឹងលោកស្រីមិនច្បាស់ទេ ប៉ុន្តែការិយាល័យរបស់លោកស្រីដែលធ្វើការហ្នឹង គឺនៅទល់មុខកន្លែងដែលច្រកចូលគុកទួលស្លែងបច្ចុប្បន្ន អ៊ីចឹងទេ?

**ឆ៖** អ៊ីចឹងមែនហើយ ខ្ញុំនៅខាងមុខគុកទួលស្លែង ។

**ស៖** នៅទួលស្លែងអ៊ីចឹង មានផ្លូវមួយពីជើងទៅត្បូង ហើយផ្លូវមួយទៀតតូចមួយ មិនធំពីមុខទេ គឺចំហៀងខាងត្បូង មានផ្លូវតូចមួយទៀតទៅកើត ។ តើកន្លែងដែលលោកស្រីអះអាងថា ជាកន្លែងដែលធ្វើការរបស់ពេទ្យ ដែលលោកស្រី ហើយនិងមិត្រភក្តិ មិត្តបីពីរនាក់ទៀត មិត្តលន និងឃីម ធ្វើការហ្នឹង នៅផ្លូវអាបណ្ដោយជើង ទៅត្បូងអ៊ីចឹង អាចំទល់មុខ មុខកន្លែងខ្លោងទ្វារចេញចូលហ្នឹងតែម្ដង ឬក៏មានផ្លូវតូចចូលទៅខាងក្នុងទៀត?

**ឆ៖** នៅផ្លូវច្រកចូល ផ្លូវធំតែម្ដង នៅទល់មុខហ្នឹង ទល់មុខចូលទៅគុកហ្នឹងតែម្ដង ផ្លូវធំហ្នឹង ។

**ស៖** ហើយពេទ្យដែលលោកស្រីធ្វើការហ្នឹង មានតែបីនាក់ហ្នឹងទេ? ចុះអ្នកណាគេជាប្រធានខាងផ្នែកពេទ្យនេះ?

[១៤:០៣:០១]

**ឆ៖** ...អាចប្រធាន អាចបង្រៀនខ្ញុំបន្តបន្ទាប់មក មានតែបីនាក់ហ្នឹងទេ ដែលគេចាត់តាំងឲ្យមកនៅទីនេះ ។ មានមិត្តលន ខ្ញុំ មិត្តឃីម តែប៉ុណ្ណឹង គ្មានប្រធានទេ ។

**ស៖** លោកស្រីអះអាថា លោកស្រីធ្វើពេទ្យ តើមុខងាររបស់លោកស្រី និងមិត្តលន មិត្តឃីម ដែលសុទ្ធតែជាពេទ្យទៅពិនិត្យរោគព្យាបាលដល់ទៅអ្នកណាខ្លះទៅ? ព្យាបាលឲ្យបុគ្គលិកនៃមន្ទីរដែលលោកស្រីធ្វើការនោះ ឬក៏ព្យាបាលឲ្យអ្នកណាផ្សេង?

**ឆ៖** នៅក្នុងមួយចំណោមដែលពួកខ្ញុំទាំងបីធ្វើការនៅក្នុងគុកទួលស្លែង គឺបែងចែកជាបី ខ្ញុំក៏ដើរតាមមើលខុសត្រូវ តាមអគារបណ្ដោយថ្ងៃ ឯចំណែកមិត្តទាំងពីរទៀត មើលអគារទាំងបួនបន្ថែមទៀត ខ្ញុំមើលតែអគារតែមួយទេ ។

**ស៖** លោកស្រីមើលអគារខាងណាមួយ? អគារបណ្ដោយថ្ងៃ អាម៉េចទៅហៅថាអគារបណ្ដោយថ្ងៃ?

**ឆ៖** ត្រង់នៅហ្នឹងបណ្ដោយថ្ងៃ! បច្ចុប្បន្នឥឡូវ ខ្ញុំដើរទៅឃើញអគារហ្នឹងធំជាងគេ មានបីជាន់

អគារបណ្តោយថ្ងៃនៅជិតដើមដូងពីក្រោយ ។

**ស៖** ពេលដែលលោកស្រីចូលទៅ ដើរចូលទៅខ្លាងទ្វារអ៊ីចឹង អគារដែលលោកស្រីថា មើលការខុសត្រូវហ្នឹង អគារខាងណាមួយ ខាងឆ្វេងដៃរបស់លោកស្រី ឬក៏ខាងស្តាំដៃរបស់លោកស្រី?

**ឆ៖** ដើរចូលទៅ គឺអគារនោះចំមុខតែម្តង អគារបណ្តោយថ្ងៃ គឺចំមុខច្រកចោល ប៉ុន្តែខាងក្រោយ ។ អគារទាំងអស់ វាមានប្រាំអគារ អគារធំពីរ អគារតូចបី ។ ធំខាងត្បូង ធំខាងជើង ។ គឺខ្ញុំអាចមើលអគារបណ្តោយថ្ងៃខាងជើង ។

**ស៖** អគារដែលលោកស្រីមើលៗអ្នកទោសហ្នឹង អគារកន្លែងណាមួយឲ្យច្បាស់លាស់ ព្រោះដូចមានបញ្ហាមិនច្បាស់លាស់ ។ អគារណាមួយក្នុងចំណោមពេលដែលលោកស្រីដើរចូលអ៊ីចឹងទៅ តើអគារណាមួយ? អំមិញថាទល់មុខ មានអគារបី តើអគារណាមួយ?

**ឆ៖** អគារដើរចូលពីនេះទៅ មានអគារតូចមួយ ចំហៀងខាងណោះតូចមួយ ខាងណេះធំ ខាងនេះធំ តូចមកកណ្តាលទៀត អាគារមានប្រាំ តែខ្ញុំនៅខាងមើលអគារហ្នឹងខាងត្បូង ជួរខាងត្បូងខាងក្រោយគេ អគារតូចៗនៅកណ្តាល ។

**ស៖** ចុះអគារពីរទៀតនៅខាងណា? អគារតូចៗនៅកណ្តាល អគារធំនៅខាងណា?

**ឆ៖** អគារធំនៅអមអគារតូចទាំងសងខាង នៅខាងជើង ខាងត្បូង អគារតូចនៅខាងលិច ខាងកើត ។

[១៤:០៧:០៩]

**ស៖** អ៊ីចឹងលោកស្រីដែលទៅមើលអ្នកទោស ព្យាបាលអ្នកទោសហ្នឹង នៅអគារខាងណាមួយច្បាស់លាស់ អគារខាងលិច ខាងកើត ឬក៏អគារខាងជើង ខាងត្បូង?

**ឆ៖** ខ្ញុំមើលនៅអគារខាងត្បូង ។

**ស៖** ពេលលោកស្រីចូលទៅ អគារហ្នឹងនៅខាងណា ខាងណាដៃរបស់លោកស្រី បើពេលលោកស្រីដើរចូលទៅក្នុងមន្ទីរនៃបរិវេណហ្នឹង តើលោកស្រីនៅខាងឆ្វេងដៃរបស់លោកស្រី ឬក៏នៅខាងស្តាំរបស់លោកស្រី?

**ឆ៖** បើខ្ញុំដើរចូលទៅ ហើយខ្ញុំបែរមុខទៅខាងកើត គឺនៅខាងស្តាំ បើខ្ញុំបែរមុខមកខាងលិច គឺនៅខាងឆ្វេងដៃ ។

**ស៖** អ៊ីចឹងលោកស្រីច្បាស់លាស់ហើយ ខាងកើត ខាងលិចមែនទេ? អំមិញអត់ច្បាស់ទេ ឥឡូវ

ច្បាស់ខាងកើត ខាងលិច ។ ច្រកចេញនៃមន្ទីរគុកទួលស្លែងហ្នឹង ច្រកចេញចូលហ្នឹងនៅខាងណាចេញទៅទិសខាងណា? ចេញទៅទិសខាងណា? ចូលពីទិសខាងណាមក ចេញទៅទិសខាងណា?

**ឆ៖** បើតាមការរៀបរាប់របស់នាងខ្ញុំ ចូលពីច្រកខាងជើង ។

**ស៖** ឥឡូវនិយាយដល់ទៅរឿងរ៉ាវរបស់ឪពុកលោកស្រីវិញ ពេលដែលលោកស្រីអះអាងថា បានឃើញនៅក្នុងអំឡុងពេលដែលគេចាប់បញ្ជូនមក ។ តើលោកស្រីនៅកន្លែងណា ហើយកំពុងធ្វើអ្វីបានជាលោកស្រីបានឃើញ?

**ឆ៖** គឺដែលខ្ញុំបានឃើញឪពុកខ្ញុំ ដែលបានគេចាប់យកមកនេះ គឺពេលព្រលប់នេះ ពួកខ្ញុំអាចដើរតាមផ្លូវហ្នឹង គឺដើរមកអើតនៅក្នុងគុកនេះឯង ក្រែងមានអ្នកជំងឺ ដល់ដើរមកប្រទះឡានគេមកដល់ទៅក៏ខ្ញុំថយទៅវិញទៅ ឯចំណែកបងខ្ញុំ ក៏ឈរនៅយាមផ្លូវខាងមុខ ។ ដល់ខ្ញុំលួចមើលពីក្រោយបងទៅ គេបណ្តើរអ្នកទោសចុះពីលើឡាន ។ ដល់ខ្ញុំក្រឡេកទៅ ខ្ញុំឃើញឪពុក ។

**ស៖** លោកស្រីទៅធ្វើការនៅទីនោះ លោកស្រីរស់នៅកន្លែងណា? នៅទីនោះ ឬក៏ទៅនៅម្តាយឪពុករបស់លោកស្រី?

**ឆ៖** ខ្ញុំធ្វើការនៅទីនោះ គឺខ្ញុំរស់នៅទីនោះ ។ ខ្ញុំរស់នៅជាមួយពួកពេទ្យទាំងអស់គ្នា នៅមុខគុកទួលស្លែងនេះតែម្តង ។

[១៤:១០:៥៥]

**ស៖** ចុះ ពេលដែលគេចាប់ឪពុកមក ដែលលោកស្រីឃើញថា គេបញ្ជូនចូលទៅក្នុងគុកហ្នឹង គេដឹកឡានយកមកដល់កន្លែងច្រកចូលហ្នឹងតែម្តង ឬក៏គេបណ្តើរឲ្យគាត់ធ្វើដំណើរដោយថ្មើរជើងទេ ពេលដែលមកកាត់កន្លែងដែលលោកស្រីនៅធ្វើការ ហើយលោកស្រីបានក្រឡេកទៅឃើញឪពុកនោះ?

**ឆ៖** គឺឯខ្ញុំក្រឡេកឃើញនោះ គឺឡាននោះគេបើកចូលជិតទៅដល់ជិតកន្លែងជណ្តើរគាត់ឡើងទៅ ហើយចុះពីលើឡានវិញបានឃើញម្តង គេអត់មានបណ្តើរពីក្រៅទៅផង ឡានចូលទៅដល់កន្លែងម្តង។

**ស៖** លោកស្រីឃើញគេបញ្ជូនឪពុករបស់លោកស្រីទៅកាន់មន្ទីរ ទៅកន្លែងអគារឃុំឃាំងហ្នឹង គឺយ៉ាងម៉េចទៅ?

**ឆ៖** បន្តបន្ទាប់ទៀត ខ្ញុំឃើញឪពុកខ្ញុំ គេចាប់សម្រាតខោអាវគាត់ គេធ្វើទារុណកម្មគាត់យ៉ាងធ្ងន់ហើយខ្ញុំតាំងពីហ្នឹងមក គឺខ្ញុំបាក់ស្មារតី ខ្ញុំធ្វើការលែងកើត ។

**ស៖** គេធ្វើទារុណកម្មគាត់ ដោយពេលដែលគេស្រាតខោអាវ ពេលដែលចាប់ចូលមកដល់ភ្លាម គេស្រាតខោអាវហ្នឹង ឬក៏ឃើញគេធ្វើទារុណកម្មនៅពេលណាផ្សេងណាពីពេលដែលចាប់មកដល់?

**ឆ៖** គេចាប់មកដល់ គេអត់ទាន់ធ្វើអីទេ គាត់សម្រាកហ្នឹងរំលងពីរបីថ្ងៃ បានខ្ញុំអាចឃើញគាត់បាន ព្រោះអីខ្ញុំដើរឡើងទៅព្យាបាល ហើយខ្ញុំក៏បានឃើញអ្នកទោសទាំងអស់នោះ ហើយខ្ញុំសួរថា អ្នកទោសទាំងអស់នោះ គេថាសុទ្ធតែកម្មាភិបាល ។ ហើយបន្ទប់មួយនោះសុទ្ធតែកម្មាភិបាល ហើយខ្ញុំថា អ៊ីចឹងបន្ទប់ហ្នឹង ឪពុកខ្ញុំហើយ ។ ខ្ញុំចូលទៅក៏ឃើញ ។

**ស៖** អ៊ីចឹងពេលដែលលោកស្រីឃើញហ្នឹង គឺឃើញគេចាប់ឪពុកហ្នឹង ដែលទាញចុះពីឡានមក ហើយក៏បញ្ជូនដាក់ឃុំឃាំងតែម្តង ហើយក្រោយមកបានគេដោះសម្លៀកបំពាក់គាត់ចេញ អ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយ ។

**ស៖** ចុះឃើញគេដកស្រង់នូវប្រវត្តិរូបរបស់គាត់ ឬមួយក៏ដែលថតរូបគាត់ទេ មុននឹងបណ្តើរគាត់ទៅដាក់អគារឃុំឃាំងនោះ?

**ឆ៖** កាលនោះឡើយខ្ញុំអត់បានឃើញគេថតទេ ទើបតែបច្ចុប្បន្ននេះ ខ្ញុំទៅរករូបថតទៅ ខ្ញុំឃើញនៅក្នុងគុកទួលស្លែងនេះទាំងអស់ ហើយគេដាក់ជាអក្សរទៀត ។

**ស៖** លោកស្រីចាំទេថា ឪពុករបស់លោកស្រីហ្នឹងត្រូវគេឃុំឃាំងនៅអគារណាមួយ ហើយនៅជាន់ទីប៉ុន្មាន?

**ឆ៖** ឪពុកខ្ញុំគេឃុំឃាំងនៅជាន់ទីពីរ អគារពិសេស នៅក្នុងអគារនោះសុទ្ធតែកម្មាភិបាលទាំងអស់ គ្មានប្រជាជនណាដែលអាចនៅដាក់គុកនៅទីនោះបានទេ ហើយឪពុកខ្ញុំបានប្រាប់ខ្ញុំថា កុំឱ្យខ្ញុំស្គាល់គាត់ តែប៉ុណ្ណឹង ខ្ញុំលែងជួបទៅ ។

[១៤:១៥:០៦]

**ស៖** អគារពិសេសហ្នឹង អគារនៅកន្លែងណាមួយដែលលោកស្រីបញ្ជាក់ថា អគារពិសេសហ្នឹង អគារដែលលោកស្រីមើលការខុសត្រូវ អ្នកជំងឺអ្នកទោសហ្នឹង ឬក៏អគារផ្សេងទេ?

**ឆ៖** អគារដែលខ្ញុំមើលហ្នឹងហើយ ប៉ុន្តែនៅខាងចុងគឺអគារពិសេសរបស់កម្មាភិបាល ។

**ស៖** នៅជាន់ទីប៉ុន្មានដែរ?

**ឆ៖** ឯចំណែក ឪពុកខ្ញុំដល់ពេលនេះទៅ គេយកដាក់គាត់ទីបីលើគេបំផុត មានគ្នាប្រាំនាក់នៅក្នុងបន្ទប់នោះទៀត ។

**ស៖** លោកស្រីបាននិយាយថា ឪពុករបស់លោកស្រីហ្នឹងត្រូវបានគេសម្លាប់ តើគេនាំទៅសម្លាប់នៅកន្លែងណា?

**ឆ៖** ឪពុកខ្ញុំៗអត់បានឃើញជាកន្លែងសម្លាប់ទេ ប៉ុន្តែគេបញ្ជាបងខ្ញុំនេះឲ្យវ៉ៃឪពុកខ្ញុំ គឺសម្លាប់តែម្តង ។

**ស៖** គេបញ្ជាបងរបស់លោកស្រីណាមួយ ក្នុងចំណោមពីរនាក់ដែលធ្វើការនៅក្នុងមន្ទីរ ដែលលោកស្រីអះអាងថា ធ្វើការនៅមន្ទីរស-២១ជាអ្នកសម្លាប់ឪពុករបស់លោកស្រី ដោយផ្ទាល់ដៃនោះ?

**ឆ៖** គឺបងទីមួយរបស់ខ្ញុំឈ្មោះ នឿន ដែលគាត់សម្លាប់ឪពុករួច គឺគេក៏វ៉ៃគាត់ជាបន្តជាមួយឪពុកខ្ញុំតែម្តង ។

**ស៖** លោកស្រីមិនដឹងថា គេនាំឪពុករបស់លោកស្រីទៅសម្លាប់នៅកន្លែងណាទេ ហេតុផលយ៉ាងម៉េចទៅដែលនាំឲ្យលោកស្រីដឹងថា គេបានបញ្ជាបងរបស់លោកស្រីឈ្មោះ នឿន ឲ្យសម្លាប់ឪពុករបស់លោកស្រី?

**ឆ៖** គឺខ្ញុំអត់បានទៅអើតឪពុកខ្ញុំទេ តាំងពីហ្នឹងមក ប៉ុនមិត្តលន ដែលធ្វើពេទ្យជាមួយខ្ញុំនោះ គេអាចដឹងគេយកមកប្រាប់ខ្ញុំថា បងខ្ញុំនេះទៅវ៉ៃឪពុកស្លាប់ទៅហើយ ហើយគេសម្លាប់បងខ្ញុំតទៅទៀត ។

**ស៖** អ៊ីចឹងលោកស្រីហ្នឹងឮតាម មិត្តលន ដែលជាពេទ្យធ្វើការជាពេទ្យ ធ្វើការជាមួយនឹងលោកស្រីនិយាយប្រាប់ទេ ។ លោកស្រីមិនបានមើលឃើញដោយផ្ទាល់ភ្នែកទេ ពិតអ៊ីចឹងមែនទេ?

**ឆ៖** ឪពុកខ្ញុំគឺពិតហើយ ។ បើខ្ញុំមើលឃើញៗតែគេវ៉ៃពួខ្ញុំទេ រឿងឪពុកខ្ញុំ ខ្ញុំមើលអត់ឃើញទេ បងខ្ញុំហ្នឹងគ្រាន់តែគេមកប្រាប់ខ្ញុំពេលដែលវ៉ៃហ្នឹង ប៉ុន្តែខ្ញុំអត់បានទៅជួប ។

[១៤:១៨:២៤]

**ស៖** យើងចង់ដឹងថា លោកស្រីគឺដឹងហ្នឹងដោយសារ មិត្តលន ដែលធ្វើពេទ្យជាមួយហ្នឹងលោកស្រីហ្នឹងជាអ្នកនិយាយប្រាប់ដល់លោកស្រី អំពីហេតុការណ៍ដែលគេបានប្រើបងរបស់លោកស្រីឈ្មោះ នឿន ឲ្យវាយសម្លាប់ឪពុករបស់លោកស្រី ។ អ៊ីចឹងមែនទេ?

**ឆ៖** ពិតអ៊ីចឹងមែន ។

**ស៖** លោកស្រីមានបានសួរនាំគាត់ទេថា ហេតុយ៉ាងដូចម្តេចបានជាឈ្មោះ លន ហ្នឹងបានដឹងឃើញអំពីហេតុការណ៍ដែលថាគេបញ្ជាឲ្យបងរបស់លោកស្រីឈ្មោះ នឿន ជាអ្នកសម្លាប់ឪពុករបស់ខ្លួនឯងនោះ? ឮគាត់និយាយអំពីមូលហេតុដែលនាំឲ្យគាត់បានឃើញ បានដឹងអំពីរឿងហេតុនេះដែរឬទេ?

**ឆ៖** ព្រោះ មិត្តលន គាត់បានឃើញនោះ ដែលគាត់ចេញទៅព្យាបាលនៅពេលយប់ នៅពេលម៉ោងប្រាំមួយ-ប្រាំពីរ នេះ ។ រួចដល់ពេលទៅៗ គាត់ទាន់ហេតុការណ៍នេះក៏គាត់មកប្រាប់ខ្ញុំទាំងយប់វិញដែរ ប៉ុន្តែខ្ញុំពុកខ្ញុំអត់ឲ្យខ្ញុំស្គាល់ អត់ឲ្យខ្ញុំឃើញ អត់ឲ្យឮឈ្មោះ គឺខ្ញុំគឺអត់បានទៅៗ ។

**សៈ** អ៊ីចឹងបានសេចក្តីថា ការសម្លាប់ដែលគេប្រើបងរបស់លោកស្រីឈ្មោះ នឿន ឲ្យសម្លាប់ឪពុកខ្លួនឯងបង្កើតហ្នឹង គឺសម្លាប់នៅក្នុងអគារនៃមន្ទីរស-២១ ហ្នឹងតែម្តងបានជាឈ្មោះ លន ហ្នឹងបានឃើញ? ឬក៏យ៉ាងម៉េច?

**ឆ៖** គឺសម្លាប់នៅក្នុងគុកហ្នឹងតែម្តង នៅខាងក្រោយគុក នៅក្រៅរបងគុកហ្នឹងតែម្តង ។

**សៈ** សម្លាប់ហ្នឹងនៅពេលប្រហែលជាម៉ោងប៉ុន្មានទៅ?

**ឆ៖** តាមគេមកប្រាប់ខ្ញុំនោះ បើគេសម្លាប់ហ្នឹងតាំងពីម៉ោងប្រាំមួយ-ប្រាំពីរហ្នឹងម្ល៉េះ ព្រោះគេមកប្រាប់ខ្ញុំម៉ោងប្រាំពីរ ទៅហើយ ។

**សៈ** ចុះបងលោកស្រីដែលថា គេបញ្ជាឲ្យសម្លាប់ឪពុករួចហើយ គេសម្លាប់គាត់ដែរឈ្មោះ នឿន ហ្នឹង ។ តើលោកស្រីដឹងថា គេសម្លាប់ភ្លាមក្រោយពីគាត់សម្លាប់ឪពុករបស់គាត់ ឬក៏មានការឃ្លាតពេលវេលាមួយថ្ងៃពីរថ្ងៃក្រោយ បានគេសម្លាប់បងរបស់លោកស្រីឈ្មោះ នឿន?

**ឆ៖** គឺបងខ្ញុំឈ្មោះ នឿន នេះ គឺសម្លាប់ឪពុកខ្ញុំរួច គឺគាត់ទៅនៅធ្វើការធម្មតា រំលងបីថ្ងៃបានគេហៅគាត់ទៅ ។

[១៤:២១:៤៩]

**សៈ** គេហៅគាត់ទៅភ្លាម ទៅសម្លាប់ភ្លាម ឬក៏គេយកទៅគាត់ទៅឃុំឃាំងនៅកន្លែងណា?

**ឆ៖** យកទៅហ្នឹង គឺគេសម្លាប់តែម្តង គេអត់មានឃុំឃាំងផង គេថាបងខ្ញុំហ្នឹងក្បត់ ។ ឲ្យវ៉ៃពុកខ្ញុំហើយអត់ចង់វ៉ៃ ថាបងខ្ញុំក្បត់ ។

**សៈ** លោកស្រីដឹងថា គេនាំបងរបស់លោកស្រីឈ្មោះ នឿន ហ្នឹងទៅសម្លាប់នៅកន្លែងណាទេ ពីព្រោះលោកស្រីក៏ធ្វើការ អះអាងថាធ្វើការនៅស-២១ ដែរ ហើយអាចដឹងរឿងច្រើន ។ តើដឹងថា គេនាំបងរបស់លោកស្រីឈ្មោះ នឿន ហ្នឹងទៅសម្លាប់នៅកន្លែងណា?

**ឆ៖** គឺបងរបស់ខ្ញុំ ព្រមទាំងឪពុក ព្រមទាំងម្តាយទាំងអស់ គឺស្លាប់នៅទួលស្លែងតែមួយ អត់មានបញ្ជូនទៅព្រៃស ឬមួយឯណាគឺអត់មាន ។

**ស៖** ទួលស្លែងហ្នឹងមានកន្លែងច្រើន កន្លែងដែលជាកន្លែងសម្លាប់នុងមានកន្លែងសម្លាប់ជាឯកជនម្នាក់ៗ សម្លាប់ជារណ្ដៅកប់សពរួម មានទាំងក្នុងបរិវេណ មានទាំងខាងក្រៅបរិវេណ មានទាំងទិសខាងលិច ទិសខាងជើង ហើយនិងខាងត្បូងនៃមន្ទីរសន្តិសុខស-២១ ដែលបច្ចុប្បន្នគេស្គាល់ជាទូទៅហៅគុកទួលស្លែងនោះ ។ អ៊ីចឹងហើយបានជាយើងសួរថា តើការសម្លាប់ហ្នឹងប្រព្រឹត្តទៅនៅកន្លែងណាជាក់លាក់ ពីព្រោះនៅក្នុងការចំណាប់អារម្មណ៍ក៏ដូចជាពាក្យសរសេររបស់លោកស្រី ក្នុងការប្ដឹងទាមទារគឺមានការកំណត់អំពីការភាពច្បាស់លាស់នៃការសម្លាប់នេះ ។ អ៊ីចឹងហើយបានជាយើងសួរឲ្យបានច្បាស់លាស់ទៅតាមសេចក្ដីអះអាងរបស់លោកស្រីដើម្បីបញ្ជាក់ការពិត ។ លោកស្រីដឹងទេ កន្លែងណាច្បាស់លាស់? កន្លែងជាមួយគ្នានឹងកន្លែងសម្លាប់ឪពុករបស់លោកស្រី ឬក៏កន្លែងផ្សេងពីកន្លែងដែលគេបញ្ជាឲ្យបងរបស់លោកស្រី សម្លាប់ឪពុករបស់លោកស្រីនោះ?

**ឆ៖** គឺខ្ញុំអត់ដឹងកន្លែងណាដែរ ប៉ុន្តែខ្ញុំដឹងថាសម្លាប់នៅក្នុងគុកទួលស្លែងនេះតែម្ដង ។ បើកន្លែងគឺខ្ញុំអត់ដឹង ។

**ស៖** ហេតុផលយ៉ាងម៉េចទៅដែលនាំឲ្យលោកស្រី អះអាងថាឪពុកលោកស្រី ហើយបងលោកស្រីហ្នឹង គឺត្រូវគេសម្លាប់នៅក្នុងគុកទួលស្លែងនោះតែម្ដង?

**ឆ៖** គឺខ្ញុំបានដឹង បានឮ បានឃើញ ឮទាំងត្រចៀក ហើយខ្ញុំក៏មិនបានឃើញគេវៃគាត់នោះដែរ ប៉ុន្តែដឹងថាគេនាំទៅសម្លាប់នៅហ្នឹងគុកហ្នឹងតែម្ដង ។ ប៉ុន្តែ មិនដឹងកន្លែងណា ព្រោះអង្គាល់សម្លាប់គាត់គឺអត់មានឡានចេញចូលផង ។

[១៤:២៥:២១]

**ស៖** លោកស្រីរកនឹកឡើងវិញមើល៍ ពីពេលចាប់ឪពុកលោកស្រីហ្នឹង ថ្ងៃចាប់ឪពុកលោកស្រីរហូតដល់លោកស្រីអះអាងថា គេសម្លាប់ហ្នឹងឃ្លាតគ្នាប្រហែលជាប៉ុន្មានដែរទៅ? ប៉ុន្មានខែប៉ុន្មានថ្ងៃ?

**ឆ៖** ឪពុកខ្ញុំគេចាប់យកមកដាក់ ការឃុំឃាំងបាន៦ខែ ។ នៅឆ្នាំ១៩៧៧ ហ្នឹងគេចាប់បាន៦ខែបានគេសម្លាប់គាត់ ។

**ស៖** ចុះបងលោកស្រីម្នាក់ទៀតឈ្មោះ នឿន ជោគវាសនារបស់គាត់យ៉ាងម៉េចដែរ?

**ឆ៖** ឈ្មោះ នឿន ។ ឈ្មោះ រឿន ឬអីបង ស្ដាប់អត់បាន ។

**ស៖** ហ្នឹងហើយឈ្មោះ រឿន អំមិញឈ្មោះ នឿន រួចហើយ ឈ្មោះរឿន ណ៎ា ។

**ឆ៖** ឯចំណែក បង រឿន ដែលគាត់នៅនេះ គឺចាប់បន្តបន្ទាប់តែគ្នាហ្នឹង គ្មាននរណារស់នៅបានទេ គ្រាន់តែគេយកមុនហើយនិងក្រោយទាំងអស់ ។

**ស៖** លោកស្រីដឹងថា គេសម្លាប់បងរបស់លោកស្រីឈ្មោះ រឿន ហ្នឹងនៅថ្ងៃខែឆ្នាំណា? វេលាយប់ឬក៏ថ្ងៃ? សម្លាប់នៅកន្លែងណាដែរទេ?

**ឆ៖** ឯបងក្រោយហ្នឹង គឺខ្ញុំបានដឹងថា គេចាប់គាត់ដាក់ឃុំឃាំងនៅក្នុងគុកនោះ ស្រករអ្នកម្ដាយខ្ញុំ ហើយព្រមទាំងប្អូនខ្ញុំដែរ ។ អត់ដឹងជាសម្លាប់នៅថ្ងៃណា គឺខ្ញុំអត់ដឹង ។

**ស៖** ម្ដាយលោកស្រី ឈ្មោះរឿន ហើយនិងប្អូនរបស់លោកស្រីពៅគេឈ្មោះ យ៉ុន អ៊ីចឹងអ្ហេ? តើចាប់នៅក្នុងអំឡុងពេលដែលឪពុករបស់លោកស្រី កំពុងតែជាប់ឃុំឃាំង ឬក៏ចាប់ក្រោយពេលដែលគេសម្លាប់ឪពុក និងបងរបស់លោកស្រីឈ្មោះ នឿន រួចហើយ ទើបចាប់ម្ដាយរបស់លោកស្រី ហើយបងរបស់លោកស្រីឈ្មោះ រឿន ហើយនិងឈ្មោះ យ៉ុន ជាក្រោយ?

**ឆ៖** ចាប់ពុកខ្ញុំទៅ ប៉ុន្តែគេអត់ទាន់សម្លាប់ទេ គឺចាប់ម្ដាយខ្ញុំទៅទៀត ទៅចាប់ម្ដាយខ្ញុំរយៈប្រហែលពីរខែ បានសម្លាប់ឪពុកខ្ញុំ ហើយព្រមទាំងម្ដាយខ្ញុំ គេសម្លាប់ក្រោយពុកខ្ញុំបន្តិច ។

**ស៖** ចុះប្អូនម្នាក់ទៀតឈ្មោះ ប្រាក់ យ៉ុន នុ៎ងគេចាប់នៅពេលណា?

**ឆ៖** ប្រាក់ យ៉ុន ហ្នឹងរួមរស់នៅជាមួយម្ដាយខ្ញុំ ចាប់ជាមួយថ្ងៃជាមួយតែម្ដាយខ្ញុំទាំងអស់តែម្ដង ។

**ស៖** ហើយលោកស្រីធ្វើការនៅទីនោះ តើបានទទួលព័ត៌មានថាម្ដាយរបស់លោកស្រី និងប្អូនពៅរបស់លោកស្រីហ្នឹងត្រូវគេសម្លាប់នៅថ្ងៃខែឆ្នាំណាដែរ?

ហើយបើធៀបជាមួយនឹងឈ្មោះ រឿន បងឈ្មោះ រឿន ហ្នឹង តើគេសម្លាប់នៅពេលជាមួយគ្នាឬក៏ពេលមុនក្រោយគ្នាយ៉ាងម៉េច?

[១៤:២៩:៤៤]

**ឆ៖** គឺម្ដាយខ្ញុំ និងបងខ្ញុំហ្នឹង គឺសម្លាប់មុនក្រោយ ។ សម្លាប់ម្ដាយខ្ញុំរួច បានគេយកបងខ្ញុំទៅសម្លាប់ជាក្រោយ ។ ហើយយើងខ្ញុំតាំងពីនោះមក ម្ដាយខ្ញុំស្លាប់ជិតដាច់ឆ្នាំ៧៧ ហើយគេសម្លាប់គាត់ ។ បន្ទាប់មកពីនោះមកខ្ញុំ ដល់សម្លាប់ម្ដាយខ្ញុំរួចបានប្រហែលរយៈមួយខែ គឺគេចាប់ខ្ញុំឃុំឃាំងតែម្ដង ។

**ស៖** អ៊ីចឹងម្ដាយលោករបស់លោកស្រីក៏ត្រូវគេសម្លាប់ ហើយប្អូនពៅក៏គេសម្លាប់ដែរអ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយ អ៊ីចឹងមែន ។

**ស៖** បានន័យថា គេសម្លាប់នៅកន្លែងដែលលោកស្រីអះអាងថា គេឃុំឃាំងចាប់គ្រួសាររបស់លោកស្រីទៅឃុំឃាំងហ្នឹងមានទីមួយ ឪពុករបស់លោកស្រី ឈ្មោះ ចួន យ៉ន ហៅ យ៉ុត ប្រាក់ ។ ទីពីរម្ដាយរបស់លោកស្រី ឈ្មោះ ខិន គុះ ហៅ សាន ហើយទីបីឈ្មោះ យិត នឿន, យិត រឿន, យិត ខឿន ហើយនិង ប្រាក់ យ៉ុន ។ អ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយ អ៊ីចឹងមែន ។

**ស៖** លោកស្រីចាំទេ ពេលដែលគេចាប់លោកស្រី តើគេចាប់លោកស្រីនៅថ្ងៃខែឆ្នាំណា? ហើយនាំលោកស្រីដែលលោកស្រី អះអាងថាយកលោកស្រីទៅឃុំឃាំងហ្នឹង គេឃុំឃាំងលោកស្រីនៅកន្លែងណាដែរ?

**ឆ៖** យើងខ្ញុំចាប់ គេចាប់ខ្ញុំនៅដើមឆ្នាំ១៩៧៨។ ខ្ញុំជាប់គុកនៅគុកទួលស្លែងនេះបានរយៈបីខែគេយកខ្ញុំទៅឃុំនៅបន្ទប់តូចមួយខាងលើជាន់ពីរជាន់ ។ គេដាក់ខ្នោះជើងម្ខាង ។

**ស៖** ឃុំខ្លួនលោកស្រីនៅអគារណាដែរ? ជាន់ទីប៉ុន្មាន?

**ឆ៖** នៅជាន់ទីមួយបន្ទប់តូច អគារបណ្ដោយថ្ងៃ ។

**ស៖** អគារដែលលោកស្រីមើលការខុសត្រូវអ្នកទោសមានជំងឺ ក៏ដូចជាអគារឃុំឃាំងដែលលោក ស្រីអះអាងថា គេឃុំឃាំងឪពុករបស់លោកស្រីហ្នឹងពិតមែនដែរឬទេ ? ឬក៏អគារផ្សេង?

**ឆ៖** គឺអគារហ្នឹងពិតមែនហើយ ។ ប៉ុនមានបន្ទប់តែមួយៗទេ អគារនៅមួយជាន់នេះ មានតែពីរបន្ទប់បីបន្ទប់ប៉ុណ្ណោះឯង ។

**ស៖** លោកស្រីក្នុងលក្ខណៈដែលរស់នៅក្នុងការឃុំខ្លួនបីខែ ដែលលោកស្រីអះអាងនេះតើគេដាក់ខ្នោះលោកស្រីទេ? ឬក៏គេមិនបានដាក់ខ្នោះទេ គេគ្រាន់តែបិទទ្វារចាក់សោរពីខាងក្រៅបន្ទប់ដែលគេឃុំឃាំងលោកស្រីនោះ?

[១៤:៣៣:៥២]

**ឆ៖** ដែលពេលចាប់ខ្ញុំគឺដាក់ខ្នោះជើង ពេលសួរចម្លើយខ្ញុំគឺវាអត់វាយនឹងរំពាត់ទេ វារឹតនឹងខ្នោះជើងតែម្ដង ។

**ស៖** អ៊ីចឹងបានន័យថា ក្នុងអំឡុងពេលបីខែដែលគេឃុំឃាំងលោកស្រីហ្នឹងគឺ គេដាក់ខ្នោះជើង ដាក់ជើងលោកស្រីជាប់ខ្នោះជាអចិន្ត្រៃយ៍ ។ អ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងពិតមែន ។

**ស៖** ហើយការដាក់ឃុំឃាំងហ្នឹង គឺក្នុងបន្ទប់មួយតូចតែម្នាក់ឯងទេ ។ អ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែនហើយ ។

**ស៖** ចុះពេលដែលគេនាំទៅសួរចម្លើយ សំណួរសួរថា តើគេសួរចម្លើយនៅកន្លែងបន្ទប់ដែលគេឃុំឃាំងលោកស្រីនៅនោះតែម្ដង ឬក៏គេនាំលោកស្រីទៅសួរចម្លើយនៅទីកន្លែងណា?

**ឆ៖** ពេលគេសួរចម្លើយគឺអត់យកខ្ញុំទៅណាទេ គឺនៅនុ៎ង ប៉ុនគេរឹតជាខ្នោះនៅក្នុងនុ៎ងបន្តិចម្ដងៗឲ្យខ្ញុំឆ្លើយ ។

**ស៖** អ្នកសួរចម្លើយលោកស្រីហ្នឹងមានមនុស្សប៉ុន្មាននាក់? ហើយជាមនុស្សប្រុស ឬក៏ជាស្ត្រី?

**ឆ៖** អ្នកសួរចម្លើយខ្ញុំនោះគឺមនុស្សប្រុស មានគ្នាពីរនាក់ ម្នាក់ឈរ ម្នាក់អង្គុយសួរ ។ ប៉ុនមិនដឹង គេរឹតហ្នឹងស្អីទេ ដាច់ជើងខ្ញុំរដាច់រដោចរលីង ។

**ស៖** លោកស្រីជាមនុស្សធ្វើការនៅទីនោះ តើលោកស្រីស្គាល់ទេ ស្គាល់អ្នកដែលសួរចម្លើយលោកស្រីដែរឬទេ? ពីព្រោះលោកស្រីអះអាងថា ជាបុគ្គលិកធ្វើបំរើការងារនៅទីនោះ?

**ឆ៖** គឺអ្នកទៅសួរចម្លើយយើងខ្ញុំនោះ គឺខ្ញុំមិនអាចស្គាល់បានទេ ព្រោះគេចូលថ្មីជាបន្តបន្ទាប់ ។ គឺអ្នកយាមគឺ ផ្លាស់ប្ដូរគ្នាជាប់ជានិច្ច ។

**ស៖** វ័យអាយុស្រករអាយុអ្នកដែលសួរចម្លើយលោកស្រីហ្នឹង អាយុប្រហែលជាប៉ុន្មានឆ្នាំទៅ?

**ឆ៖** (ឮមិនច្បាស់) តែប៉ុននុ៎ងឯង ។

**ស៖** លោកស្រីនិយាយម្ដងទៀត កុំអាលនិយាយចាំដល់ពេលមានភ្លើងក្រហមសឹមនិយាយណា និយាយឆ្លើយអំមិញម្ដងទៀត ព្រោះខាងអន្តរជាតិអត់ឮទេ ព្រោះអត់បានបកប្រែ ។

[១៤:៣៦:៤៣]

**ឆ៖** អ្នកសួរចម្លើយខ្ញុំនោះប្រហែលជាអាយុ ២០ ទៅ ២១ឆ្នាំតែប៉ុណ្ណោះ ។

**ស៖** គេសួរចម្លើយលោកស្រីប៉ុន្មានលើក? អំឡុងពេលដែលលោកស្រីជាប់ឃុំឃាំងរយៈពេលប្រហែលជាបីខែនោះ?

**ឆ៖** ថ្ងៃខ្លះទៅ គេសួរខ្ញុំមួយថ្ងៃពីរដង ថ្ងៃខ្លះគេសួរខ្ញុំមួយថ្ងៃបីដង សួររៀងរាល់ថ្ងៃ ។

**ស៖** គេសួរលោកស្រី សួរចម្លើយលោកស្រីប្រហែលជាប៉ុន្មានដងសរុបទៅ ឬក៏ប្រហែលជាប៉ុន្មានថ្ងៃ?

**ឆ៖** ខ្ញុំជាប់គុករយៈបីខែនេះ គេសួរប្រហែលជាកន្លះខែតែប៉ុណ្ណោះទេ គេអាចសួរជាប់ចំពោះរូបខ្ញុំ ។

**ស៖** សួរក្នុងអំឡុងពេលទាំងកន្លះខែ ប្រហែលជាកន្លះខែនោះ គឺគេសួរនៅហ្នឹងក្នុងបន្ទប់ដែលឃុំឃាំងតែម្តងដោយមិននាំទៅសួរកន្លែងផ្សេងទេ ។ អ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងពិតមែនហើយ ។

**ស៖** នៅក្នុងការសួរចម្លើយ បំណងនៃការសួរចម្លើយនេះ គេសួរសង្កត់លើចំណុចលើបញ្ហាអ្វីខ្លះទៅដែលគេចង់ឲ្យលោកស្រីឆ្លើយនោះ ចង់ឲ្យឆ្លើយពីបញ្ហាអ្វីខ្លះទៅ?

**ឆ៖** ដែលគេសួរឲ្យខ្ញុំឆ្លើយនឹង គេចោទខ្ញុំថាខ្ញុំហ្នឹងកូនក្បត់ ថាអ្នកក្បត់ ថាគេដឹងខ្ញុំថា ខ្ញុំកូនឈ្មោះ ប្រាក់ អ៊ីចឹង ។ ទៅខ្ញុំប្រកែកគេ ថាខ្ញុំមិនមែនទេ គាត់អ្នកនាំខ្ញុំចូលទេ ។ គេសង្កត់អ៊ីចឹងគេអាចរឹតខ្នោះខ្ញុំ។

**ស៖** អ៊ីចឹង គ្រប់ពេលដែលគេសួរចម្លើយលោកស្រីហ្នឹង គឺគេប្រើវិធីតែដដែលៗហ្នឹង គឺគេប្រើប្រដាប់ម្យ៉ាងហ្នឹងគឺរឹត ចាប់រឹតខ្នោះដែលគេដាក់ជើងលោកស្រីហ្នឹងឲ្យតឹងទៅ ដើម្បីឲ្យលោកស្រីឈឺ ។ អ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងពិតមែន ។

**ស៖** ក្នុងអំឡុងពេលដែលលោកស្រីអះអាងថា បានត្រូវបានគេចាប់ខ្លួនដោយសារមូលហេតុមានជាប់ឪពុកជាខ្មាំង ជាជនក្បត់អ៊ីចឹង តើក្នុងពេលឃុំឃាំងហ្នឹងរបបហូបចុក របស់លោកស្រីហ្នឹងគេផ្តល់ឲ្យយ៉ាងម៉េចដែរ?

[១៤:៣៩:៥៨]

**ឆ៖** ឲ្យខ្ញុំហូបបបរមួយថ្ងៃមួយវែក ព្រឹកល្ងាច ព្រឹកមួយវែក ល្ងាចមួយវែកតែប៉ុណ្ណោះ ។

**ស៖** ចុះងូតទឹកគេឲ្យងូតទឹកយ៉ាងម៉េចដែរ?

**ឆ៖** រឿងទឹករឿងអីគេហៅងូតដែរ តែខ្ញុំអត់ងូតទេ ខ្ញុំអត់ចង់ងូតតែម្តង ព្រោះនៅក្នុងខ្នុំងវាឈឺណាមួយជើងខ្ញុំដើរវាមិនចង់រួចផង ម្ល៉ោះហើយខ្ញុំអត់បានទៅងូត ។

**ស៖** នៅក្នុងបន្ទប់ឃុំឃាំងហ្នឹង លោកស្រីអាចអង្គុយបានដែរឬទេ? ឬក៏ឈរបានដែរឬទេ? ឬក៏ដេករហូត?

**ឆ៖** គឺខ្ញុំនៅបន្ទប់ឃុំឃាំងហ្នឹងខ្ញុំអាចអង្គុយបាន ឈរក៏បាន សម្រាកក៏បានអត់អីទេ ។

**ស៖** នៅបន្ទប់ក្បែរលោកស្រីហ្នឹងតើលោកស្រីដឹងថា នៅបន្ទប់ក្បែរៗជាប់ហ្នឹងលោកស្រីហ្នឹងជាបន្ទប់ឃុំឃាំង ឬក៏ជាកន្លែងអ្វីដែរទេ? ហើយបើជាបន្ទប់ឃុំឃាំងតើជាបន្ទប់ឃុំឃាំងស្ត្រីដែរ ឬក៏ជាបន្ទប់ឃុំឃាំងមនុស្សបុរស?

**ឆ៖** គឺនៅក្បែរនោះគឺខ្ញុំឃុំឃាំងនោះគឺមិនដឹងស្រី មិនដឹងប្រុសទេ ប៉ុន្តែខ្ញុំគ្រាន់តែដឹងថា បន្ទប់មួយៗ សុទ្ធតែដាក់អ្នកទោសទាំងអស់ ។

**ស៖** ចុះសំលៀកបំពាក់លោកស្រីប្រើប្រាស់ហ្នឹងក្នុងអំឡុងពេលដែលគេឃុំឃាំងហ្នឹងប្រើប្រាស់យ៉ាងម៉េចទៅសំលៀកបំពាក់របស់លោកស្រី?

**ឆ៖** គឺសំលៀកបំពាក់ខ្ញុំ តាំងពីគេដាក់ខ្នោះជើងថ្ងៃណាឡើង ខ្ញុំមិនដែលផ្លាស់ខោអាវទេ ។

**ស៖** សំលៀកបំពាក់លោកស្រីហ្នឹងពណ៌យ៉ាងម៉េចដែរ ដែលលោកស្រីស្លៀកពាក់នៅក្នុងអំឡុងពេលដែលលោកស្រីជាប់ឃុំឃាំងនោះ?

**ឆ៖** ដែលខ្ញុំសំលៀកបំពាក់ខ្ញុំ ដែលគេចាប់ខ្ញុំឃុំឃាំង គឺខ្ញុំស្លៀកខ្មៅ សំពត់ក៏ខ្មៅអាវក៏ខ្មៅទាំងអស់ ។

**ស៖** សំលៀកបំពាក់ដែលលោកស្រីស្លៀកពាក់ហ្នឹង គឺជាសំលៀកបំពាក់ដែលលោកស្រីស្លៀកពាក់ធ្វើការក្នុងនាមលោកស្រីធ្វើជាបុគ្គលិកពេទ្យនៅទីនោះ ។ អ៊ីចឹងមែនទេ?

**ឆ៖** មិនមែនសំលៀកបំពាក់ដូចអង្កាល់ពីខ្ញុំនៅធ្វើពេទ្យ គឺខ្ញុំបានស្លៀកស្អាតបាតដល់ពេលខ្ញុំឈប់ធ្វើពេទ្យទៅ គឺខ្ញុំស្លៀកតែផាឌិបខ្មៅតែប៉ុណ្ណោះឯង ។

**ស៖** សំលៀកបំពាក់នុ៎ងបានពីណាមក?

**ឆ៖** សំលៀកបំពាក់ដែលខ្មៅគេចែកឲ្យអ្នកដែលដោះរួចពីឈប់ធ្វើពេទ្យធ្វើអីហ្នឹង គេបើកខោអាវឲ្យម្នាក់មួយកំប្លេៗហ្នឹង គឺគេឲ្យយើងជម្រះស្មៅដំបូងហ្នឹងគេបើកឲ្យ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចពិភាក្សាដេញដោលតទៅទៀត ។ មន្ត្រីតុលាការសម្របសម្រួលដើម្បីឲ្យ

លោកស្រី ណាំ ម៉ុន នឹងបានទទួលនូវកន្លែងសម្រាកសមរម្យ ។

*[សវនាការសម្រាកពីម៉ោង ១៤:៤៤នាទី ដល់ម៉ោង ១៥:០៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោល ។

មន្ត្រីផ្នែកខាងសោតទស្សន៍សូមបង្ហាញនូវឯកសាររូបភាព ដែលមានលេខ ERN00189137 ត្រូវនឹង D45/1/8 នៅលើកញ្ចក់ទូរទស្សន៍ ។

លោកស្រី ណាំ ម៉ុន ពិនិត្យមើលរូបភាពនៅនឹងកញ្ចក់ទូរទស្សន៍នេះ នេះជារូបភាពដែលការថត នឹង គឺថតពីលើមកក្រោម ។ លោកស្រីពិនិត្យមើល ហើយយើងនឹងសួរលោកស្រី ។ លោកស្រីមើលឃើញទេ?

មន្ត្រីតុលាការទៅជិតគាត់ ដើម្បីក្នុងការសួរអី នឹងអាចចង្អុល ។

អញ្ជើញមេធាវី មានបញ្ហាអីទៅ?

**លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមជម្រាបថាកូនក្តីរបស់ខ្ញុំ គឺគាត់អត់ចេះអានអ្វីទេ ។ សូមឲ្យលោកប្រធាន និងអង្គសវនាការធ្វើការពិចារណាទៅលើចំណុចនេះផង ។

**សួរដោយប្រធានអង្គជំនុំ៖**

(លោកមន្ត្រីតុលាការចង្អុលប្រាប់គាត់អំពី ច្រកចូល១ គឺចំណុចច្រកចូលនៃទួលស្លែង) ។

**ស៖** ហើយលោកស្រីចង្អុលមើល ថាតើកន្លែងការិយាល័យរបស់លោកស្រី ដែលអះអាងថាកន្លែងលោកស្រីធ្វើពេទ្យនៅមន្ទីរស-២១ បច្ចុប្បន្នដែលគេស្គាល់ទូទៅថា គុកទួលស្លែងហ្នឹង កន្លែងការិយាល័យពេទ្យនៅចំណុចណា?

**ឆ៖** ខ្ញុំនៅច្រកចូលតាមហ្នឹង ខ្ញុំចូលពីនេះទៅ គឺនៅស្តាំដៃ អគារបណ្តោយថ្ងៃ ។

**ស៖** ឈប់សិន! យើងសួរពីរឿងកន្លែងពេទ្យ កន្លែងលោកស្រីធ្វើការងារហ្នឹង នៅកន្លែងណា? កន្លែងធ្វើការ? កន្លែងបុគ្គលិក កន្លែងធ្វើពេទ្យដំបូងនៅកន្លែងណា?

**ឆ៖** អគារយើងខ្ញុំនៅធ្វើពេទ្យនេះ នៅពីមុខគុកហ្នឹងតែម្តង ។

**ស៖** ចុះចំណុចណាមួយ ដែលគេឃុំឃាំងឪពុកលោកស្រី?

**ឆ៖** គឺអគារអក្សរ “D” ។

[១៥:០៩:៥៦]

**ស៖** ចុះកន្លែងណាដែលគេឃុំឃាំងខ្លួនលោកស្រី?

**ឆ៖** ស្អី?

**ស៖** អាចៗមើលយល់ទេ?

(បានហើយ បើមិនយល់អាច-- មន្ត្រីសោតទស្សន៍អាចបង្វែររូបភាពមកធម្មតាឡើងវិញ) ។

**លោក តាន់ សេណារ៉ុង៖**

តំណាងអយ្យការសូមចង់ជូនយោបល់ដល់លោកប្រធានអង្គជំនុំជម្រះថា តើអាចយករូបភាពនេះ ដែលនៅក្នុង ដែលមាន ERN 00181356 បង្ហាញគាត់បានទេ ។ ហើយរូបភាពនេះវាអាចជាអគារ ដែលធ្វើឲ្យគាត់អាចចាប់រម្មណ៍ និងនឹងឃើញជាជាងរូបភាព ដែលមានអម្បាញ់មិញ ដែលលោកបាន បង្ហាញហ្នឹង ។

**ប្រធានអង្គជំនុំ៖**

អរគុណតំណាងសហព្រះរាជអាជ្ញា ប៉ុន្តែទុកចាំវេនលោកចុះ ។

**ស៖** អង្គជំនុំជម្រះសួរតទៀត ចុះបងលោកស្រីម្នាក់ទៀតឈ្មោះ យ៉ាត-- យៀត យឿន តើ ជោគវាសនារបស់គាត់យ៉ាងម៉េចដែរ យៀត យឿន? លោកស្រីដឹងទេ?

**សាក្សី ណាំ ម៉ុន៖**

**ឆ៖** យៀត យឿន ដែលគាត់ធ្វើការនៅជាមួយពូខ្ញុំ នៅឯរថយន្តកប៉ាល់ហោះនោះ ក៏គេចាប់ គាត់នោះដែរ ចាប់មកទាំងអស់ ហើយដឹកស្មៅ គឺទាំងឫស ទាំងអស់តែម្តង ។

**ស៖** គេចាប់យមកដាក់នៅកន្លែងឃុំខ្លួនជាមួយនឹងលោកស្រី ឬក៏ដាក់ជាមួយគ្រួសារលោកស្រី ដែរ ឬក៏ដាក់នៅកន្លែងណាផ្សេង?

**ឆ៖** នៅគុកតែមួយ ប៉ុន្តែបន្ទប់ដោយខ្លួន នៅអគារដោយខ្លួន មិនជាគេចាប់មកដាក់អគារមួយ ណា គឺខ្ញុំអត់ដឹងដែរ ។ ប៉ុន្តែថាឲ្យតែកូនកម្មាភិបាល គឺចូលគុកនេះទាំងអស់តែម្តង អត់មានបែងចែកទៅ គុកព្រៃសឯណាទៀត គឺអត់មាន ។

**ស៖** ចុះលោកស្រីក្រោយពីគេឃុំឃាំងអស់រយ:ពេលបីខែ នៅកន្លែងដែលលោកស្រីអះអាងថាជាមន្ទីរស-២១ ដែលបច្ចុប្បន្នហៅ គុកទួលស្លែងនោះ រួចគេបញ្ជូនលោកស្រីទៅទីកន្លែងណា? ហើយគេបញ្ជូនដោយមធ្យោបាយអ្វីដែរ? ទៅពេលយប់ ឬក៏ពេលថ្ងៃ?

**ឆ៖** ដើមឡើយគេបញ្ជូនខ្ញុំទៅនេះ ពេលល្ងាចថ្ងៃរសៀលទៅគុកព្រៃសនេះ ខ្ញុំរស់នៅហ្នឹងគុកព្រៃស ។ គេធ្វើទារុណកម្មរបស់ខ្ញុំយ៉ាងធ្ងន់ធ្ងរនៅក្នុងគុកព្រៃស នេះតែម្តង ។

[១៥:១៣:៤៩]

**ស៖** បញ្ជូនលោកស្រីចេញអ៊ីចឹង ដោយមធ្យោបាយអ្វីដែរ? ហើយមានដាក់ខ្នោះ មានរុំមុខដែរឬទេ?

**ឆ៖** បញ្ជូនខ្ញុំ-- ខ្ញុំចេញទៅនោះ គឺគេអត់រុំមុខទេ គេដាក់តែខ្នោះទេ គេហៅឡើងឡានទៅ ។

**ស៖** ការដែលគេបញ្ជូនទៅព្រៃសនោះ តើទៅតែលោកស្រីម្នាក់ឯង ឬក៏មានមនុស្សផ្សេងគេបញ្ជូនទៅជាមួយលោកស្រីដែរ?

**ឆ៖** ទៅនៅក្នុងឆ្នាំ១៩៧៨ នេះ គេបញ្ជូនទៅជាមួយខ្ញុំនេះ គឺមានប្រាំប្រាំមួយនាក់នៅលើឡាន ប៉ុន្តែខ្ញុំមិនអាចស្គាល់ឈ្មោះគេបានទេ ។

**ស៖** លោកស្រីគេបញ្ជូនទៅព្រៃសហ្នឹង ទៅចំណុចកន្លែងណាដែលលោកស្រីទៅរស់នៅទីនោះ? លោកស្រីស្គាល់ទេទីតាំងដែលលោកស្រីទៅដេក ទៅស្នាក់នៅឯព្រៃសនោះ?

**ឆ៖** គឺខ្ញុំទៅនៅមន្ទីរព្រៃស ទៅនៅក្នុងមន្ទីរជាមួយគេមានតែម្តង គឺខ្ញុំចាំណាំមិនបានទេ ព្រោះអីខ្ញុំកាលនោះឯង ព្រលឹមឡើង គឺគេឲ្យជីករណ្តៅកប់ខ្មោចបាត់ទៅហើយ ល្ងាចឡើងគេឲ្យខ្ញុំមកវិញ ។ ទាល់តែដល់គេបញ្ជូនខ្ញុំទៅគុកព្រៃទទឹងនោះ បានខ្ញុំធូរស្រាលបន្តិច ។

**ស៖** លោកស្រីស្គាល់អ្នកណាជាប្រធាននៅព្រៃសកាលនោះ ដែលលោកស្រីទៅដល់នោះ? ហើយប្រធានហ្នឹងប្រុស ឬក៏ស្រី?

**ឆ៖** គឺខ្ញុំទៅដល់ដំបូង គឺមានមិត្តស្រីម្នាក់ទទួល ឈរឃើញពួកខ្ញុំចុះពីលើឡាន ឃើញមិត្តស្រីម្នាក់ទទួល ។ ប៉ុន្តែដឹងថាគេប្រធាន គេមិនប្រធាន គឺខ្ញុំមិនដឹង ។ ឃើញតែបញ្ជាពួកខ្ញុំ មានតែមនុស្សប្រុសទេបញ្ជា ។

**ស៖** ប្រធានធំជាងគេនៅទីនោះ គាត់ជាមនុស្សប្រុស ឬមនុស្សស្រី? ហើយឈ្មោះអ្វីដែរ?លោកស្រីស្គាល់ទេ? ពាក្យថា“ស្គាល់ទេនេះ” បើមិនស្គាល់ឆ្លើយថាមិនស្គាល់ជាការចប់ មិនអាចឆ្លើយអ្នក

ផ្សេងមិនជំនួសនឹងសំណួរនេះបានទេ ។

**ឆ៖** គឺប្រធាននៅគុកនោះ គឺប្រធានប្រុស ប៉ុន្តែយើងខ្ញុំមិនស្គាល់ឈ្មោះគាត់បាន ។

**ស៖** កន្លែងលោកស្រីរស់នៅហ្នឹង មានមនុស្សច្រើនទេ? ហើយមានមនុស្សប្រភេទណាដែរ? ប្រុស ស្រី កុមារ ចាស់ជរា កងទ័ពអ៊ីចឹង តើលោកស្រីរៀបរាប់មើល តើមានប្រភេទរបស់មនុស្សដែលរស់នៅអង្គភាពជាមួយលោកស្រីហ្នឹងយ៉ាងម៉េចដែរ?

[១៥:១៧:១៤]

**ឆ៖** គឺរស់នៅក្នុងគុកនោះតាំងពីរយៈដែលខ្ញុំទៅ តែច្រើនតែកុមារ និងមនុស្សស្រី មនុស្សប្រុសអត់សូវមានទេ ។ កុមារច្រើនស្លាប់ ក៏ច្រើន មនុស្សស្រីស្លាប់ក៏ច្រើននៅគុកនោះតែម្តង ។

**ស៖** នៅទីនោះមនុស្សទូទៅ គេឲ្យធ្វើការងារអ្វីដែរ?

**ឆ៖** មនុស្សទាំងអស់នោះ មិនដឹងគេធ្វើអ្វីខ្លះទេ ។ ប៉ុន្តែ ឯចំណែកដូចពួកខ្ញុំទៅនេះ គេឲ្យខ្ញុំជីករណ្តៅ ដែលសម្រាប់កប់ក្មេងៗ ដែលងាប់នៅទីនោះ ។

**ស៖** អ៊ីចឹង មនុស្សផ្សេងទៀត ក្រៅពីខ្លួនលោកស្រី លោកស្រីមិនដឹងទេ ថាតើគេឲ្យធ្វើអ្វីខ្លះ គឺមិនដឹងទេ អ៊ីចឹងមែនទេ?

**ឆ៖** អ៊ីចឹងមែន ។

**ស៖** ចុះលោកស្រីក្រៅជីករណ្តៅកប់ខ្មោចកុមារក្មេងៗ ហ្នឹង តើលោកស្រីគេឲ្យធ្វើអ្វីទៀតដែរឬទេ?

**ឆ៖** គឺខ្ញុំជីកនោះ គឺរៀងរាល់ថ្ងៃ ទាល់តែខ្ញុំបានធូរស្រាលពីទុក្ខទោសទៅ នៅគេមិនសូវវាយ មិនសូវដុំ មិនសូវធ្វើបាបទៅ ក៏គេបញ្ជូនខ្ញុំទៅគុកព្រៃទទឹងទៅ គឺឃ្នួនចូលតែម្តង ។

**ស៖** លោកស្រីអះអាងថាទទួលបន្ទុកខាងជីករណ្តៅកប់ខ្មោចកុមារក្មេងៗ ។ សំណួរទីមួយសួរថាកន្លែងដែលជីករណ្តៅកប់ខ្មោចក្មេងៗហ្នឹង មានចម្ងាយប៉ុន្មានពីកន្លែងរោង ដែលលោកស្រី ឬក៏នាក់ផ្សេងទៀតហ្នឹងរស់នៅដេកនៅទីនោះ?

**ឆ៖** គឺចម្ងាយនោះ ឆ្ងាយក៏មិនឆ្ងាយពេក ជិតក៏មិនជិតពេក ។ ឯខ្ញុំអាចប៉ាន់ក៏មិនដែរ គឺចម្ងាយនោះ គឺខ្ញុំដើរមួយភ្លែតដែរដល់ ។

**ស៖** ហើយលោកស្រីជីករណ្តៅកប់ក្មេងៗ គ្រាន់តែជីករណ្តៅទេ ឬក៏នាំយកខ្មោចក្មេងៗ ទៅកប់នៅទីនោះដោយខ្លួនឯង តែម្នាក់ឯង?

[១៥:២០:០០]

**ឆ៖** ខ្ញុំគ្រាន់តែគេបញ្ជាឲ្យទៅជីករណ្ដៅទេ ឯងាប់មិនអីក៏ខ្ញុំអត់ដឹងដែរ ។

**ស៖** រណ្ដៅដែលលោកស្រីគេបញ្ជាឲ្យជីកហ្នឹងជម្រៅប៉ុនណាទៅ? ហើយទំហំប៉ុនណាដែរ? ទទឹងប៉ុន្មាន? បណ្ដោយប៉ុន្មាន?

**ឆ៖** នៅរណ្ដៅនៅក្នុងគុកព្រៃសនេះគឺទទឹង គឺកាលខ្ញុំជីកនោះបានប្រាំម៉ែត្របួនជ្រុងតែប៉ុណ្ណោះឯង ។

**ស៖** ជម្រៅប៉ុនណាដែរ ជម្រៅ?

**ឆ៖** ជម្រៅបួនម៉ែត្រ ទៅប្រាំម៉ែត្រតែប៉ុណ្ណោះ ។

**ស៖** លោកស្រីជីកតែម្នាក់ឯង ឬក៏មានគ្នាច្រើននាក់ក្នុងការជីករណ្ដៅកប់ក្មេងៗដែលមានជម្រៅ បួនម៉ែត្រ ទៅប្រាំម៉ែត្រនោះ?

**ឆ៖** គឺខ្ញុំជីកនេះគ្នាច្រើន មានប្រុសមានស្រី ប្រុសនោះតិចណាស់ជាងស្រីៗច្រើនជាងប្រុស ។

**ស៖** សរុបមើលលោកស្រីតាំងពីទៅរស់កន្លែងព្រៃស ដែលលោកស្រីអះអាងថាព្រៃស នោះតើជីករណ្ដៅជម្រៅបួន-ប្រាំម៉ែត្របួនជ្រុង ហើយជម្រៅដល់ទៅបួនម៉ែត្រ ទៅប្រាំម៉ែត្រហ្នឹងបានប៉ុន្មានរណ្ដៅដែរ ក្នុងអំឡុងពេលដែលលោកស្រីទៅដល់ទីនោះ ហើយមុននឹងចាកចេញ-- រហូតដល់ពេលចាកចេញទៅនៅកំពង់ចាមនោះ?

**ឆ៖** គឺខ្ញុំជីកបានតែមួយរណ្ដៅទេ ។

**ស៖** លោកស្រីរស់នៅព្រៃសហ្នឹងអស់រយៈពេលប្រហែលប៉ុន្មានខែ?

**ឆ៖** ខ្ញុំរស់នៅនៅក្នុងគុកព្រៃស អស់រយៈប្រហែលប្រាំខែ ប៉ុន្តែខ្ញុំធ្វើការបានតិច ព្រោះអីខ្ញុំជើងខ្ញុំជិតបាក់ហើយ ខ្ញុំជីកបានតែមួយនោះឯង ។

**ស៖** លោកស្រីបានប្រើពាក្យអំមិញថាគេធ្វើទារុណកម្ម ឬក៏យើងប្រើពាក្យសាមញ្ញថា គេបានប្រព្រឹត្តអំពើហិង្សាទៅលើខ្លួនលោកស្រីនៅក្នុងអំឡុងពេលលោកស្រីត្រូវបានគេយកទៅឃុំឃាំងនៅព្រៃស សំណួរសួរថា តើគេប្រព្រឹត្តអំពើយ៉ាងម៉េចទៅលើខ្លួនលោកស្រី?

**ឆ៖** គេធ្វើបាបវាយដំខ្ញុំតាមទំនើងចិត្តវាទាំងអស់ សូម្បីឆ្លើយវា តវ៉ាជាមួយវាហើយ ក៏វានៅតែមិនព្រម នៅតែវ៉ៃខ្ញុំ គៀបខ្ញុំតែរហូត ។ នេះហើយជាការធ្វើបាបចំពោះរូបយើងខ្ញុំ ។

[១៥:២៣:២៤]

**ស៖** គេវាយលោកស្រីនឹងអីទៅ? ហើយកៀបៗនឹងអ្វីទៅ? យើងសួរអំពីដំណើររឿងដែលលោកស្រីទៅដល់ព្រៃស យើងមិនសួរកាលពីលោកស្រី អំឡុងពេលថា អះអាងថាឃុំឃាំងនៅស-២១ ឬក៏ទួលស្លែងទេ គឺសួរថាលោកស្រីទៅដល់ព្រៃស ។ តើគេវាយ គេដំ គេកៀបហ្នឹង កៀបយ៉ាងម៉េច? ហើយកៀបនឹងឧបករណ៍អ្វី? ឬក៏វាយនឹងឧបករណ៍អ្វីដែរ? ហើយវាយប៉ុន្មានលើក?

**ឆ៖** នៅក្នុងគុកព្រៃស នេះ ខ្ញុំចេញពីនេះទៅ នៅទីនេះក៏គេធ្វើបាប ទៅដល់គុកព្រៃស ក៏គេវាយដំខ្ញុំកៀបនឹងខ្នោះជើងដូចតែនៅឯណោះអ៊ីចឹងដែរ ។ ប៉ុន្តែ គេវាយខ្ញុំនឹងរំពាត់ផ្តៅមួយ វាយទៅលើខ្នងរបស់យើងខ្ញុំ ។

**ស៖** អ៊ីចឹងបានន័យថា លោកស្រីទៅដល់ព្រៃស ហ្នឹង ក៏គេនៅតែដាក់ឃុំឃាំងលោកស្រីដាក់ជាប់ខ្នោះ ឬក៏ដាក់នៅក្នុងបន្ទប់ឃុំឃាំងអ៊ីចឹងដដែល ។ អ៊ីចឹងមែនទេ?

**ឆ៖** ពិតមែនហើយ នៅក្នុងគុកព្រៃស ពោលពាក្យថា អ្នកយកទៅក្នុងគុកព្រៃស គឺគេអត់ធ្វើបាប យកទៅកសាងខ្លួន ។ អ្នកនិយាយនោះ គឺចេះតែនិយាយទេ ដែលយកអ្នកទោសទៅក្នុងនៅគុកព្រៃស មួយៗសុទ្ធតែធ្វើទារុណកម្មមុននឹងយកទៅវ៉ៃចោល ។

**ស៖** គេដាក់ឃុំឃាំងលោកស្រីនៅព្រៃស គេឃុំឃាំងយ៉ាងម៉េច? ពេលយប់ធ្វើយ៉ាងម៉េច? ពេលថ្ងៃគេធ្វើយ៉ាងម៉េច?

**ឆ៖** ពេលយប់ៗគេចាក់សោពីក្រៅ គេដាក់ខ្នោះជើងយើងខ្ញុំ ពេលថ្ងៃរៀបបណ្តើរយើងខ្ញុំទៅកាប់ដី គឺគេដោះខ្នោះចេញ ហើយគេបណ្តើរខ្ញុំទៅកាប់ដី ។ នុ៎ងទោសខ្ញុំដែលរាងស្រាលបន្តិចហើយ ។

**ស៖** គេដាក់ខ្នោះជើងលោកស្រីហើយនិងចាក់សោពីក្រៅនៅអគារហ្នឹង មានមនុស្សច្រើននាក់ទេជាមួយលោកស្រី ឬក៏មានតែម្នាក់ឯងទេគេធ្វើដូច្នេះ?

**ឆ៖** គឺអគារនោះនៅយ៉ាងច្រើន នៅប្រហែលជាសាមសែសិបនាក់ គឺធ្វើដូចគ្នាតែអ៊ីចឹង ទាំងអស់តែម្តង ហើយគេថា អគារនោះគេសម្រាលទោសមនុស្ស គឺមិនសម្រាលទេ រឹតថែម រឹតយកទៅវ៉ៃចោលនៅគុកព្រៃស នេះឯង ។

[១៥:២៦:២៣]

**ស៖** លោកស្រីគេឲ្យជីករណ្តៅសម្រាប់កប់ខ្មោចកុមារក្មេងៗហ្នឹង ធ្វើនៅពេលណា? មួយថ្ងៃធ្វើប៉ុន្មានពេល? ចាប់ពីម៉ោងប៉ុន្មាន ដល់ម៉ោងប៉ុន្មានដែរ?

**ឆ៖** គេដោះលែងខ្ញុំទៅកាប់ដីនៅពេលវេលាម៉ោងប្រាំមួយព្រឹក ទាល់ម៉ោងដប់ពីរថ្ងៃពេលបាយ ហើយហូបតែបបរទេ មិនបានបាយទេ ។ ល្ងាចពីម៉ោងមួយដល់ម៉ោងប្រាំ ។

**ស៖** ហើយពេលយប់មានគេឲ្យធ្វើការដែរទេ?

**ឆ៖** ពេលយប់ គឺអត់ធ្វើទេ គេចាក់សោដាក់ក្នុងបន្ទប់ ។

**ស៖** នៅក្នុងអំឡុងពេលដែលលោកស្រីធ្វើការជីករណ្ដៅជម្រៅបួនទៅប្រាំម៉ែត្រសម្រាប់កប់សពកប់ខ្មោចកុមារក្មេងៗហ្នឹង តើអ្នកធ្វើការ បុគ្គលិកធ្វើការនៅមន្ទីរព្រៃស ហ្នឹងគេបានយាមកាមមើលលោកស្រី ខ្លាចលោកស្រីរត់ ឬក៏ខ្លាចអ្នកដែលផ្សេងទៀតធ្វើការជាមួយនិងលោកស្រីរត់ដែរឬទេ? ឬក៏គេបណ្ដោយឲ្យលោកស្រី និងអ្នកផ្សេងទៀតធ្វើការធម្មតា ដោយបុគ្គលិកផ្សេងទៀតមិនបានមកក្បែរមកមើលការខុសត្រូវឃ្លាំមើលពួកលោកស្រីធ្វើការទេ?

**ឆ៖** គឺអ្នកយាមដែលខ្ញុំធ្វើការនោះ គេយាមជុំវិញនៅអង្គុយចាំមើលពួកខ្ញុំធ្វើហ្នឹង មានកាំភ្លើងម្នាក់មួយដើមហ្នឹង គឺអង្គុយយាមពួកខ្ញុំធ្វើការហ្នឹង ទាល់តែដល់ម៉ោងបានគេជូនពួកខ្ញុំទៅវិញ ។

**ស៖** លោកស្រីថា ជីករណ្ដៅសម្រាប់កប់កុមារ ហើយមើលទៅរណ្ដៅហ្នឹងមានជីកទ្រង់ទ្រាយធំប្រាំម៉ែត្របួនជ្រុង ហើយជម្រៅបួនទៅប្រាំម៉ែត្រឯណោះ ។ សំណួរសួថា តើកុមារដែលគេយកទៅកប់នៅនោះស្លាប់ដោយសារជំងឺ ឬក៏ត្រូវគេនាំយកទៅសម្លាប់បានជាជីករណ្ដៅធំ ហើយជ្រៅដូច្នេះ?

**ឆ៖** គឺខ្ញុំមិនដឹងឈឺ ឬមួយគេសម្លាប់ គឺយើងខ្ញុំអត់ដឹងដែរ ដឹងតែខ្ញុំបានជីករណ្ដៅនៅក្នុងនោះ ហើយឃើញកុមារស្រែកយំខ្លាំងលាន់ឮ ប៉ុន្តែមិនដឹងជាយំដោយសារជំងឺ ឬមួយយំដោយសារគេវៃចោល គឺខ្ញុំមិនអាចដឹងដែរ ។

**ស៖** លោកស្រីនិយាយអំមិញថា លោកស្រីនៅទីនោះបានបីខែ ហើយក៏គេបានបញ្ជូនលោកស្រីចេញ ។ តើគេបញ្ជូនលោកស្រីចេញទៅកាន់កន្លែងណា? ហើយមធ្យោបាយដែលបញ្ជូនលោកស្រីចេញទៅហ្នឹង គេបញ្ជូនទៅដោយមធ្យោបាយអ្វីដែរ?

**ឆ៖** គឺគេបញ្ជូន គេសម្រាលទោសយើងខ្ញុំនេះ ថាឲ្យខ្ញុំហ្នឹងទៅរកឪពុកម្ដាយនៅឯស្រុកកំពង់ចាមហ្នឹងវិញ ។ គេឈប់ដាក់គុកយើងខ្ញុំហើយ ប៉ុន្តែ ព័ត៌មានគេទៅមុខថាយកខ្ញុំហ្នឹងទៅដាក់គុកព្រៃទទឹង ដល់ពេលគេឲ្យខ្ញុំជិះឡានទៅដល់គុកព្រៃទទឹង គឺគេបញ្ចូលខ្ញុំនៅក្នុងគុកព្រៃទទឹងហ្នឹងទៀត ។ ពីនេះទៅគេថាឲ្យខ្ញុំហ្នឹងទៅរកឪពុកម្ដាយ ព្រោះអីខ្ញុំដាក់ប្រវត្តិឪពុកម្ដាយខ្ញុំ គឺមិនមែនឪពុកម្ដាយដែលស្លាប់ហ្នឹងទេ ខ្ញុំយកឪពុកធម៌ធ្វើជាឪពុកម្ដាយរបស់ខ្ញុំ ឯខ្ញុំធ្វើប្រវត្តិរូប គឺតាមនុ៎ងដែរ ។

[១៥:៣០:២៥]

**ស៖** លោកស្រីទៅជាប់នៅគុកព្រៃទទឹងហ្នឹងរយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំទៅដល់គុកព្រៃទទឹងហ្នឹងក៏ខ្ញុំចុះពីលើឡានទៅ ក៏បានប្អូនចិញ្ចឹមខ្ញុំមួយក៏ជាប់គុកនៅទីនោះដែរ ក៏ខ្ញុំជាប់ពីរនាក់បងប្អូនរយៈប្រហែលពីរខែ ទៅយួនចូលមកដល់រំដោះយើងខ្ញុំយកទៅ ។

**ស៖** ឥឡូវត្រឡប់បកក្រោយបន្តិច ។ លោកស្រីចាប់តាំងពីគេចាប់ខ្លួនលោកស្រីដំបូង ទីមួយគេប្រាប់អំពីមូលហេតុនៃការចាប់ខ្លួនលោកស្រីដែរឬទេ?

**ឆ៖** កាលដើមដំបូងចាប់ខ្លួនខ្ញុំក៏គេអត់ប្រាប់ខ្ញុំទេ ហៅខ្ញុំឡើងទៅ គេដាក់ខ្នោះតែម្តង ។ ខ្ញុំអត់ដឹងកំហុសខ្លួនឯងកើតអីផង ។

**ស៖** គេបានធ្វើកំណត់ត្រាសួរជីវប្រវត្តិរូបរបស់លោកស្រីដែរឬទេ មុនពេលបញ្ជូនទៅឃុំឃាំងនោះ?

**ឆ៖** គេបានសួរពីឪពុកម្តាយ ប្រវត្តិដែលឪពុកម្តាយខ្ញុំ គ្រួសារខ្ញុំទាំងអស់ គេបានសួរ គេចោទថាខ្ញុំៗ-- ខ្ញុំប្រកែកគេ ខ្ញុំថាខ្ញុំអត់មែនកូនឈ្មោះប្រាក់ ហ្នឹងទេ ខ្ញុំកូនឪពុកខ្ញុំឈ្មោះ រឿន ។ ហើយគេអត់ជឿខ្ញុំថាខ្ញុំហ្នឹងកូនឈ្មោះ ប្រាក់ ហ្នឹង ឥឡូវគេអាចចាប់ខ្ញុំ ដាក់ខ្នោះខ្ញុំ គំរាមខ្ញុំ ថាខ្ញុំហ្នឹងសុទ្ធតែពួកក្បត់ពួកខ្មែរក្រហមក្បត់ ។

**ស៖** ប្រវត្តិរបស់លោកស្រីសរសេរថា ឪពុកឈ្មោះ រឿន ហ្នឹង ស្អី រឿនទៅឪពុក? (ឈប់សិនចាំភ្លើងពណ៌ក្រហមសីមនិយាយ) ។

**ឆ៖** ឪពុកចិញ្ចឹមខ្ញុំឈ្មោះ រឿន ហ្នឹង គាត់នាមត្រកូលគាត់ រឹម រឿន ដល់មកខ្ញុំៗដាក់ រឿន ចាន់ថា ឪពុកចិញ្ចឹម ។

**ស៖** ចុះកាលលោកស្រីធ្វើជាបុគ្គលិកពេទ្យ លោកស្រីអះអាងថានៅមន្ទីរស-២១ ហ្នឹងលោកស្រីប្រើឈ្មោះអ្វីច្បាស់លាស់ពិតប្រាកដ? ឈ្មោះ ណាំ ម៉ុន ឬក៏ឈ្មោះ រឿន ចាន់ថ ។

**ឆ៖** ខ្ញុំប្រើឈ្មោះ រឿន ចាន់ថា ជាបន្តបន្ទាប់មកទាល់តែដាច់ភ្នំពេញនេះឯង ទាល់តែយួនចូលនេះរហូតមក ។

**ស៖** ចុះពេលដែលគេសួរប្រវត្តិរូបលោកស្រី លោកស្រីប្រើឈ្មោះ រឿន ចាន់ថា អ៊ីចឹង ឬក៏ប្រើឈ្មោះ ណាំ ម៉ុន នៅពេលដែលគេបុគ្គលិកកន្លែងឃុំឃាំងហ្នឹងគេសួរព័ត៌មានពីជីវប្រវត្តិលោកស្រីនោះ?

[១៥:៣៤:០៦]

**ឆ៖** គេសួរចម្លើយខ្ញុំ ខ្ញុំក៏ឈ្មោះ រឿន ចាន់ថា ។ គេសួរថា រឿន ចាន់ថា ហ្នឹងគឺនៅទីណាអី? ខ្ញុំប្រាប់ថាគាត់នៅភូមិព្រៃកសង្កែ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមដូចគ្នា ។ ចុះគេចោទខ្ញុំថា ខ្ញុំខាងនិរតីយកខ្ញុំទៅសម្លាប់ថែមទៀត ។ និយាយយ៉ាងម៉េចក៏អត់ត្រូវនឹងគេដែរ ។

**ស៖** ចុះកាលពីគេសួរព័ត៌មានពីបុគ្គលិកនៃកន្លែងឃុំឃាំងហ្នឹងសួរព័ត៌មានលោកស្រីអំពីឈ្មោះម្តាយរបស់លោកស្រី តើលោកស្រីដាក់ម្តាយ ឈ្មោះម្តាយលោកស្រីនៅក្នុងប្រវត្តិរូបពេលគេសួរហ្នឹងឈ្មោះអ្វីដែរ?

**ឆ៖** ប្រវត្តិរូបម្តាយចិញ្ចឹមខ្ញុំ ម្តាយខ្ញុំឈ្មោះ រីម ។ ដាក់ម្តាយឈ្មោះ រីម ឪពុកឈ្មោះ រឿន ។ ដាក់តែម្តាយចិញ្ចឹមទេ ម្តាយបង្កើតខ្ញុំអត់ហ៊ានដាក់ទេ គឺខ្លាចគេយកខ្ញុំទៅវៃចោលដូចគាត់ដែរ ។

**ស៖** អំមិញលោកស្រីបាននិយាយថា ឪពុកចិញ្ចឹមរបស់លោកស្រីឈ្មោះ រីម រឿន ស្រាប់តែឥឡូវនេះលោកស្រីនិយាយថា ម្តាយចិញ្ចឹមរបស់លោកស្រីឈ្មោះ រីម ។ តើត្រកូលឪពុកចិញ្ចឹមរបស់លោកស្រីហ្នឹង ឈ្មោះអីច្បាស់លាស់?

**ឆ៖** ត្រកូលរបស់ឪពុកចិញ្ចឹមខ្ញុំឈ្មោះ រីម រឿន ។ ឯចំណែកម្តាយខ្ញុំក៏ឈ្មោះ រីម ដែរ ។

**ស៖** ត្រកូលគាត់ស្អី រីម ទៅ?

**ឆ៖** ម្តាយចិញ្ចឹមខ្ញុំឈ្មោះ ហាក់ រីម ឪពុកចិញ្ចឹមឈ្មោះ រីម រឿន ។

**ស៖** ឪពុកចិញ្ចឹមឈ្មោះ រីម រឿន អ៊ីចឹង? នៅខណៈពេលនោះ គេមានបានថតរូបលោកស្រីរូបពាក់កណ្តាលខ្លួននៅមុនពេលដាក់ឃុំឃាំងលោកស្រី តើគេមានថតរូបលោកស្រីដែរឬទេ?

**ឆ៖** គឺអត់បានថតផង ។ ខ្ញុំជាប់រយៈកាលតិចពេកនៅគុកទួលស្លែងនេះ បានតែបីខែ ហើយគេថតខ្ញុំអត់ទាន់ទេ ព្រោះរយៈនោះអ្នកណាជាប់យូរ គឺថតបានយូរ ។

**ស៖** ចុះពេលលោកស្រីគេបញ្ជូនទៅមន្ទីរអប់រំកែប្រែសាជាថ្មីព្រៃស តើនៅទីនោះបានចាត់ចែងថតរូបរបស់លោកស្រីដែរឬទេ?

**ឆ៖** នៅឯគុកព្រៃស គឺខ្ញុំបានថត ប៉ុន្តែខ្ញុំរករូបថតខ្លួនខ្ញុំអត់ឃើញ ។

**ស៖** នៅព្រៃស តើមានការ គេដកស្រង់នូវប្រវត្តិរូបរបស់លោកស្រីសាជាថ្មីរបស់លោកស្រីម្តងទៀតដែរឬទេ?

**ឆ៖** នៅគុកព្រៃសនេះ គឺសួរចម្លើយលើកម្តង ទៅពីរដង គឺខ្ញុំ ខ្លួនខ្ញុំផ្ទាល់គឺឆ្លើយនៅតែម៉ាត់ណាគឺម៉ាត់ហ្នឹង ខ្ញុំអត់មានកែប្រែពាក្យទៅណា រួចហើយគេថា ខ្ញុំស្មោះត្រង់នឹងគេ ក៏គេលើកលែងទោស

ឱ្យទៅ ។

**ស៖** លោកស្រីបានអះអាងថា គ្រួសាររបស់លោកស្រីទាំងមូលសរុប៧នាក់ ឪពុកម្ដាយ បងប្អូនប្រុសប្អូននាក់ រួមទាំងរូបស្រីផង គឺប្រាំពីរនាក់ៗហ្នឹង គឺត្រូវបានគេសម្លាប់ចំនួន ប្រាំមួយនាក់ គឺនៅសល់តែលោកស្រីម្នាក់ទេ ។ ក្រៅពីអ្វីដែលលោកស្រីបាននិយាយរៀបរាប់ជូនអង្គសវនាការទាំងមូលបានស្ដាប់កន្លងមកនេះ តើលោកស្រីមានរបស់អ្វីផ្សេងទៀតទេ ដើម្បីបញ្ជាក់ទៅលើការអះអាងរបស់លោកស្រីនេះ?

**ឆ៖** គឺរបស់អីទៅ? អត់យល់ផង ។

**ស៖** លោកស្រីនិយាយអំមិញថា លោកស្រីបានប្រឹងប្រែក្នុងការរករូបថតដែលលោកស្រីបានដឹងថា ពេលដែលគេបញ្ជូនលោកស្រីទៅដល់ព្រៃស គឺគេបានថតរូបលោកស្រីដែរ ប៉ុន្តែលោកស្រីរកមិនឃើញទេ ។ សំណួរសួរថា រូបថតរបៀបនេះ តើវាមានរបស់សមាជិករបស់គ្រួសាររបស់លោកស្រីដែលស្រីអះអាងបានថា អះអាងថាត្រូវបានគេសម្លាប់នៅមន្ទីរស-២១ ឬក៏ទួលស្លែងនោះ ដែរឬទេ? បើរករូបថតខ្លួនឯងមិនឃើញ តើរូបថតអ្នកផ្សេងទៀតដែលជាសាច់ញាតិរបស់លោកស្រី លោកស្រីបានរកដែរឬទេ?

**ឆ៖** គឺរូបទាំងឪពុក ទាំងម្ដាយ បងប្អូនខ្ញុំ បងថ្លៃ បងជីដូនមួយអីទាំងអស់ គឺខ្ញុំរកឃើញនៅគុកទួលស្លែងទាំងអស់ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីខាងសោតទស្សន៍ចូរបង្ហាញនូវរូបមួយដែលមានលេខជា ERN ភាសាអង់គ្លេស ដែលមានលេខ 00274367 នៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។

លោកស្រី ណាំ ម៉ុន តើអាចបន្តទៅមុខបានទេ ឬក៏សុំសម្រាកមួយភ្លែតសិន ។

**លោកស្រី ណាំ ម៉ុន៖**

ខ្ញុំសុំសូមសម្រាក ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកដប់មីនុត ដើម្បីឱ្យដើមបណ្ដឹងរដ្ឋប្បវេណីនេះសម្រួលនូវអារម្មណ៍របស់ខ្លួនឡើងវិញ ។

*[សវនាការសម្រាកពីម៉ោង ១៥:៤៣នាទី ដល់ម៉ោង ១៥:៥៧នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តនីតិវិធីពិភាក្សាដេញដោលតទៅទៀត។ ម៉េចទៅ ណាំ ម៉ុន អាចមានអារម្មណ៍ល្អឡើងវិញហើយមែនទេ ណាំ ម៉ុន ?

**លោកស្រី ណាំ ម៉ុន៖**

អារម្មណ៍បានធូរស្រាលបន្តិច ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តនេះសូមខាងសោតទស្សន៍បង្ហាញនូវរូបភាពនៅលើកញ្ចក់អេក្រង់ទូរទស្សន៍ ។ ទីមួយ គឺលេខ ERN ជាភាសាអង់គ្លេស គឺលេខ 00274367 មួយទៀតគឺ 43684369 ជាប់គ្នា ហើយនិង 4370 ។

ខាងបុគ្គលិកវីស្ស៊ូតើមានអញ្ជើញមកទេ? អាចទៅអង្គុយនៅក្បែរគាត់ ដើម្បីឲ្យគាត់មានការកក់ក្តៅបន្តិច ដើម្បី-- នីតិវិធីនេះយើងប្រព្រឹត្តទៅតែបន្តិចទេ ។ មើលៗរូបនេះ តើៗលោកស្រីស្គាល់ទេ? តើរូបថតនេះជារូបថតអ្នកណាគេ?

មន្ត្រីផ្នែកខាងសោតទស្សន៍ដករូបនេះចេញវិញ ។ ដោយហេតុថា នៅអំឡុងពេលចុងម៉ោងថ្ងៃនេះ ដើមបណ្តឹងរដ្ឋប្បវេណីមានអារម្មណ៍រន្ធត់ចិត្តយ៉ាងខ្លាំង ដែលមិនអាចឲ្យអង្គជំនុំជម្រះដំណើរការទៅមុខបានទេ ហើយអំឡុងពេលវេលាក៏តិចដែរ នៅសល់តែដប់ប្រាំមីនុតទៀតប៉ុណ្ណោះ ។ ហើយដើម្បីសម្រួលដល់អារម្មណ៍របស់គាត់ អង្គជំនុំជម្រះសម្រេចថាសវនាការសម្រាប់ថ្ងៃនេះ គឺផ្អាកត្រឹមនេះសិនហើយសវនាការលើកទៅបន្តនៅថ្ងៃ ព្រឹកថ្ងៃច័ន្ទវេលាម៉ោងប្រាំបួនព្រឹក ។ ថ្ងៃច័ន្ទទី១៣ ខែកក្កដា ឆ្នាំ២០០៩ ចាប់ពីវេលាម៉ោងប្រាំបួនព្រឹក ។

[១៦:០១:២៨]

ដូច្នេះ សូមអញ្ជើញភាគីមកចូលរួមតាមការកំណាត់ ។ ណាំ ម៉ុន ឥឡូវនេះអង្គជំនុំជម្រះសម្រេចផ្អាកសវនាការត្រឹមនេះ ហើយដោយបញ្ហាលោកស្រីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនៅមាន-- ការសំណួរពាក់ព័ន្ធទៅនឹងលោកស្រីជាច្រើនទៀត ទាំងអង្គជំនុំជម្រះ ទាំងភាគី ។ ដូច្នេះ អង្គជំនុំជម្រះផ្អាកពីពេលនេះទៅ ដើម្បីឲ្យលោកស្រីមានការបន្ធូរអារម្មណ៍ឲ្យបានល្អ ហើយដំណើរការសវនាការចាប់ធ្វើជាបន្តនៅព្រឹក-- ចាប់ពីពេលម៉ោងប្រាំបួនព្រឹក ថ្ងៃច័ន្ទសប្តាហ៍ក្រោយ ។ ហើយមន្ត្រីតុលាការសម្របសម្រួលឲ្យគាត់បានត្រឡប់ទៅលំនៅដ្ឋានវិញ ដោយសម្របសម្រួលខាងផ្នែកគាំពារជនរងគ្រោះ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងប្រាំបួនព្រឹកថ្ងៃច័ន្ទទី១៣ ខែកក្កដា អាទិត្យក្រោយ ៕

*[សវនាការផ្អាកនៅម៉ោង ១៦:០៣នាទី]*